ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Jun-2017, 12:57
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៩នាទី**

**សវនាការលើកទី២៤៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ៊ាង

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ស្រ៊ា រតនៈ

លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de Wilde d'Estmael)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក សួន វិសាល

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ទ្រី ស៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំច អរុណ

លោកស្រី ស្ហូ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក សួន វិសាល | ខ្មែរ |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| ព្រះតេជព្រះគុណ ឯម ភឿង (2-TCW-954) | ខ្មែរ |
| លោក ភ្នៅ យ៉ាវ (2-TCW-934) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ ព្រះតេជព្រះគុណ ឯម តឿង** (2-TCW-954)

សួរដោយលោក ស្រ៊ា រតនៈ ផ្ដើមពី ........................................ទំព័រ ៩

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ........................................ទំព័រ ២១

សួរដោយលោក វ៉េន ពៅ ផ្ដើមពី ........................................ទំព័រ ៣៦

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ........................................ទំព័រ ៤០

សួរដោយលោក សួន វិសាល ផ្ដើមពី ........................................ទំព័រ ៤៦

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........................................ទំព័រ ៤៩

សួរដោយលោក គង់ សំអុន ផ្ដើមពី ........................................ទំព័រ ៥៦

**ការសួរសំណួរទៅសាក្សី៖ លោក ភ្លៅ យ៉ាច** (2-TCW-934)

សួរដោយលោកប្រធានអង្គជំនុំ ផ្ដើមពី ........................................ទំព័រ ៨០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៩:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្តីកម្មសាក្សីព្រះតេជព្រះគុណ ឯម ភឿង ហើយព្រះតេជព្រះគុណ ឯម ភឿង គឺអង្គជំនុំជម្រះបាននិមន្តព្រះអង្គមកចូលរួមក្នុងការផ្តល់សក្ខីកម្មម្តងហើយ កាលពីសប្តាហ៍កន្លងទៅ។ ប៉ុន្តែដោយសារពេលវេលាត្រូវធ្វើសវនាការបន្ទាប់ហ្នឹង ស្តាប់សក្ខីកម្មអ្នកជំនាញ អេលីហ្សាបេត បេកឃ័រ អ៊ីចឹង អង្គជំនុំជម្រះមិនបានស្តាប់សក្ខីកម្មរបស់ព្រះអង្គទេ។ ហើយអង្គជំនុំជម្រះបានប្រាប់អំពីសិទ្ធិនិងករណីយកិច្ច និងសួរសាវតារព្រះអង្គរួចហើយ។ ហើយអង្គជំនុំជម្រះនឹងបន្តផ្តល់វេទិកាជូនទៅភាគីពាក់ព័ន្ធដោយមិនបាច់សួរពីប្រវត្តិសាវតារនិងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងការចូលរួមក្នុងឋានៈជាសាក្សីនៅក្នុងដំណើរការនីតិវិធីជំនុំជម្រះទៀតទេ។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺព្រះតេជព្រះគុណ ឯម ភឿង។ ព្រះតេជព្រះគុណមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ រីឯសាក្សីបម្រុងសម្រាប់សវនាការនៅថ្ងៃនេះ មានសាក្សីដែលមានរហស្សនាម 2-TCW-934។ សាក្សីរូបនេះ បានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះនឹង

ធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនៅម៉ោងដប់ព្រឹកនេះមុនពេលមកផ្តល់សក្ខីកម្ម។ សូមអរគុណលោកប្រធាន។

[០៩:១១:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

ឥឡូវនេះ អង្គជំនុំជម្រះសម្រេចទៅលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថាដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ វិលមុខ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការឲ្យមានប្រសិទ្ធភាពនាពេលខាងមុខ ខ្លួនសុំលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥។ ហើយគាត់បានបញ្ជាក់ថា មេធាវីការពារក្តីរបស់គាត់បានជម្រាបអំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះហើយថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់នឹងភស្តុតាងនៅក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

ដោយបានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ជាទូទៅ គឺមិនមានអ្វីប្រែប្រួលទេ។ មាន -- ថ្ងៃនេះគាត់មានការអាការៈឈឺចង្កេះខ្លាំង វិលមុខ មិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់ នៅតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ឃុំមួយនៅខាងក្រោមសាលសវនាការនេះ។

[០៩:១៣:១៥]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការ

ដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់លោក នួន ជា អាច ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនដល់ភាគីផងដែរថា នៅថ្ងៃនេះមានបញ្ហាធនធានអ្នកបកប្រែ ដោយសារមានបញ្ហាសុខភាព។ ដូច្នេះ អង្គជំនុំជម្រះនិងអង្គភាពបកប្រែភាសាប្រឹងសម្របសម្រួល ដើម្បីឲ្យដំណើរការសវនាការអាចប្រព្រឹត្តទៅបាន។ ដូច្នេះ សូមឲ្យភាគីពាក់ព័ន្ធ មេត្តាធ្វើការតាំងសំណួរដេញដោលឲ្យបានយឺត ឬក៏មានការដកឃ្លារវាងចម្លើយហើយនិងសំណួរ ដើម្បីសម្រួលដល់ការបកប្រែភាសាហ្នឹងឲ្យបានពេញលេញល្អ។ ហើយសង្ឃឹមថា អស់លោក លោកស្រីមានការផ្ដល់អារម្មណ៍ និងការយកចិត្តទុកដាក់លើបញ្ហានេះផងដែរនៅក្នុងអំឡុងពេលពិភាក្សាដេញដោលថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីសួរដេញដោលសាក្សីព្រះតេជព្រះគុណ ឯម ភឿង មុនភាគីដទៃទៀតនៃរឿងក្ដី។

កុំអាលទាន់!

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[០៩:១៤:៥៦]

**លោក វ៉ិចទ័រ កូប៉េះ**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។

លោកប្រធាន ខ្ញុំសុំទោសដែលខ្ញុំក្រោកឈរមុនសហព្រះរាជអាជ្ញាតាំងសំណួរទៅកាន់សាក្សី។ ប៉ុន្តែ ខ្ញុំលើកបញ្ហាមួយនៅពេលនេះដោយសារទាក់ទងទៅនឹងសាក្សីអង្គនេះ <ហើយវាគឺជាបញ្ហាសំខាន់មួយ។> ប្រហែលជាលោកប្រធាននៅចាំហើយ <បី>សប្ដាហ៍មុន បាទ ខ្ញុំ<បានក្រោកឈរឡើងហើយសួរ>ឲ្យមានការបញ្ជាក់អំពីកំណត់ហេតុ<ស្ដាប់>ចម្លើយ<សាក្សីចំនួនបួនថ្មី> ដែលដាក់ចូលទៅក្នុងសំណុំរឿង គឺឯកសារចេញមកពីសំណុំរឿង០០៤ ខ្ញុំសូមឲ្យមានការបញ្ជាក់នៅថ្ងៃទី២៦ ខែ<មេសា> ២០១៥<*(ស៊ីក)*> ខ្ញុំមានប្រតិចារឹក ERN អង់គ្លេស <01060391>, បារាំង <01060293> ដល់ 4, ខ្មែរ 01060886 ដល់ 87។ ឥឡូវនេះ ខ្ញុំសូមអានប្រតិចារឹក "សំណួរទី២ របស់ខ្ញុំគឺប្រសិនណាជា<កំណត់ហេតុស្ដាប់ចម្លើយសាក្សីចំនួនបួននោះ ត្រូវបានបង្ហាញនោះ ថាតើមានអ្វីច្រើន

ទៀតចេញមកពាក់ព័ន្ធនឹងវគ្គសវនាការនេះដែរឬទេ?>” ខ្ញុំសូម<បញ្ចប់ការដកស្រង់។> ហើយសហព្រះរាជអាជ្ញា <គឺលោក ដេលីសាក់> ពេលនោះបានឆ្លើយតប ខ្ញុំសូមអាន គាត់បាននិយាយដូចខាងក្រោមនេះ ខ្ញុំដកស្រង់៖ “មានចម្លើយបន្ថែមទៀត តាមដែលខ្ញុំដឹងមិនពាក់ព័ន្ធ<សវនាការស្តាប់សក្ខីកម្មសាក្សី>ទេ ក៏ប៉ុន្តែយើងបានស្នើសុំរួចទៅហើយ។ ហើយនៅពេលមានការដាក់ចូល<កំណត់ហេតុស្តាប់ចម្លើយសាក្សីថ្មី>ទាំងអស់នេះ គឺថានឹងបង្ហាញជូនជាសាធារណៈ<។ ប៉ុន្តែវាមិនមានការពាក់ព័ន្ធទៅនឹងសវនាការស្តាប់សក្ខីកម្មសាក្សីនោះទេ។>”។ ហើយគាត់បាននិយាយថា សុំដកស្រង់៖ “តាមដែលខ្ញុំចាំគឺឯកសារនេះ មានចំនួនតិចតួចទេ”។

[០៩:១៧:០៨]

កាលពី<ថ្ងៃសុក្រ>សប្តាហ៍កន្លងទៅនេះ <យើង>បានទទួលព័ត៌មានពីសហព្រះរាជអាជ្ញាគឺថាមានចម្លើយសាក្សី ២០ចេញពីសំណុំរឿង០៤ យកមក<ប្រើប្រាស់នៅព្រឹកនេះ។> ហើយយើងអត់ទាន់បានទទួលនូវចម្លើយសាក្សីទាំងអស់នេះនៅឡើយទេ។ ខ្ញុំមិនដឹងថាតើចម្លើយសាក្សីទាំង២០នេះថា<ពាក់ព័ន្ធតួលេខតិចតួចរបៀបម៉េច។ អ្វីដែលខ្ញុំបារម្ភនោះ ថាមានពាក្យចចាមអារ៉ាមដ៏រឹងមាំមួយ ហើយខ្ញុំមិនដឹងថាតើវាជាការពិតឬក៏អត់ទេ>។ តែ<>គឺថានឹងមានចម្លើយសាក្សីដល់រាប់រយឯណោះមកពីសំណុំរឿង០០៤ ដែលត្រូវដាក់ចូលមកក្នុងសំណុំរឿងនេះ។ ប្រសិនណាបើបញ្ហានេះជាការពិតគឺថា យើងជួបប្រទះនូវស្ថានភាពធ្ងន់ធ្ងរមួយហើយ ដោយសារថាកិច្ចដំណើរការនីតិវិធីតាំងសំណួរទៅកាន់សាក្សីកំពុងតែដំណើរការទៅមុខ ហើយ<ខ្ញុំមិនដឹងមានអ្វីខ្លះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយទាំងនោះ ហើយលោកក៏មិនដឹងដូចគ្នាដែរ>។ ដូច្នេះ សំណួររបស់ខ្ញុំនោះគឺទាក់ទងទៅនឹងចម្លើយពីខាងដើមរបស់សហព្រះរាជអាជ្ញា ដែលគេហៅថាការផ្តល់ឲ្យនូវសាច់ក្រកហុងគ្រី ឬអ៊ីតាលី ឬក៏យុទ្ធសាស្ត្រ>សូឡាមី <ក្នុង>ចំនួនតូច <ឬក៏ថាតើនឹងមានអ្វីកើតឡើងនោះ>។ <ហើយខ្ញុំពិតជាចង់ដឹងខ្លាំងណាស់ ពីព្រោះ> វាអាចប៉ះពាល់ទៅដល់សាក្សីអង្គនេះ ហើយក៏ដូចជាសាក្សីក្រោយៗទៀតដែរ។ តែបើសិនណាជា<ការពិតមែននោះ គឺថា>ចម្លើយនោះមានដល់រាប់រយ ខ្ញុំយល់ថាមិនអាចទទួលយកបានទេ។ ប្រហែល<ជាយើងត្រូវការ – ខ្ញុំមិនដឹងថាលោកប្រធានអនុញ្ញាតដែរឬអត់ទេ ប៉ុន្តែយើងសូមស្នើ>សុំឲ្យពន្យារកិច្ចដំណើរការនីតិវិធីរហូតដល់ពួកយើងបានអាននូវឯកសារទាំងអស់នេះសិន។ <ខ្ញុំសូមអភ័យទោសដែលលើកយកបញ្ហានេះឡើងនៅពេលនេះ ប៉ុន្តែខ្ញុំគិតថាវាពាក់ព័ន្ធ>ទៅនឹងព្រះសង្ឃអង្គនេះតែម្តង ទើបបានខ្ញុំសុំសួរសំណួរបែបនេះ លោកប្រធាន។

[០៩:១៩:០៨]

**កញ្ញា អង់តា ហ៊្គីសសេះ**

សូមអរគុណលោកប្រធាន ជម្រាបសួរភាគីទាំងអស់។

ខ្ញុំសូម ខាងមេធាវីការពារក្តី ខៀវ សំផន សុំគាំទ្រទៅលើអ្វីដែលបានលើកឡើងដោយខាងមេធាវី នួន ជា។ យើងមានបញ្ហាពាក់ព័ន្ធទៅនឹងការត្រៀមរៀបចំខ្លួននៅខាងក្រុមរបស់យើង។ យើងយល់ច្បាស់នៅពេលដែលលោក លីសាក់ និយាយកាលពីលើកមុននោះថា មានចំនួនតិចទេ ក៏ប៉ុន្តែចំនួនចេះតែកើនឡើងជាលំដាប់ ជារៀងរាល់ថ្ងៃ។ ដូច្នេះ យើងអត់អាចប្រមើលមើលបានថា តើមានចំនួនប៉ុន្មានឲ្យពិតប្រាកដនូវ<កំណត់ហេតុនៃការស្លាប់>ចម្លើយដែលដាក់នុ៎ងទេ។ អ៊ីចឹង ខ្ញុំគិតថានេះជាចំណុចមួយដែលយើងត្រូវទទួលការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាក៏គាត់ត្រូវតែដឹងថា តើគាត់ស្នើសុំចំនួនប៉ុន្មានឲ្យពិតប្រាកដនោះ? ដើម្បីផ្ញើជូនមកឲ្យភាគីទាំងអស់នោះ ចំណុចទី១នេះ។ ចំណុចទី២ យើងៗអត់មានការយល់ឃើញទៅលើសំណុំរឿងដូចគ្នាទេ ហើយក៏ខ្ញុំមិនគិតថាវាមានភាពពាក់ព័ន្ធដូចគ្នាដែរ។ <ដូច្នេះ ប្រហែលជាខាងសហព្រះរាជអាជ្ញា ពួកគាត់យល់ឃើញថាកំណត់ហេតុនៃការស្លាប់ចម្លើយមួយចំនួនពុំមានប្រយោជន៍អ្វីក្នុងការឲ្យសាក្សីមកបង្ហាញខ្លួននោះទេ។> ខាងមេធាវីការពារក្តីយើង<អាចយល់ឃើញខុសពីនេះ>។ ដូច្នេះ ខណៈដែលយើងមិនទាន់មានកំណត់ហេតុ<នៃការស្លាប់ចម្លើយ>ទាំងអស់នោះនៅក្នុងដៃ ហើយយើងមិនទាន់បានអានឯកសារទាំងនោះ យើងមិនទាន់តទល់ជាមួយនឹងភស្តុតាងដែលយើងនឹងពិភាក្សានោះ ខ្ញុំដូចថាខ្ញុំពិបាកនឹងផ្តល់យោបល់ណាស់។ ដូច្នេះខ្ញុំគិតថា នេះជាបញ្ហាមួយ<ខាងក្រុមមេធាវីការពារក្តីក្នុងការ>ត្រៀមរៀបចំខ្លួន ដើម្បីឲ្យមានដំណើរសវនាការ<សួរដេញដោលប្រព្រឹត្ត>ទៅ<បាន>ល្អ។ <ខ្ញុំដឹងថា ភាគីផ្សេងទៀតនៅក្នុងសាលសវនាការនេះ បានលើកឡើងជាញឹកញាប់អំពីគំនិតនៃការធ្វើសវនាការសួរដេញដោលនេះ។> ដូច្នេះ យើងស្នើសុំឲ្យអង្គជំនុំជម្រះធ្វើយ៉ាងម៉េចឲ្យមានការបំភ្លឺឲ្យបានច្បាស់អំពីចំនួននៃឯកសារដែលនឹងត្រូវផ្ញើជូន <ជារួមតាមសំណើរបស់សហចៅក្រមស៊ើបអង្កេត>។ ធ្វើយ៉ាងម៉េច ដើម្បីឲ្យយើងអាចរៀបចំខ្លួនឲ្យបានល្អដើម្បីការពារកូនក្តីរបស់យើងឲ្យមានប្រសិទ្ធភាព លោកប្រធាន។

[០៩:២១:០៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ជាបឋម ខ្ញុំសូមសោកស្ដាយណាស់ ពីព្រោះថាយើងមានពេលតិចណាស់ សម្រាប់សួរសាក្សី ហើយឥឡូវយើងឃើញថាម៉ោង<ប្រាំបួន និងម្ភៃនាទីហើយ>។ ដូច្នេះវាមិនសមរម្យទេដែលមកនិយាយអំពីតាក់ទិក និយាយពីយុត្តិសាស្ត្រអីៗបែបនេះនោះ។ សហព្រះរាជអាជ្ញាមានតួនាទី ឬក៏មានករណីយកិច្ចក្នុងការផ្ដល់ជូនភាគីនូវកំណត់ហេតុស្ដាប់ចម្លើយ ដែលអាចមានទំនាក់ទំនងទៅនឹងសំណុំរឿង០០២<> ពីព្រោះថាឯកសារទាំងអស់នោះអាចមានព័ត៌មានដោះបន្ទុក ហើយក៏វាមាន<ព័ត៌មានដែលពាក់ព័ន្ធទៅនឹងប្រធានបទ>ដែលត្រូវពិភាក្សា<នៅចំពោះមុខអង្គជំនុំជម្រះ>នៅក្នុង<ដំណើរការនីតិវិធី>សំណុំរឿង០០២/០២។ យើងមិនដឹងច្បាស់អំពីនីតិវិធីទាំងមូលនោះទេ ក៏ប៉ុន្តែយើងដឹងថាអ្វីវាត្រូវដំណើរការទៅមុខហើយ។ យើងទទួលបានកំណត់ហេតុស្ដាប់ចម្លើយជាបន្តបន្ទាប់ ហើយនិងមានការបកប្រែជាបន្តបន្ទាប់ ជាលំដាប់។ អ៊ីចឹងយើងពិបាកក្នុងការផ្ដល់តួលេខពិតប្រាកដថាស្ថានការថាឥឡូវប៉ុន្មានអ៊ីចឹងណាស់ ព្រោះវាមានដំណើរការបន្តទៅមុខរហូត។ ដូច្នេះ យើងៗបានស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ដើម្បី<ដាក់បង្ហាញ>កំណត់ហេតុ<នៃការស្ដាប់ចម្លើយទាំងអស់នេះ>។ ដូច្នេះ យើងមិនអាចត្រូវធ្វើយ៉ាងម៉េចទៅមុខលឿនឲ្យបានតាមអ្វីដែលមេធាវីការពារក្ដីចង់បាននោះទេ។ នេះជាអ្វីដែលយើងចង់បំភ្លឺជូនអង្គជំនុំជម្រះ ក៏ប៉ុន្តែ<>ខ្ញុំសូមបញ្ជាក់<ដល់ភាគីទាំងអស់>ថា នេះគឺជាដំណើរការដែលកំពុងតែតទៅមុខរហូត វាមិនមែនជាកលល្បិចអីទេ។ យើងត្រូវមានការអនុញ្ញាតដើម្បី<ដាក់បង្ហាញ>កំណត់ហេតុ<នៃការស្ដាប់ចម្លើយ>ទាំងអស់ហ្នឹង ហើយធ្វើយ៉ាងម៉េចឲ្យបានឆាប់រហ័ស <និងប្រឹងអស់ពីលទ្ធភាពរបស់យើង។> នេះជាអ្វីដែលខ្ញុំអាចត្រឹមតែនិយាយបាន នៅត្រឹមដំណាក់កាលនេះ លោកប្រធាន។

[០៩:២៣:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំមានការកត់សម្គាល់ខ្លីមួយ។ យើងស្ថិតនៅក្នុងជំហរដូចគ្នា <ជាមួយ>នឹងមេធាវីការពារក្ដី <ពាក់ព័ន្ធនឹងឯកសារទាំងអស់នេះ>។ យើង<មិនអាច>ចូលទៅក្នុង

សំណុំរឿង០០៤<បាន>ទេ អ៊ីចឹងយើងអត់អាចប្រមើលមើលមុនបានអំពីឯកសារដែលដាក់ជូនទេ។ អ៊ីចឹងយើង<មើលឃើញថា យើងក៏>មានស្ថានភាពដូចគ្នា<នឹងខាងមេធាវីការពារក្តីដែរ>។ ដូច្នេះដើម្បីលាតត្រដាងការពិតនោះ យើងត្រូវតែមានដាក់ឯកសារទាំងអស់ហ្នឹងចូលទៅក្នុងសំណុំរឿង ហើយយើងក៏ត្រូវរៀបចំខ្លួនដើម្បីឱ្យយើងអាចប្រើប្រាស់ឯកសារនោះបានទាន់ពេលវេលា។ ហើយយើងសូមជំទាស់នូវការផ្អាក<>សវនាការ ដើម្បីឱ្យភាគី អានឯកសារ<ទាំងអស់>នោះ អ៊ីចឹងយើងមិនបាច់ធ្វើអ៊ីចឹងទេ។ យើង<គិតថារឿងដែលសំខាន់នោះ គឺ>ដំណើរការសវនាការយើងតទៅទៀតទៅ។ <ហើយវាក៏សំខាន់ផងដែរ សម្រាប់ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាខាងមេធាវីការពារក្តីក្នុងការសម្របខ្លួនជាមួយស្ថានភាពបែបនេះ។> ខ្ញុំដឹងហើយថាវាពិបាក ក៏ប៉ុន្តែ<វាចាំបាច់ណាស់ដែលពួកគាត់សម្របខ្លួនជាមួយដំណើរការបន្តដាក់បង្ហាញឯកសារទាំងអស់នេះ ដើម្បីឱ្យ>ដំណើរការ<នីតិវិធីទាំងមូល>ទៅមុខទៀត <>។

[០៩:២៤:៣៤]

**លោក វិចទ័រ កូប៉េ៖**

លោកប្រធានសូមឆ្លើយតបសង្ខេបទេ ទាក់ទងទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញា។ ខ្ញុំពេញចិត្តទាំងស្រុងដែលសហចៅក្រមស៊ើបអង្កេត ឬក៏មន្ត្រីច្បាប់ធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវពិនិត្យឡើងវិញនូវ<កំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះ,> ឯកសារទាំងអស់នេះ។ ប៉ុន្តែច្បាស់ណាស់ថា សហព្រះរាជអាជ្ញាដឹងហើយថាខ្លួនបានស្នើសុំឯកសារចំនួនប៉ុន្មាន<>ដើម្បីពិនិត្យមើលឡើងវិញ<។ វាគឺជាដំណើរការមួយនៃការពិនិត្យឡើងវិញ ប៉ុន្តែវាក៏មានសំណើមួយផងដែរ។ ថាតើដំណឹងចចាមអារ៉ាមនោះជាការពិតដែរឬទេ ដែលថា>មានចម្លើយសាក្សីដល់ទៅរាប់រយ<នឹងយកមកដាក់បញ្ចូល ឬក៏អត់ទេ? ប្រសិនបើមិនមែននោះទេ ថាតើចំនួនអ្វីដែល>យើងកំពុងនិយាយគ្នានេះ? ដូច្នេះខ្ញុំសង្ឃឹមថា ខាងសហព្រះរាជអាជ្ញានឹងមានចម្លើយជាក់លាក់ ឆ្លើយតបមកសំណួរជាក់លាក់នេះ។

[០៩:២៥:២២]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣០:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះជូនវេទិកាទៅចៅក្រម ហ្វេនស៍ ដើម្បីសួរបញ្ជាក់បំភ្លឺលើបញ្ហានេះ ឱ្យបាន

ច្បាស់លាស់។ សូមអញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សំណួរ>ទី១ <ទៅកាន់លោកមេធាវី> ប្រហែលជាបញ្ហានៃការបកប្រែ។ លោកលើកឡើងអំពី ERN ដែលយោងទៅលើ<សំណួរពីមុនរបស់លោក នៅក្នុងតុលាការនេះ តើ>ត្រឹមត្រូវទេ?

មេធាវីការពារក្តីងក់ក្បាល ថាត្រឹមត្រូវហើយ។

សំណួរបន្ទាប់គឺសួរទៅខាងសហព្រះរាជអាជ្ញា ដោយយោងមកលើ<តែ>សាក្សីអង្គនេះ គឺឯកសារ<ដែលលោកបានដឹង ហើយ>គឺថាជិតនឹងបង្ហាញជាសាធារណៈហើយ តើវាមានផលប៉ះពាល់អីដល់សាក្សីអង្គនេះដែរឬទេ តំណាងសហព្រះរាជអាជ្ញា?

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ចំពោះខ្ញុំផ្ទាល់ ខ្ញុំគិតថាអត់ទេ។ លោកស្រីចៅក្រមគឺថា មិនមានផលប៉ះពាល់អីទេទៅលើសក្ខីកម្មរបស់សាក្សីអង្គនេះនោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ឥឡូវនេះ សំណួរពាក់ព័ន្ធទៅនឹងស្ថានភាពទូទៅ ប៉ុន្តែបញ្ហានេះ ក៏វាមិនមែនជារឿងធម្មតា វាអាចបង្កជាបញ្ហា។ ដូច្នេះ សំណួរដំបូងរបស់យើងខ្ញុំ <គឺថាខ្ញុំមិនច្បាស់ថា តើលោកបានឆ្លើយនឹងសំណួរនេះហើយឬនៅទេ។> តើលោកអាចវាយតម្លៃ ថាតើឯកសារចំនួនប៉ុន្មានដែលនឹងយកមកដាក់ចូលក្នុងសំណុំរឿង?

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

<>លោកស្រីចៅក្រម ខ្ញុំអត់មានតួលេខទេ។ <ប្រសិនបើខ្ញុំទទួលបាន>អ៊ីម៉ែល <ខ្ញុំអាចរៀបចំផ្តល់នូវចំនួនតួលេខជាក់លាក់។ ខ្ញុំមិនដឹងតួលេខទេ>។ ប៉ុន្តែខ្ញុំគិតថា ការិយាល័យរបស់យើងនឹងផ្ញើជូនទៅឲ្យភាគី ហើយនិងលោក លោកស្រីចៅក្រមនៅថ្ងៃនេះ តាមអ៊ីម៉ែល។ ខ្ញុំគិតថា មានកំណត់ហេតុ<នៃការស្តាប់ចម្លើយ>មួយចំនួនពាក់ព័ន្ធនឹងការដ្ឋាន គឺពាក់ព័ន្ធនឹងផ្នែកបន្ទាប់ទៀត នៃសវនាការយើងនេះ។ ហើយយើងកំពុងតែពិនិត្យមើលឡើងវិញ ខាងចៅក្រមស៊ើបអង្កេតកំពុងតែពិនិត្យមើលឡើងវិញ ខ្ញុំគិតថាគឺថាឯកសាររាប់សិប គឺប្រហែលជាត្រឹម៦០អីទេនោះ ប៉ុន្តែខ្ញុំប្រហែលជាមិនអាចផ្តល់តួលេខច្បាស់លាស់ទេ កុំឲ្យមានការភ័ន្តច្រឡំ។

[០៩:៣៣:៣៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំដឹងថា ការស៊ើបអង្កេតនៅក្នុងរឿងក្ដីនោះ កំពុងតែបន្តធ្វើនៅឡើយទេ។ តាមដែលលោកដឹង តើ<កិច្ចសម្ភាសន៍ដែលធ្វើនៅ>ក្នុងពេលនេះ ឬក៏ខែបន្តបន្ទាប់ វាប៉ះពាល់ទៅដល់សំណុំរឿង០០២ដែរទេ? ហើយមកដល់ពេលនេះ ខ្ញុំសូមសួរថា តើឯកសារចំនួនប៉ុន្មានវាប៉ះពាល់ដល់សំណុំរឿងនេះ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំគិតថា នេះជាការសម្ងាត់នៃការស៊ើបអង្កេត យើងអត់អាចទទួលព័ត៌មានបានទេ ពីព្រោះមានការការពារពីចៅក្រមស៊ើបអង្កេត។ ពួកគាត់មិនផ្ដល់ជូនព័ត៌មានបែបនេះមកឲ្យយើងទេ។ អ្វីដែលខ្ញុំដឹងនោះ គឺប្រហែលជាមានកំណត់ហេតុ<នៃការស្ដាប់ចម្លើយ>មួយចំនួនដែលមានភាពពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ដូច្នេះ ឯកសារទាំងអស់នោះ នឹងប្រហែលជានឹងមកដល់នៅប៉ុន្មានសប្ដាហ៍ ឬប៉ុន្មានខែខាងមុខនេះ។ ដូចជាក្រៅពីនេះ ខ្ញុំដូចជាមិនអាចផ្ដល់ព័ត៌មានអ្វីជូនលោកស្រីចៅក្រមបានទេ។ ខ្ញុំគិតថា សំណួរនេះ មានតែចៅក្រមស៊ើបអង្កេតទេ ដែលគាត់អាចឆ្លើយជូនលោកស្រីចៅក្រមបាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូចដែលខ្ញុំបានលើកហើយ បញ្ហានេះគឺជាបញ្ហាមួយមិនល្អ វាអាចជះឥទ្ធិពល ឬក៏មានបញ្ហា។ ដូច្នេះអង្គជំនុំជម្រះពិចារណា ថាតើត្រូវដោះស្រាយជាមួយបញ្ហាដោយរបៀបណា? ដោយសារសាក្សីអង្គនេះ គឺថាយើងទទួលបានព័ត៌មានមកខាងពីខាងតំណាងសហព្រះរាជអាជ្ញាវិញថា គឺថាយើងអាចដំណើរការទៅមុខបាន។

[០៩:៣៥:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ សហព្រះរាជអាជ្ញា!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធានអង្គជំនុំជម្រះ។ សូមគោរពលោក លោកស្រីដែលមានវត្តមាននៅទីនេះ។ សូមថ្វាយបង្គំព្រះអង្គ ឯម គឿង។ ខ្ញុំព្រះករុណា ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិនៃ អ.វ.ត.ក។

**ស៖** ខ្ញុំព្រះករុណាមានសំណួរមួយចំនួន ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើពុទ្ធសាសនិកជនក្នុងអំឡុងពេលចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩។ កន្លងមកព្រះអង្គធ្លាប់មានថេរៈដីកានៅចំពោះមុខសហចៅក្រមស៊ើបសួរនៅក្នុងឯកសារ E3/5133 ត្រង់ERN ខ្មែរ 00165260, ERN អង់គ្លេស 00223200 ERN ជាភាសាបារាំង 00702335 ថា ព្រះអង្គ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ត្រូវបានជម្លៀសចេញពីភ្នំពេញ និមន្តកាត់តាមផ្លូវជាតិលេខ៣ រួចទៅដល់វត្តអង្គរកា។ ខ្ញុំព្រះករុណាចង់ទូលព្រះអង្គថា តើវត្តអង្គរកា កាលសម័យនោះស្ថិតនៅក្នុងឃុំណា ស្រុកណា តំបន់ណា?

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** វត្តអង្គរកានៅឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ។ ឃុំជាងទង វត្តអង្គរកា ស្រុកត្រាំកក់ ខេត្តតាកែវ។

**ស៖** តើព្រះអង្គប្រើប្រាស់រយៈពេលប៉ុន្មានពីភ្នំពេញទៅដល់វត្តអង្គរកានាពេលនោះ?

**ឆ៖** ចម្រើនពរ ពីភ្នំពេញមកអង្គរកាហ្នឹងប្រើវេលាយូរណាស់។ មិនចាំទេ ប៉ុន្តែយូរ ប្រហែលជា១ខែ ឬ២ខែបានដល់ ព្រោះដើររហូតតាំងពីភ្នំពេញមក។

**ស៖** តើក្នុងអំឡុងពេលដែលព្រះអង្គនិមន្តពីភ្នំពេញទៅវត្តអង្គរកានោះ តើព្រះអង្គបានទទួលរងនូវការប្រមាថមើលងាយអំពីសំណាក់កម្មាភិបាលខ្មែរក្រហម ឬក៏ទាហានយ៉ាងដូចម្តេចដែរ?

[០៩:៣៨:០៨]

**ឆ៖** ចម្រើនពរ មកតាមផ្លូវហ្នឹងអត់មាន១អីទេ។ អត់មានអីទេ មកគ្នាច្រើន ប្រជាជនចេញពីភ្នំពេញមកច្រើន។

**ស៖** ចុះក្រៅពីនេះ តើព្រះអង្គបានឃើញការប្រមាថមើលងាយទៅលើព្រះសង្ឃពុទ្ធសាសនាផ្សេងទៀតដែរទេ?

**ឆ៖** បើពេលចេញពីភ្នំពេញមកហ្នឹងមិនបានឃើញអីទេ ព្រោះព្រះសង្ឃមកច្រើន ប្រជាជនមកច្រើន ពរមកច្រើន។ បានគ្រាន់តែឃើញ មានអ្នកខ្លះមកមុន ហើយខ្លះមកក្រោយ។ ប៉ុន្តែមកតាមផ្លូវហ្នឹងលំបាក ជីវភាព ការរស់នៅ ទម្រាំមកដល់ទីគោលដៅហ្នឹងវាច្រើន យូរណាស់។

**ស៖** ក្នុងការដែលព្រះអង្គនិមន្តទៅហ្នឹង ទិសដៅនេះ ព្រះអង្គអ្នកជ្រើសរើសខ្លួនឯង ឬក៏មានការកំណត់ដោយអ្នកណា?

**ឆ៖** ចម្រើនពរ ពេល១៧ មេសា អាត្មានៅវត្តសំពៅមាស ផ្សារអូរឫស្សី រាជធានីភ្នំពេញ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ម៉ោងដប់យប់បានកងទ័ពរំដោះហ្នឹង ឲ្យចេញៗពីភ្នំពេញ។ ហើយសួរថា "មិត្តឲ្យទៅណាវិញ?" ថា "ស្រុកឯណាទៅឯហ្នឹង"។ សួរអ៊ីចឹង សួរពួកកងទ័ពតូចៗ មិនធំទេ កាំភ្លើងអូសដី ពរ កាំភ្លើងអូសដីតើតូចៗហ្នឹង។ សួរថា "មិត្តឲ្យទៅឯណាវិញ" ថាឲ្យ "ស្រុកឯណាទៅអីហ្នឹង"។ ហើយអាត្មានៅតាកែវកំពត អាត្មាមកផ្លូវជាតិលេខ៣មក ដើរតាំងពីម៉ោងដប់មកទល់មកភ្លឺពេទ្យលោកសង្ឃ ចេញពីសំពៅមាសមក។

[០៩:៤០:៤៦]

**ស៖** ត្រង់នេះចំណុចគោលដៅចុងក្រោយ ដែលខ្ញុំព្រះករុណាលើកឡើងពីដំបូងហ្នឹង ចង់មានន័យថា វត្តអង្គរកា។ តើព្រះអង្គមានជម្រើសទៅនិមន្តទៅវត្តអង្គរការដោយខ្លួនឯង ដោយអង្គឯង ឬក៏មានអ្នកណាបង្ខំ?

**ឆ៖** ចម្រើនពរ ព្រោះកន្លែងអាត្មារស់នៅកន្លែងហ្នឹង ទៅកន្លែងហ្នឹងពរ អត់មានក្រៅពីហ្នឹងគោលដៅទៅហ្នឹងតែម្ដង ព្រោះនៅហ្នឹង។

**ស៖** តើព្រះអង្គមានជម្រើសទេកាលណោះ អាចមានជម្រើសផ្សេងក្រៅពីវត្តអង្គរការនេះឬទេ?

**ឆ៖** ស្រុកកំណើត ធ្លាប់រស់នៅ ប៉ុណ្ណឹងទេពរ។

**ស៖** អ៊ីចឹងនៅពេលដែលព្រះអង្គនិមន្តទៅដល់វត្តអង្គរការនោះ តើព្រះអង្គបានពិនិត្យឃើញថាមានព្រះ -- មានព្រះសង្ឃផ្សេងទៀត ឬក៏គ្រហស្ថដែរឬទេនៅក្នុងវត្តនោះ?

**ឆ៖** ចម្រើនពរ អាត្មាទៅដល់វត្តអង្គរការហ្នឹង ឧបជ្ឈាអាត្មានៅ ឧបជ្ឈាក៏នៅ ហើយមានលោកព្រះអង្គ លោកច្រើនពីតាកែវទៅក៏នៅហ្នឹងទាំងអស់។ ទៅនៅវត្តអង្គរកាទាំងអស់ ប្រមូលមូលនៅហ្នឹងពីតាកែវទៅ វត្តសីហរតនារាម។ ទៅនៅមូលអង្គរការជាមួយនឹងលោកគ្រូឧបជ្ឈាអាត្មាវត្តអង្គរកាហ្នឹង។

[០៩:៤២:៥៨]

**ស៖** ព្រះអង្គអាចដឹងថាមានចំនួនប៉ុន្មានអង្គទេកាលណោះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

ព្រះតេជព្រះគុណ កុំអាលទាន់ឆ្លើយតប! រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការសិន អត់ទាន់ភ្លើងក្រហមផង។ ឆ្លើយម្ដងទៀត ចាំដល់ភ្លើងក្រហមបាទ។

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** ពរ ពេលនោះមិនបានរាប់ចំនួនព្រះសង្ឃទេ អត់បានរាប់អីផង។ ប៉ុន្តែឲ្យលោកមកគង់នៅហ្នឹង ត្រៀមលក្ខណៈឲ្យទៅលើកប្រឡាយនៅអីត្រពាំងអណ្ដើក លោកឲ្យទៅហ្នឹងទាំងអស់លើកប្រឡាយនៅកន្លែងហ្នឹង។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** តើព្រះអង្គ -- មុនៗនេះព្រះអង្គបានមានថេរៈដីកាថា និមន្តមកពីកន្លែងផ្សេងៗ។ តើព្រះអង្គអាចៗដឹងទេថា និមន្តមកពីកន្លែងណាខ្លះ ព្រះសង្ឃផ្សេងៗទៀតដែលព្រះអង្គនិមន្ត -- ពេលដែលព្រះអង្គនិមន្តទៅដល់ឃើញនៅទីនោះស្រាប់នោះ?

[០៩:៤៤:៣១]

**ឆ៖** ចម្រើនពរ ព្រះសង្ឃដែលមកនៅអង្គរការហ្នឹង ភាគច្រើនមកពីតាកែវ ពីក្រុងតាកែវៗ។ គេឲ្យមកស្នាក់នៅវត្តហ្នឹងទាំងអស់អង្គ ត្រៀមដើម្បីទៅធ្វើកិច្ចការផ្សេងៗ។

**ស៖** នៅពេលដែលព្រះអង្គនិមន្តទៅដល់វត្តអង្គរកាភ្លាម តើគេឲ្យព្រះអង្គធ្វើអ្វីខ្លះដែរ?

**ឆ៖** ចម្រើនពរ អាត្មាដល់អង្គរកាមិនទាន់ធ្វើអ្វីទេពរ ទំនេរទេ។ លោកគ្រូឧបជ្ឈាអាត្មា លោកប្រាប់ថាលោក គេមិនអាចឲ្យលោកនៅបាទទេ ព្រោះករុណាចាស់ហើយក៏គេឲ្យករុណាសឹកដែរ ប៉ុន្តែករុណាមិនទាន់ដល់ពេលវេលាសឹក។ លោកនៅព្រៃត្រូវសឹកមុនករុណាអស់ទៅ ព្រោះអង្គការមិនឲ្យនៅទេ។ ប៉ុន្តែដំបូងមិនទាន់ធ្វើអីទេអត់ទាន់ស្អីទេ គ្រាន់ជុំគ្នានៅហ្នឹងមិនទាន់ធ្វើអីទេ។ គ្រូឧបជ្ឈាអាត្មាប្រាប់អ៊ីចឹង ព្រោះលោកនៅហ្នឹងលោកមូលដ្ឋាន។

**ស៖** មានថិរវេលាប៉ុន្មានដែរព្រះអង្គ ចន្លោះពេលដែលនៅទំនេរហ្នឹង?

**ឆ៖** ចម្រើនពរ មិនយូរប៉ុន្មានទេ ព្រោះអង្គការមិនឲ្យៗទំនេរយូរទេ កាលនោះ។ ព្រោះអាហារហូបចុកខ្លួនឯង អីខ្លួនឯងទាំងអស់ អត់មានអ្នកឧបត្ថម្ភទេ អស់ហើយអស់អ្នកមានឧបត្ថម្ភហើយ។ ដាំស្លខ្លួនឯង អីធ្វើខ្លួនឯងទាំងអស់ អត់មានអ្នកឧបត្ថម្ភទៀតទេ អស់ហើយ។

**ស៖** នៅៗចំពោះមុខចៅក្រមស៊ើបសួរ ព្រះអង្គធ្លាប់មានព្រះថេរៈដីកានៅក្នុងឯកសារE3/5133 ERN ជាភាសាខ្មែរនៅទំព័រទី៤គឺ 00165261, ជាភាសាអង់គ្លេសត្រង់ទំព័រទី៤ ERN 00223200, ជាភាសាបារាំងនៅទំព័រទី៤ និងទី៥ ERN 00702335 ដល់ 36។ ព្រះអង្គមានថេរៈដីកាថា បន្ទាប់ -- “គេឲ្យព្រះសង្ឃទាំងនោះទៅដាំដំឡូងទាំងស្បង់ចីពរ។ ពេលនោះ គេប្រាប់ថាអស់មានអ្នកណាបម្រើអ្នក

ទៀតហើយ ត្រូវធ្វើពលកម្មទាំងអស់គ្នា"។ អ៊ីចឹង តាមរយៈថេរៈដីកាព្រះអង្គពីមុន មុននេះ ហើយនិង -- ខ្ញុំករុណាកត់សម្គាល់ឃើញថា មានៗភាពខុសគ្នាបន្តិច។ អ៊ីចឹងព្រះអង្គកំណត់ថា ថេរៈដីកាមួយណាដែលត្រឹមត្រូវ?

**ឆ៖** បាទខុសគ្នាម៉េចបាទ? ចម្រើនពរ ខុសគ្នាម៉េច? មានប្រសាសន៍បន្តិចមើល៍?

**ស៖** គឺដែលខុសគ្នាហ្នឹងត្រង់ថា ព្រះអង្គមានថេរៈដីកានៅពេលនេះថា ព្រះអង្គក្រោយពេលនិមន្តទៅដល់វត្តអង្គរកា ព្រះអង្គមានពេលទំនេរអត់បានធ្វើអីទេ។ ប៉ុន្តែនៅក្នុងថេរៈដីកាកាលពីនៅចំពោះចៅក្រមស៊ើបសួរ ព្រះអង្គមានថេរៈដីកាថា ព្រះអង្គត្រូវបានគេបង្ខំឲ្យធ្វើ -- ព្រះសង្ឃទាំងអស់ត្រូវបានគេបង្ខំឲ្យធ្វើការទាំងស្បង់ចីពរ។ អ៊ីចឹង ករុណាចង់ទូលព្រះអង្គថាតើការពិតនុង់ ព្រះអង្គត្រូវបានគេបង្ខំឲ្យធ្វើការទាំងស្បង់ចីពរ ឬក៏ឲ្យទំនេរៗសិន នៅពេលៗដែលនិមន្តទៅដល់វត្តអង្គរកា ហើយបានឲ្យធ្វើការ ក្រោយពេលសឹកបានឲ្យធ្វើការ?

[០៩:៤៩:៥៥]

**ឆ៖** ចម្រើនពរ អ៊ីចេះ អាត្មាជម្រាបអ៊ីចេះ ទៅដល់ដំបូង មិនទាន់មានការធ្វើទេ បន្តិចបានអង្គការគេមក មកប្រមូលថា ឥឡូវមានការងារធ្វើហើយ។ បាននាំគ្នាទៅលើកទំនប់នៅត្រពាំងអណ្តើកទាំងអស់អង្គ អត់នៅទេ អត់ទំនេរទេពរ អត់មានទំនេរទេ។ នៅពេលនោះអត់មានអង្គណាមួយទំនេរបានទេ។ មុនដំបូងទំនេរអ៊ីចឹងមែន ប៉ុន្តែដល់ហើយអត់ទំនេរទេពរ។ អង្គការគេដឹងថា លោកមានច្រើនហើយ បានមកប្រមូលទៅហ្នឹងទាំងស្បង់ចីពរ ទៅទាំងអស់អង្គ។

**ស៖** ទាំងនៅក្នុងផ្នួសព្រះអង្គ?

**ឆ៖** ពរ។

**ស៖** តើការងារដែលដូចព្រះអង្គលើកឡើងនេះជាការងារជីកប្រឡាយ ជាការងារអីហ្នឹង អាហ្នឹងជាការងារដែលព្រះសង្ឃទូទៅនៅសម័យមុនគេត្រូវតែធ្វើអ៊ីចឹង ឬយ៉ាងណា?

**ឆ៖** ពរ ស្តាប់មិនទាន់បានម្តងទៀតមើល។ ចង់ថាម៉េច ចង់សួរថាម៉េច?

**ស៖** ករុណាចង់ទូលសួរ -- ចង់ពិតទូលថា ការងារដែលព្រះអង្គបានបំពេញដូចជាជីកប្រឡាយនៅត្រពាំងអណ្តើកអីហ្នឹងដែលព្រះអង្គបានលើកឡើងពីខាងដើមហ្នឹង ជាការងារដែលព្រះសង្ឃត្រូវបំពេញជាធម្មតា ជាការងារប្រចាំថ្ងៃនៅសម័យមុន មែនឬ?

[០៩:៥២:៥៦]

**ឆ៖** ចម្រើនពរ ពីមុនមកមិនមែនព្រះសង្ឃអត់មានទេ ពរ។ ទើបតែរំដោះហើយទេ ដែលប្រើព្រះសង្ឃឲ្យអីចឹងបង រំដោះហើយទេបង ពីមុនអត់មានពីណាប្រើទេ។ រំដោះហើយបានប្រើព្រះសង្ឃឲ្យធ្វើអីចឹង ធ្វើទាំងផ្នួស ធ្វើទាំងបួស រំដោះហើយបង ១៧មេសារួចបានប្រើឲ្យធ្វើអីចឹង។ អង្គការចាត់តាំងឲ្យធ្វើ។

**ស៖** តើពេលនោះព្រះអង្គអាចប្រកែកនឹងការដាក់បញ្ជាហ្នឹងបានទេ?

**ឆ៖** អត់មានអ្នកណាហ៊ានប្រកែកទេ អត់ទេ អត់ហ៊ានពរ។ អង្គការចាត់តាំងហើយ អត់មានប្រកែកទេពរ។ ត្រូវតែគោរពការងារតែម្តង។

**ស៖** ចុះចំពោះលក្ខខណ្ឌការងារវិញ តើគេបង្គាប់ឲ្យព្រះអង្គធ្វើការហ្នឹងចាប់ពីម៉ោងប៉ុន្មានដល់ប៉ុន្មាន? ហើយចង្ហាន់អីយ៉ាងដូចម្តេចដែរ?

**ឆ៖** ពរ រឿងការងារហ្នឹង ឧបាសកគេយ៉ាងម៉េច លោកសង្ឃក៏អីចឹងដូចគ្នាបង។ ព្រឹកម៉ោងប្រាំមួយ ម៉ោងដប់មួយ ល្ងាចម៉ោងមួយ រហូតដល់ម៉ោងប្រាំដូចគ្នាអីចឹងពរ។

[០៩:៥៣:៤៥]

**ស៖** តើព្រះអង្គធ្លាប់បានឃើញព្រះសង្ឃអង្គណាផ្សេង ដែលប្រកែកនឹងបទបញ្ជារបស់កម្មាភិបាលខ្មែរក្រហម ដែលបង្គាប់ឲ្យធ្វើការងារហ្នឹងដែរទេ?

**ឆ៖** ចម្រើនពរ នៅកន្លែងអាត្មាហ្នឹងអត់មានអង្គណាហ៊ានប្រកែកទេពរ អត់ទេ។ កន្លែងអាត្មាប្រកបការងារ នៅកន្លែងអាត្មាធ្វើពលកម្មហ្នឹងអត់មានអង្គណាហ៊ានប្រកែកទេ។

**ស៖** នៅក្នុងអំឡុងពេលដែលព្រះអង្គគង់នៅវត្តអង្គរកាហ្នឹង តើមានការគោរពប្រតិបត្តិជាព្រះសង្ឃពុទ្ធសាសនាពីសំណាក់កម្មាភិបាល ឬក៏ទាហានខ្មែរក្រហមនាសម័យនោះដែរឬទេ?

**ឆ៖** ចម្រើនពរ អីចេះថា ព្រះសង្ឃពេលនោះអស់មានវត្តហើយ អស់ហើយ។ នៅតាមការដ្ឋានទាំងអស់ពរ។ អត់មានទេ ក្នុងវត្តអត់មានលោកសង្ឃទេ មានតែតាមការដ្ឋានមាន ពរ ពលកម្ម។

[០៩:៥៥:១៧]

**ស៖** អីចឹង មុននេះបន្តិចព្រះអង្គក៏បានមានថេរៈដីកាដែរថា ភ្លាមនៅពេលដែលនិមន្តមកដល់ហ្នឹង ព្រះអង្គត្រូវបានគេបង្ខំឲ្យធ្វើ -- គេឲ្យនៅស្លៀកស្បង់នៅឡើយទេ។ ហើយករុណាចង់ ពិតទូលព្រះអង្គថា តើនៅពេលហ្នឹង បើអត់មានគេប្រណិប័តន៍អីចឹង តើអត់មានវត្តអីចឹង តើព្រះអង្គធ្លាប់បានសូត្រធម៌សុំសីលអីក្នុងនាមជាអ្នកបួសទេ?

**ឆ៖** ចម្រើនពរ អឺចេះ ភារកិច្ចរបស់អ្នកបួស ទោះបីគេបង្ខំយ៉ាងណាក៏ដោយ ក៏នៅតែមានគោលជំហរច្បាស់លាស់ចំពោះសាសនា សម័យនោះ ពរ។ មិនឲ្យគេឮទេ ក៏ប៉ុន្តែលាក់ការណ៍ខ្លួនឯងពេលស្ងាត់ៗ ពរ។

**ស៖** ចុះចំណែកទំនាក់ទំនងរវាងព្រះអង្គនៅក្នុងវត្តហ្នឹង តើព្រះអង្គមានសិទ្ធិទំនាក់ទំនងគ្នារវាងសង្ឃនិងសង្ឃ ឬក៏សង្ឃនិងគ្រហស្ថផ្សេងទៀតដែរទេ នៅពេលដែលព្រះអង្គគង់នៅវត្តអង្គរការនោះ?

[០៩:៥៧:០២]

**ឆ៖** បាទ ចម្រើនពរ អឺចេះ មានការទាក់ទងបានតែតាចាស់ៗទេ តាចាស់បាន។ ទំនាក់ទំនងសួរនាំគ្នាបាន ពីកន្លែងដែលរស់ ធ្លាប់តាៗគាត់នៅមុន ពួកលោកសង្ឃមកថ្មី ពរ។ គាត់អ្នកប្រាប់ហេតុផលពីរឿងកិច្ចការសព្វសារពើទាំងអស់ហ្នឹង ទាក់ទងបានតាៗ។ ក្មេងៗមិនបានទេ ក្មេងៗពលកម្មអស់ហើយ។

**ស៖** មានការហាមឃាត់ ឬមួយយ៉ាងម៉េចកាលនោះព្រះអង្គ?

**ប្រធានអង្គជំនុំ៖**

ស្ងួរម្ដងទៀត។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** កាលហ្នឹង មិនមានការទំនាក់ទំនងហ្នឹងដោយសារអត់មាន -- ដោយសារគេហាម ឬក៏ៗមានហេតុផលអីផ្សេង?

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** ចម្រើនពរ អឺចេះ ដំបូងបំផុតមិនទាន់ជាតឹងរ៉ឹងណាស់ណាទេ។ ដំបូងបំផុត ១៧ មេសាមកហើយ ប្រហែល១ខែ ២ខែហ្នឹងមិនទាន់ទៅណាទេ អាចនៅទំនាក់ទំនងបានខ្លះ ពរ។ នៅនឹងវត្តហ្នឹងអាចទំនាក់ទំនងជាមួយតាៗអី ចាស់ៗអីបាន សួរហេតុផលអាចដែលគាត់នៅមូលដ្ឋានហ្នឹង ដឹងរឿងច្រើន អាចធ្វើម៉េចនៅបាន ហ្នឹងហើយ។ គាត់បានប្រាប់ហើយគាត់ប្រាប់ថា "ព្រះអង្គអើយ មិនអាចនៅជាព្រះសង្ឃបានទៀតទេ អំណើះតទៅត្រូវ គេម៉េច យើងម៉េចហើយ តាមគេហើយ" ហ្នឹងគាត់ប្រាប់ហេតុផលឲ្យដឹងមុនដែរ តាៗហ្នឹងណា ពរ។

**ស៖** ចុះ ព្រះអង្គនិមន្តមកដល់ មកគង់នៅវត្តអង្គរកាហ្នឹងរយៈពេលប៉ុន្មានទើបគេបង្គាប់ឲ្យព្រះអង្គសឹកពីព្រះផ្នួស?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[០៩:៥៩:២១]

**ប្រធានអង្គជំនុំ៖**

ព្រះអង្គៗ បង្អង់បន្តិច! មិនទាន់ ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**ព្រះតេជព្រះគុណ ឯម ភឿង ៖**

**ឆ៖** ចម្រើនពរ ៧៥មក៧៦ ព្រះសង្ឃចេះតែសឹកបណ្ដើរៗ ពរ ៧៦បានអស់ អស់ទៅឧបាសក អស់ហើយ។ ព្រោះនៅមិនកើត អត់អ្នកឧបត្ថម្ភដដែល ហើយអង្គការគេឲ្យ គេប្រាប់ថា អត់មានអ្នកណាពាក់អាវធំអ៊ីចឹងទៀតទេ មានតែអាវតូចៗទេ ធ្វើការធ្វើងារនឹងគេ រកស៊ី។ ពេលវេលាខុសគ្នា គេនិយាយអ៊ីចឹងចប់ហើយ។

**សួរដោយលោក ស្រ៊ា រតនះ៖**

**ស៖** ចុះៗ ព្រះអង្គផ្ទាល់ៗ ព្រះអង្គហ្នឹងត្រូវបានគេឲ្យសឹកនៅឆ្នាំណា?

**ឆ៖** ៧៦ ពរ ៧៦។

**ស៖** តើនៅពេលៗដែលព្រះអង្គសឹកហ្នឹង គេមានរៀបចំកម្មវិធីអី ឬក៏ព្រះអង្គសឹកៗទៅតាមទំនៀមទម្លាប់ប្រពៃណីព្រះពុទ្ធសាសនាកន្លងមក?

**ឆ៖** ចម្រើនពរ ខណៈនោះមិនមានអ្នកណាចង់ទេ ពរ។ ក៏ប៉ុន្តែអង្គការ អាជ្ញា ពិធីមានចិត្តសាស្ត្រ គឺអបអរសាទរគេឲ្យអាវ ឲ្យខោ ទ្រនាប់ជើងហ្នឹងហើយ មានតែប៉ុណ្ណឹងទេ អត់មានស្ពឹទេ អត់មានស្បង់ចីពរទេ មានតែខោខ្មៅអាវខ្មៅ ទ្រនាប់ជើងខ្មៅទេ។ សឹកឯណាសឹកទៅ កុំឲ្យហួស៧៦។

[១០:០១:៤០]

**ស៖** គេមានធ្វើពិធីអីដែរ ព្រះអង្គកាលនោះ?

**ឆ៖** ទេ គ្មានពិធីអីទេ អត់មានទេពរ អត់មានពិធីអីទេ។ សឹកតៗគ្នាទៅ។ អង្គណាក្មេងសឹកមុនទៅ អង្គណាចាស់សឹកក្រោយទៅ សឹកតៗគ្នាទៅទល់តែនឹងចប់អស់ទៅ។

**ស៖** គេឲ្យព្រះអង្គសឹកហ្នឹង សឹកម្ដងមួយអង្គៗ ឬមួយក៏គេប្រជុំគ្នា ហើយគេ -- ដូចព្រះអង្គមានថេរៈដីកាពីខាងដើមអ៊ីចឹងថា គេឲ្យខោអាវមួយកំប្លេ និងស្បែកជើងមួយគូ។ អ៊ីចឹងអាហ្នឹងៗគេធ្វើៗក្នុងកម្មវិធី ករុណាចង់សំដៅលើកម្មវិធីហ្នឹងមានដូចជាកិច្ចប្រជុំ ឬក៏កម្មវិធីជួបជុំអី ឬយ៉ាងម៉េចព្រះអង្គ?

**ឆ៖** ចម្រើនពរ ពេលនោះ សមាជិកឃុំគេ សមាជិកឃុំទទួលបន្ទុក គេប្រជុំប្រាប់ថា "អង្គការ

រំដោះបានមកហើយអត់មានទំនេរទេ អត់មានអ្នកណាចិញ្ចឹមអ្នកណាទេ ខ្លួនទីពឹងខ្លួន។ អង្គការចាត់តាំងអាត្រង់ណាធ្វើអាហ្នឹង"។ បើអ៊ីចឹងអ្នកទំនេរអត់មានទៀតហើយ អស់មានហើយ មានតែអ្នកធ្វើការពលកម្ម ស្មើគ្នាទូទៅទាំងអស់។ អត់មានអ្នកណាទំនេរទេ ខុសពីមុនហើយ។ បើអ៊ីចឹងគេឲ្យ បានគេឲ្យៗអាវឲ្យខោ ទូនាប់ជើង។ ដាក់កម្មវិធីឲ្យថា យ៉ាងយូរ១ខែអីហ្នឹងត្រូវអស់ទៅ ប្រឡាយទំនប់។ ហ្នឹងអង្គការចាត់តាំងឲ្យធ្វើអ៊ីចឹងពរ អង្គការចាត់តាំងមកអាហ្នឹង។

[១០:០៣:៥២]

**ស៖** តើករុណាយល់ៗខុស ឬត្រូវ នៅពេលដែលព្រះអង្គមានថេរៈដីកាថា អ្នកទទួលបន្ទុកឃុំហ្នឹងប្រជុំប្រាប់ ហើយអ៊ីចឹងការដែលនៅក្នុងកិច្ចប្រជុំហ្នឹង គឺព្រះអង្គត្រូវបានគេបង្គាប់ឲ្យសឹកនៅពេលនោះតែម្តង។ តើករុណាយល់អ៊ីចឹងត្រូវទេព្រះអង្គ?

**ឆ៖** ចម្រើនពរ នេះជាប្រជុំដាក់ផែនការ ហើយបានចែកសម្ភារៈឲ្យ ថ្ងៃក្រោយបានចាកសិក្ខាបទ ពរ។

**ស៖** ដែលព្រះអង្គមានថេរៈដីកាអំពីថា អ្នកទទួលបន្ទុកឃុំហ្នឹង គាត់ប្រុស ឬស្រី?

**ឆ៖** ប្រុស មេឃុំប្រុស។

**ស៖** ពេលហ្នឹង គាត់មកណែនាំខ្លួនគាត់ថា គាត់ជានរណានៅក្នុងកិច្ចប្រជុំហ្នឹង?

**ឆ៖** ចម្រើនពរ គេឧទ្ទេសនាមគេជាសមាជិកឃុំ ទទួលបន្ទុកយុវជន ពរ។

**ស៖** ពេលហ្នឹង គាត់មកតែឯងទេ ឬមួយក៏គាត់មានគ្នាហែហមមក?

**ឆ៖** មានឈ្លប មកជាមួយឈ្លប។

**ស៖** តើព្រះអង្គធ្លាប់ស្គាល់គាត់ពីមុនមកទេ អ្នកដែលទទួលបន្ទុកឃុំហ្នឹង ដែលមកធ្វើជាអធិបតីនៃអង្គប្រជុំកាលណោះ?

[១០:០៦:០០]

**ឆ៖** ចម្រើនពរ ខ្លះស្គាល់ ខ្លះមិនស្គាល់ទេ ព្រោះក្មេងៗក្រោយ។

**ស៖** ចុះក្រៅអំពីកិច្ចប្រជុំដែលគេលើកៗឡើងអំពីការបង្គាប់ឲ្យព្រះសង្ឃពុទ្ធសាសនាសឹកទាំងអស់គ្នាហ្នឹង តើមានកិច្ចប្រជុំណាផ្សេងទៀតទេ? មានកិច្ចប្រជុំប្រចាំសប្តាហ៍ ប្រចាំខែ ឬក៏កិច្ចប្រជុំបន្ទាន់ណាផ្សេងទៀត ដែលត្រូវបាន -- ដែលព្រះអង្គបានចូលរួម?

**ឆ៖** ចម្រើនពរ ការងារជំនាន់នោះ គឺ១ខែប្រជុំម្តងៗ ពរ។ ពង្រឹងគោលជំហរយុវជន អ្នកសឹក

នោះបានទៅយុវជនទាំងអស់ យុវជនទាំងអស់តែម្តង។ អ៊ីចឹង ប្រធានប្រជុំគេហ្នឹង គេពង្រឹងគោលជំហរ ពរ។

**សៈ** តើនៅគ្រប់កិច្ចប្រជុំទាំងនុ៎ង មានការលើកឡើងដូចម្តេចដែរ ចំពោះព្រះសង្ឃពុទ្ធសាសនា? កិច្ចប្រជុំដែលករុណាលើកឡើងនៅពេលនេះ គឺកិច្ចប្រជុំនៅពេលដែលព្រះអង្គគង់នៅវត្តអង្គរកា។

**ផៈ** ចម្រើនពរ សួរម្តងមក ស្តាប់មិនទាន់បានផង ពរ។

**សៈ** ព្រះអង្គមានថេរៈដីកាថា មានការលើកឡើងអំពី -- មានកិច្ចប្រជុំដែលលើកឡើងអំពីការពង្រឹងគោលជំហរ។ ករុណាចង់ពិតទូលថា តើនៅកិច្ចប្រជុំនៅវត្តអង្គរកាហ្នឹង នៅពេលដែលព្រះអង្គគង់នៅវត្តអង្គរកាហ្នឹង មាន គេមានលើកឡើងអំពីព្រះសង្ឃពុទ្ធសាសនាដូចម្តេចខ្លះ?

[១០:០៨:២២]

**ផៈ** ចម្រើនពរ រឿងនេះអ៊ីចេះ សូមជម្រាប។ អង្គការ មានឃុំជាដើម កាលហ្នឹងគេប្រជុំថា "ពេលមុននិងពេលឥឡូវនេះ ផ្សេងពីគ្នាហើយ។ ពេលមុនម្ចាស់សក្តិភូមិ ចក្រពត្តិ ឥឡូវនេះអត់មានទៀតទេ អង្គការចាត់តាំង។ អត់មានអ្នកទំនេរ អត់មានអ្នកអីៗទេ អត់មានអ្នកណាបម្រើពីណាទេ គឺពលកម្មទាំងអស់គ្នា។ បញ្ចេញពលកម្មទាំងអស់គ្នា ហូបទាំងអស់គ្នា"។ ហ្នឹងគេប្រជុំអ៊ីចឹងពរ ពីមុនមានអ្នកទំនេរ ឥឡូវអត់មានឲ្យអ្នកទំនេរទៀតទេ អស់មានហើយ មានតែពលកម្មមាន។

**សៈ** តើក្នុងអំឡុងពេលនោះ តើព្រះអង្គធ្លាប់ស្គាល់ព្រះសង្ឃពុទ្ធសាសនាអង្គណាដែរទេ ដែលបានៗស្លាប់ ឬបានបាត់ខ្លួន ក្នុងអំឡុងរបបពេលហ្នឹង?

**ផៈ** ពរចម្រើនពរ ព្រះអង្គដែលស្លាប់ហ្នឹង គឺមានតែពេលចេញពីភ្នំពេញទេ ចេញបែកពីតាមខេត្តនានាទេ ពរ អាហ្នឹងមានស្លាប់ ពរ។ តាមខេត្ត បែកតាមខេត្ត បែកពីរាជធានី។ ពេលអាត្មាចិត -- ១៧ មេសា ចេញរួបរាងមក គេ -- កាលនោះគេទុកព្រះសង្ឃសម្តេចសង្ឃរាជ ហួត តាត ហើយលោកនៅគង់នៅៗ។ អាត្មាដឹងប្រហែលជា ២០អង្គដែរនៅភ្នំពេញ ពរ។ ប៉ុន្តែដល់ក្រោយមកបាត់អស់ទៅមិនដឹងទៅណា មកណាទេ។

**សៈ** ករុណាចង់ពិតទូលព្រះអង្គអំពីសង្ឃពុទ្ធសាសនាដែលនៅខេត្តតាកែវ តើព្រះអង្គមានស្គាល់ព្រះសង្ឃអង្គណាដែលបានអនិច្ចកម្ម ឬក៏ត្រូវបានធ្វើគុតនៅ ឬក៏បាត់ខ្លួននៅពេលនោះ?

[១០:១០:៥៣]

**ផៈ** អាត្មាបាត់ -- សុគតម្នាក់ទេ មិត្តភក្តិរាប់អានគ្នាស្គាល់គ្នានៅខាងជើងផ្សារស្វាយព្រៃ ពរ

អាហ្នឹងបានរ៉ាយរ៉ាប់ប្រាប់ថា "អូ្ហ! លោកគ្រូឯងមិនទាន់ដឹងទេ ករុណានៅហ្នឹងគេធ្វើបាបព្រះសង្ឃ រ៉ៃព្រះសង្ឃងាប់បាត់ហើយ។ រឹងទទឹងហ្នឹងគេ អង្គការចាត់តាំងមិនព្រម"។

**ស៖** នៅដំណាក់កាលក្រោយមកទៀត នៅពេលដែលព្រះអង្គសឹកមកវិញ តើព្រះអង្គត្រូវបានគេចាត់ទុកថា ជាអតីតព្រះសង្ឃ ជាកសិករ ជាសក្តិភូមិ ឬក៏ប្រជាជនថ្មី? ព្រះអង្គនិមន្តឆ្លើយមួយសាទៀតអំមិញ--

**ឆ៖** ពរ គេហៅ ១៧ មេសា។ ពួកហ្នឹងពួក ១៧មេសា។ ពរ។

**ស៖** តើនៅពេលហ្នឹង គេមានបង្គាប់ឲ្យព្រះអង្គបំពេញប្រវត្តិរូបដែរឬទេ? ព្រះអង្គនិមន្តឆ្លើយមួយសាទៀតព្រះអង្គ។

[០៩:១២:២៦]

**ឆ៖** ពរ មានប្រសាសន៍ថាម៉េច? មើល។ អត់ឮផង។

**ស៖** តើពេលហ្នឹងព្រះអង្គត្រូវបានគេឲ្យ -- បង្គាប់ឲ្យបំពេញប្រវត្តិរូបដែរឬទេ?

**ឆ៖** អត់មានទេបង អត់មានទេ អត់ដែលមានប្រវត្តិរូបអីទេ អត់មានទេ ពរ។

**ស៖** ហើយក្រោយមក គេឲ្យព្រះអង្គទៅធ្វើការងារអីដែរ?

**ឆ៖** អាត្មាកាលនោះជាយុវជន ពរ យុវជន។

**ស៖** នៅ។ គេឲ្យទៅធ្វើការនៅកន្លែងណាដែលព្រះអង្គ?

**ឆ៖** អាត្មាជម្រាបអីចេះ ព្រោះអាត្មាពាក់ព័ន្ធពីរខេត្ត។ អាត្មានៅអង្គរកា តែអាត្មាមកខេត្តកំពតនៅកំពតវិញ ពរ ព្រោះញាតិញោមអាត្មានៅកំពត មកកំពតវិញ ពរ។ តែអាត្មាបួសនៅអង្គរកា ទៅរៀនសូត្រនៅអង្គរកា នៅអង្គរកាហ្នឹង ដល់ហើយបានមកនៅកំពតវិញ។ ពរ នៅយុវជន។

[១០:១៤:00]

**ស៖** ដែលករុណាពិតទូលព្រះអង្គទាំងអស់ហ្នឹង គឺចង់ពិតទូលតែនៅក្នុងខេត្តតាកែវទេ អត់--

**ឆ៖** យុវជន នៅយុវជន លើកប្រឡាយលើកទំនប់ លើកប្រឡាយលើទំនប់អីហ្នឹងពរ។

**ស៖** នៅកន្លែងណាដែលព្រះអង្គ នៅកន្លែងណា?

**ឆ៖** អង្គរកាតែម្តង ព្រោះគេបំបែកគ្នាខ្លះទៅនៅត្រពាំងអណ្តើក ខ្លះនៅអង្គរកា តែអាត្មាបាននៅអង្គរកាហ្នឹង ព្រោះចាស់ទុំគាត់ស្គាល់ច្រើន នៅហ្នឹងទៅ សុំគាត់នៅហ្នឹងទៅ។

**ស៖** ចុះស្ថានភាពការងារពេលហ្នឹងយ៉ាងដូចម្តេចដែរ ព្រះអង្គ?

**ឆ៖** ម៉េច ពរ មានប្រសាសន៍ម្តងទៀតមើល៍!

**ស៖**ករុណាចង់ពិតទូលអំពីអ្វីដែលព្រះអង្គជួបផ្ទាល់ ដែលនៅពេលដែលព្រះអង្គគេបង្គាប់ឲ្យទៅធ្វើការនៅត្រពាំងអណ្តើកហ្នឹង តើលក្ខខណ្ឌការងារហ្នឹងព្រះអង្គៗជួបៗកិច្ចការអីខ្លះ ហើយទទួលមានស្ថានភាពដូចម្តេចដែរ?

**ឆ៖** ចម្រើនពរ យុវជនមានតួនាទីខ្លាំងជាងយុវចាស់។ យុវជនកម្លាំងឈានមុខ កម្លាំងទី១ លើកប្រឡាយ ជីកប្រឡាយ លើកទំនប់ ស្រែប្រាំង យុវជនទាំងអស់តែម្តង កម្លាំងឈានមុខ កម្លាំងទី១។

[១០:១៦:០៥]

**ស៖** តើៗពេលហ្នឹងព្រះអង្គស្ថិតនៅក្រោមបង្គាប់អ្នកណា?

**ឆ៖** ម៉េចទៀតពរ? ម្តងទៀតមើល៍។

**ស៖** តើនៅពេលដែលព្រះអង្គបំពេញការងារហ្នឹង តើព្រះអង្គស្ថិតនៅក្រោមបង្គាប់របស់អ្នកណា?

**ឆ៖** ដូចជំនាន់ ប៉ុល ពត កាលនោះមិនបានសួរនាំអីគេទេ មិនស្គាល់គេទេ។

**ស៖** អ៊ីចឹងៗនៅពេលហ្នឹងព្រះអង្គធ្វើការតាមៗអ្នកណាៗបង្គាប់?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** តើនៅពេលហ្នឹងព្រះអង្គធ្វើការតាមៗបង្គាប់របស់អ្នកណា?

**ឆ៖** ព្រោះគេមានក្រុមគេពរ ក្រុមៗ។ កងមកក្រុម អាត្មានៅក្រុម ពរ។

**ស៖** តើនៅពេលហ្នឹងគេមានកំណត់ជាផែនការៗដែរទេ សម្រាប់ការងារដែលព្រះអង្គបានបំពេញនៅពេលនុ៎ង?

**ឆ៖** បើលើកប្រឡាយ គេកំណត់៣០ម៉ែត្របណ្តោយ ជម្រៅពីរម៉ែត្រ មាត់លើប្រាំម៉ែត្រ មាត់ក្រោម៣ម៉ែត្រ ៣០នាក់ឲ្យហើយ កំណត់ថាកន្លះខែហើយ។ បណ្តោយ ៣០ ហ្នឹងប្រឡាយ។

[១០:១៨:២២]

**ប្រធានអង្គជំនុំ៖**

បាទ ដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នក

ជំនាញដល់ព្រះតេជព្រះគុណ ឯម ភឿង នៅក្នុងអំឡុងពេលសម្រាកនេះ ហើយនិងឲ្យនិមន្តព្រះអង្គមកចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៨ នាទី ដល់ម៉ោង ១០:៣៦ នាទី)*

[១០:៣៦:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោយចំពោះសាក្សី។ សូមអញ្ជើញ!

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** មុនពេលសម្រាកអម្បាញ់មិញនេះ ករុណាបានពិតទូលព្រះអង្គអំពីផែនការដែលគេដាក់ឲ្យ។ អ៊ីចឹង តាមទំហំការងារហ្នឹង តើព្រះអង្គទទួលបាននូវរបបចង្ហាន់គ្រប់គ្រាន់ដែរទេ?

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** ដូចជីវភាពហ្នឹងវាមិនអាចថ្លែងទេ។ ជីវភាពហ្នឹងមិនបាច់ថ្លែងទេ ព្រោះកម្លាំងច្រើនជាងជីវភាព ជីវភាពតិចជាងកម្លាំង។ ធ្វើការច្រើន ជីវភាពតិចណាស់ណា។

**ស៖** ក្នុងកម្រិតដូចម្តេចដែរព្រះអង្គ? ព្រះអង្គមានថេរៈដីកាថា មិនអាចៗអត្ថាធិប្បាយបានហ្នឹង តើមានន័យថាដូចម្តេចដែរ?

**ឆ៖** ចម្រើនពរ សម័យនោះពលកម្មច្រើន ក៏ប៉ុន្តែដល់ជីវភាពវាតិច។ មិនល្មមនឹងពលកម្មហ្នឹងណា ជីវភាពហ្នឹងណា ប៉ុន្តែអត់ធ្លត់តស៊ូ ដើម្បីជីវិត។

**ស៖** ចុះកាលសម័យនោះ អ្នកជំងឺដែលព្រះអង្គបានជួបប្រទះហ្នឹង តើអ្នកជំងឺអាចទទួលរបបអាហារដែរឬទេ?

**ឆ៖** គឺចែកឲ្យតាម អ្នកជំងឺនៅតាមផ្ទះគេរែកចែកឲ្យ រែកចែក ដូចជាឪពុកធំអាត្មាវិញ គេចែកបាយ ព្រោះអ្នកជំងឺអត់មានធ្វើការអី គេឲ្យមួយវែកអ៊ីចឹងទៅពរ គ្រប់គ្នាអ៊ីចឹង។ អ្នកជំងឺនៅផ្ទះ តាម

ពេទ្យផ្សេង។

**លោក ស្រ៊ា រតនៈ៖**

សូមគោរពអង្គជំនុំជម្រះ ខ្ញុំបាទសូមបញ្ចប់កម្រងសំណួរខ្ញុំត្រឹមប៉ុណ្ណេះ ហើយទុកលទ្ធភាពជូនទៅលោកសហព្រះរាជអាជ្ញារងអន្តរជាតិស្នួរបន្ត បាទ។

[១០:៤០:០៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរ ភាគីទាំងអស់។ ព្រះអង្គ ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនអំពីអ្វីដែលព្រះអង្គបានជួបប្រទះ។ ជាពិសេស គឺនៅក្នុងស្រុកត្រាំកក់ អ៊ីចឹងខ្ញុំនឹងនិយាយអំពីអ្វីដែលកើតឡើងនៅក្នុងវត្តអង្គរកា។ លោកប្រធាន ដើម្បីឲ្យបានច្បាស់នោះ យើងបានចាប់ផ្តើមនៅម៉ោងប្រាំបួនកន្លះ។ អ៊ីចឹង ខ្ញុំសូមបន្តរហូតដល់ដប់មួយកន្លះ។ ដើមបណ្តឹងរដ្ឋប្បវេណី គាត់មានសំណួរបន្តិចបន្តួចទេ អ៊ីចឹងគាត់អាចសួរនៅដើមរសៀលនេះ លោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំនឹងបន្តពីអ្វីដែលខាងព្រះរាជអាជ្ញាជាតិបានសួរ គឺពាក់ព័ន្ធនឹងការជីកប្រឡាយនៅស្រុកត្រាំកក់។ ព្រះអង្គបានមានថេរៈដីកាថា មានអ្នកធ្លាក់ខ្លួនឈឺ ហើយព្រះអង្គប្រាប់ថា គេចាត់ទុកព្រះអង្គជា អ្នក១៧មេសា។ តើនៅក្នុងកងដែលព្រះអង្គធ្វើការនុង គឺសុទ្ធតែជាអ្នក១៧មេសា<>?

[១០:៤១:២៦]

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** នៅតាមការដ្ឋានមាន១៧មេសាខ្លះ មានមូលដ្ឋានខ្លះ ចម្រុះ ព្រោះមូលដ្ឋានគេអ្នកគ្រប់គ្រង។

**ស៖** តើព្រះអង្គមានកត់សម្គាល់ឃើញថា អ្នកមូលដ្ឋានហ្នឹងធ្វើការនៅកន្លែងតែមួយដូចព្រះអង្គទេ? ហើយអ្នកមូលដ្ឋានហ្នឹង ហូបចុកអីនៅកន្លែងតែមួយដូចព្រះអង្គដែរទេ?

**ឆ៖** បើៗកងៗនៅជាមួយ បើកងនៅជាមួយ បើភូមិមិនបាននៅជាមួយយើងទេ បើកងនៅជាមួយពរ។

**ស៖** នៅក្នុងស្រុកត្រាំកក់ តើព្រះអង្គមានសង្កេតឃើញការប្រព្រឹត្តខុសគ្នាចំពោះអ្នក១៧មេសាហើយនិងអ្នកមូលដ្ឋានដែរទេ ឧទាហរណ៍ដូចជាម្ហូបអាហារ ការងារ ឬក៏ការស្នាក់នៅជាដើមនោះ?

**ឆ៖** ពរ សម័យហ្នឹង មុនដំបូងគេចែកជាមូលដ្ឋាន ចែក១៧មេសា អ្នកជម្លៀសមកពីទីក្រុង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

នានាដាក់១៧មេសា មូលដ្ឋានគេផ្សេង។

**ស៖** ខ្ញុំសូមសួរម្តងទៀត ខ្ញុំចង់ដឹងថា តើអ្នកមូលដ្ឋាននិងអ្នក១៧មេសានេះ មានទទួលនូវការប្រព្រឹត្តដូចគ្នាទេ ឧទាហរណ៍ព្រះអង្គទទួលចង្ហាន់ដូចគ្នា ហើយស្នាក់កន្លែងតែមួយជាមួយគ្នា? អ៊ីចឹង ខ្ញុំចង់ដឹងថា តើគេប្រព្រឹត្តចំពោះព្រះអង្គហ្នឹង ដូចទៅនឹងអ្វីដែលគេប្រព្រឹត្តចំពោះ<>ប្រជាជនមូលដ្ឋានដែរទេ?

[១០:៤៣:៥៨]

**ឆ៖** នៅកន្លែងហ្នឹង គឺរោងបាយតែមួយ អាហារហូបចុករួមគ្នាពរទាំងមូលដ្ឋាន ទាំង១៧មេសា រោងបាយតែមួយ។

**ស៖** ព្រះអង្គមានថេរៈដីកាថា អ្នក -- អ្នកមូលដ្ឋានហ្នឹងត្រួតត្រាលើអ្នក១៧មេសា។ អ៊ីចឹង តើមានគេធ្វើបាបអ្នក១៧មេសា ទេ? ព្រះអង្គមានសង្កេតឃើញបែបហ្នឹងទេ?

**ឆ៖** ចម្រើនពរ កន្លែងអាត្មាមិនមានឃើញទេពរ។

**ស៖** តើព្រះអង្គមានឃើញគេនាំមនុស្សចេញ ឬក៏មានឃើញមានមនុស្សបាត់ខ្លួនទេនៅពេលដែលព្រះអង្គធ្វើការនៅស្រុកត្រាំកក់នោះ?

**ឆ៖** ពរ ចម្រើនពរ ឃើញបាត់អ៊ីចឹងដែរ។ ប៉ុន្តែសួរគ្នីគ្នាថា មិនដឹងទៅណាថា គេថា "អង្គការគេហៅទៅរៀនសូត្របាត់ហើយ មិនដឹងទេ"។ សួរគ្នីគ្នាទៅ គេឆ្លើយតែប៉ុណ្ណឹងចប់តែម្តង។

**ប្រធានអង្គជំនុំ៖**

សម្របសម្រួលឲ្យគាត់ចេញក្រៅ នាំគាត់ចេញក្រៅទៅ ហើយឲ្យគាត់ទៅរកពេទ្យ។

បាទអញ្ជើញបន្តទៀត លោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

**ស៖** ព្រះអង្គនិយាយអំពីការបាត់ខ្លួនមនុស្សមួយចំនួន អ៊ីចឹងការបាត់ខ្លួនហ្នឹង ញឹកញាប់ទេព្រះអង្គ? ព្រះអង្គអាចប្រាប់ឈ្មោះមនុស្សដែលបាត់ខ្លួនហ្នឹងបានទេ? ហើយព្រះអង្គស្គាល់ទេអ្នកដែលបាត់ខ្លួនទាំងនុ៎ង?

[១០:៤៦:១១]

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** ដូចមិនបានស្គាល់ទេ។

**ស៖** ខ្ញុំគិតថាប្រហែលយើងស្តាប់គ្នាមិនយល់ ប្រហែលជាបញ្ហាបកប្រែឬក៏យ៉ាងណា? ព្រះអង្គមានថេរៈដីកាថាមនុស្សមួយចំនួនបាត់ខ្លួន គឺគេនាំយកទៅ<អប់រំ>កសាង។ អ៊ីចឹង ខ្ញុំចង់អានសម្រង់នៃកំណត់ហេតុស្តាប់ចម្លើយព្រះអង្គនៅចំពោះចៅក្រមស៊ើបអង្កេត គឺឯកសារ E3/5133 ទំព័រ៥ ជាភាសាបារាំងគឺ 00702336, ជាភាសាអង់គ្លេស ទំព័រ៤ 00223200, ជាភាសាខ្មែរទំព័រ៤ 00165261 ។ ព្រះអង្គបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតថា "ខ្ញុំជួប ណុប ណៃម ហើយនិងប្រពន្ធរបស់គាត់ គឹម ណូវ៉ា យើងធ្វើការជាមួយគ្នា។ បន្ទាប់មកទៀតអង្គការបានស្នើឲ្យអ្នកទាំងពីរ ហើយនិងកូន<ស្រី> គាត់ហ្នឹង គេយកចេញទៅ។ បន្ទាប់មកអ្នកទាំងអស់ហ្នឹងបាត់ខ្លួនរហូត។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងតើព្រះអង្គអាចរៀបរាប់អំពីអ្វីដែលបានកើតឡើងចំពោះ ណុប ណៃម និង គឹម ណូវ៉ា បានទេ? ហើយអ្នកទាំងពីរហ្នឹងជាអ្នកណាដែរព្រះអង្គ?

**ឆ៖** ចម្រើនពរ អ្នកទាំងពីរនេះ កាលអាត្មានៅភ្នំពេញ គាត់ជាឧបត្ថៈកុដិអាត្មា ពរ ឧបត្ថៈអាត្មា។ ដល់ពេលរំដោះបានមកហ្នឹង ក៏បានជួបគ្នានៅអង្គរកាហ្នឹង លើកប្រឡាយ ទំនប់ នៅហ្នឹង ពរ លើកប្រឡាយខាងកើតវត្តអង្គរកាហ្នឹង។ ហ្នឹងបានគេស្នើសុំ អ្នកទាំងពីរហ្នឹង ហើយនិងកូនស្រីមួយហ្នឹងបាត់ទៅ មិនដឹងទៅឯណាបាត់ទៅ បាត់រហូតមក ពរ អាត្មាអត់ដឹងដែរ។

**ស៖** នៅពេលដែលព្រះអង្គមានថេរៈដីកាថា អង្គការស្នើយកគាត់ទៅហ្នឹង តើពួកគាត់មានសិទ្ធិថាទៅ ឬក៏មិនទៅទេពេលហ្នឹង? ឬក៏<ពួកគាត់>ត្រូវ<គេបង្ខំឲ្យ>ទៅ?

[១០:៤៨:៥៨]

**ឆ៖** ទេ ដូចមិនមានពាក្យអីប្រកែកផង ពរ។ ព្រោះដំបូងដែលបំផុតហ្នឹងអត់ទាន់ៗ មានអ្នកណាយល់ទេ ១៧មេសា អត់ទាន់យល់ថា តើអង្គការស្នើទៅណាហ្នឹង អត់ទាន់ដឹងទេ អត់ទាន់ដឹងថាយ៉ាងម៉េចទេ ពរ។ អត់ទាន់ដឹងទេ អត់ទាន់ដឹងគោលការណ៍របស់អង្គការយ៉ាងម៉េចអត់ដឹងដែរ អត់ទាន់ដឹងផង។ ដល់ដំបូងហ្នឹងស្នើទៅនៅនេះ ស្នើទៅនេះ ស្នើទៅនោះ ធ្វើការធ្វើងារអ៊ីចឹងទៅ អត់ទាន់ដឹងទេ ស្មានតែអ៊ីចឹងមែន ធ្វើការអ៊ីចឹងមែន ព្រោះគ្មានអ្នកសួរ ពរ។ សុទ្ធតែសួរអ្នកឯងធ្វើការអី ពីមុនមកធ្វើការអីៗហ្នឹង ប្រាប់គេត្រង់ៗទៅ គេយកទៅបាត់ទៅ មិនដឹងទៅណា មកណា ពរ។

**ស៖** ពាក់ព័ន្ធទៅនឹងប្រវត្តិរបស់ពួកគាត់នោះ តើព្រះអង្គដឹងថា ណុប ណៃម និង គឹម ណូវ៉ា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹង មានមុខរបរអ្វីដែរ មុនពេលរបបខ្មែរក្រហម?

[១០:៥០:០៤]

**ឆ៖** ពួកគាត់ជាតួកុនទាំងពីរនាក់ប្ដីប្រពន្ធ គាត់តួកុនតើ។ នៅភ្នំពេញផ្ទះគាត់នៅជិតឥន្ទ្រទេវី ផ្ទះនៅខាងត្បូងសាលាកាលេះសាលាឥន្ទ្រទេវី ពរ ទួលគោក ផ្ទះគាត់។

**ស៖** សូមអរគុណតេជគុណ។ ឥឡូវនេះ ខ្ញុំចង់សួរព្រះអង្គ <ពីរ>សំណួរពាក់ព័ន្ធទៅនឹងគុក។ តើព្រះអង្គមានធ្លាប់ឮគេនិយាយអំពីគុកនៅអង្គរកាទេ នៅពេលព្រះអង្គនៅទីនោះ? មានធ្លាប់ឮថា មានគុកខ្មែរក្រហមនៅអង្គរកាទេព្រះអង្គ?

**ឆ៖** ពរ អត់បានឃើញទេញាតិញោម អត់បានឃើញទេ។

**ស៖** ចុះព្រះអង្គមានធ្លាប់ឮគេនិយាយអំពីមន្ទីរសន្តិសុខនៅក្រាំងតាចាន់ នៅស្រុកត្រាំកក់ទេ?

**ឆ៖** ឮតែគេថា តែមិនដែលស្គាល់ផង អត់ដែលដើរៗទៅរួចទេ ឃុំណានៅឃុំនុ៎ង អត់ដែលប៉ានដើរទៅឆ្ងាយផង ឮគេថា គេនិយាយ តែមិនដែលឃើញផង។ អ្នកនៅឃុំណា នៅឃុំហ្នឹង ភូមិណាភូមិហ្នឹង អត់ប៉ានឈានជើងទៅណាមកណាឆ្ងាយពីកន្លែងគេឲ្យនៅផងកាលនោះ។

[១០:៥១:៤៣]

**ស៖** អ៊ីចឹងព្រះអង្គឮអ្វីខ្លះពីក្រាំងតាចាន់? តើគេនិយាយអីខ្លះពីក្រាំងតាចាន់? ហើយព្រះអង្គដឹងទេថា ក្រាំងតាចាន់ហ្នឹងជាកន្លែងអ្វីដែរ ហើយមានអ្វីកើតឡើងដែរចំពោះអ្នក ដែលគេបញ្ជូនទៅក្រាំងតាចាន់ហ្នឹង?

**ឆ៖** ឮគេនិយាយៗ តែមិនដែលដឹងញោម ខ្ញុំមិនដែលដឹងទេ ឮតែនិយាយ។

**ស៖** ក្នុងអំឡុងពេលដែលព្រះអង្គធ្វើការនៅស្រុកត្រាំកក់ តើព្រះអង្គធ្លាប់ឮអំពី<អ្វីដែលបានកើតឡើងចំពោះ>អ្នក<ដែល>គេរកឃើញថា ជាមន្ត្រីរាជការ លន់ នល់ ឬក៏ជាទាហាន ឬក៏នាយទាហានរបស់ លន់ នល់ នោះ។ តើព្រះអង្គមានធ្លាប់ឮថា គេធ្វើអ្វីដែរចំពោះអ្នកទាំងអស់នុ៎ង?

**ឆ៖** សូមជម្រាបពីរឿងមន្ត្រីរាជការរបប លន់ នល់ បញ្ហាហ្នឹងៗពរ។ សូម្បីតែគ្រូក៏មានរឿងដែរ ប៉ូលិស ទាហាន ជំនាន់នោះពរ។ ហ្នឹងគេសុំហើយៗ មិនដឹងយកទៅឯណាទេ សុំហើយ តែមិនដឹងទៅឯណាមកណា មិនបានដឹងទេ គ្រាន់តែគេសុំ ៗយកហើយ។

[១០:៥៣:៣៩]

**ស៖** ព្រះអង្គមានថេរៈដីកាថា “គេសុំ” អ៊ីចឹងខ្ញុំចង់ដឹងថា តើខ្មែរក្រហមគេធ្វើយ៉ាងម៉េចបានដឹង

ថា អ្នកហ្នឹងជាមន្ត្រីរដ្ឋការ លន់ នល់ អ្នកហ្នឹងជាទាហាន ជាប៉ូលិស អ៊ីចឹងព្រះអង្គ? តើគេធ្វើ គេមានវិធីអ្វីដើម្បីដឹងថា អ្នកហ្នឹងជាទាហាន ជាប៉ូលិស ជាមន្ត្រីរដ្ឋការហ្នឹង?

**ឆ៖** ចម្រើនពរ មធ្យោបាយគេដំបូងថា អង្គការត្រូវការអ្នកណាដែលធ្លាប់ធ្វើការងារបម្រើជំនាន់សីហនុ, ជំនាន់លន់នល់ អីហ្នឹងអង្គការត្រូវការយកទៅធ្វើការឡើងវិញ ព្រោះឥឡូវខ្វះអ្នកធ្វើការធ្វើងារ។ ម្ល៉ោះហើយមិនបានដឹងរឿងពិត ក៏បញ្ចេញឲ្យគេដឹងអស់ទៅពរ ឲ្យគេដឹងទៅ។ ខ្លះក៏ដឹង ខ្លះក៏មិនលាក់ ខ្លះក៏មិនបញ្ចេញដែរ ខ្លះក៏បញ្ចេញឲ្យគេដឹងទៅ។ អ្នកណាមិនបញ្ចេញក៏បាននៅ អ្នកណាបញ្ចេញទៅក៏បាត់ទៅ ពរ។

**ស៖** ព្រះអង្គជាព្រះសង្ឃ អ៊ីចឹងតើព្រះអង្គដឹងទេថា មានរឿងអ្វីកើតឡើងនៅវត្ត<>ចម្ប៉ាលើកនៅស្រុកត្រាំកក់ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់មកនោះ? តើព្រះអង្គមានធ្លាប់ឮទេថា វត្តហ្នឹងគេធ្វើយ៉ាងម៉េចដែរ នៅពេលនុ៎ង?

**ឆ៖** ពុំបានដឹងទេញោម មិនបានដឹងទេរឿងហ្នឹង មិនបានដឹងទេ។ បើនៅភូមិណាភូមិហ្នឹង ឃុំណាឃុំហ្នឹង អត់មានប៉ានដើរក្រៅពីហ្នឹងផង អត់ដឹងទេ ពរ អត់ដឹងទេ។

**ស៖** នៅក្នុងភូមិ ឬក៏ក្នុងកង ឬក៏ក្នុងឃុំរបស់ព្រះអង្គ ព្រះអង្គធ្លាប់ជួបអ្នកណាដែលមកពីកម្ពុជាក្រោមទេ ហើយដែលគាត់និយាយរដឺនៗនោះ ព្រះអង្គមានជួបទេ?

[១០:៥៦:០៥]

**ឆ៖** អត់មាន អាត្មាអត់មានបានជួបទេ ពរ អត់បានជួបទេ។ អត់មានទេកន្លែងហ្នឹង អាត្មាអត់មានទេ។

**ស៖** ក្នុងអំឡុងពេលដែលព្រះអង្គគង់នៅវត្តអង្គរកា បន្ទាប់មកទៀត ក្នុងរយៈពេលដែលព្រះអង្គធ្វើការនៅក្នុងស្រុកត្រាំកក់ តើមេដឹកនាំ<ជាន់ខ្ពស់ថ្នាក់>តំបន់ ភូមិភាគ ឬក៏ស្រុក ឬក៏មកពីមជ្ឈិមនោះមានធ្លាប់មកទស្សនា មកពិនិត្យមើលនៅកន្លែងដែលព្រះអង្គធ្វើការទេ?

**ឆ៖** ចម្រើនពរ ដូចមិនបានឃើញទេ មិនបានដឹងទេ គឺអត់ដឹង។ ដឹងតែឃុំ ដឹងតែភូមិអីដឹង តែពលករមិនបានដឹងអីនឹងគេទេ។

**ស៖** សូមអរគុណព្រះអង្គ។ ឥឡូវនេះ ខ្ញុំចង់និយាយអំពីការប្រជុំនៅអង្គរកា ដែលនៅពេលនោះគេចែកសម្លៀកបំពាក់ ហើយគេប្រាប់ព្រះអង្គថា ត្រូវតែផ្សឹក។ ព្រះអង្គបានមានដីកាថា អ្នកដែលដឹកនាំអង្គប្រជុំនោះ គឺមានអមទៅដោយពួកឈ្លប។ តើពួកឈ្លបហ្នឹង មានកាន់កាំភ្លើងអីទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ពួកឈ្លបសម័យនោះ សុទ្ធតែមានអាវុធទាំងអស់ ពេញដៃទាំងអស់។ មិនអាចដើរទទេ សុទ្ធតែមានអាវុធស្ពាយរហូតតាម។ ឃុំទៅណា ភូមិទៅណាអី អេស្កកទៅ សុទ្ធតែមានអាវុធទាំងអស់ស្ពាយតាម។

[១០:៥៨:១៦]

**ស៖** សូមអរគុណព្រះអង្គ។ នៅអង្គរកា បើតាមព្រះអង្គដឹងហ្នឹង គឺថាមានតែការប្រជុំម្តងទេ ដែលគេប្រាប់ឲ្យព្រះសង្ឃផ្សឹកនោះ ឬក៏មានការប្រជុំច្រើនដង<>?

**ឆ៖** ក៏ពេលនោះ ប្រជុំម្តងទេ ពរ។ ប្រជុំឲ្យលាចាកសិក្ខា ដើម្បីទៅបំពេញពលកម្ម។

**ស៖** ខ្ញុំចង់អាន<សម្រង់>មួយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយព្រះអង្គ ហើយចង់សួរ<តើគេបានប្រាប់>ព្រះអង្គ<នៅ>អង្គរកា<មែនទេ។ នេះគឺជាសម្រង់>មួយនៅក្នុងឯកសារ E3/5133 ជាភាសាបារាំងគឺទំព័រ៥ 00702336, អង់គ្លេស គឺទំព័រ៥ 00223201, ជាភាសាខ្មែរទំព័រ៥ដែរ គឺលេខ ERN 00165262។ ឃ្លានោះ ព្រះអង្គនិយាយថា "ជួបព្រះសង្ឃមួយ<អង្គ នៅក្រោយមកទៀត> នៅ<ជិតខេត្ត>កំពត នៅដំណាក់ត្រយឹង" ហើយព្រះអង្គបាននិយាយអំពីខ្លឹមសារនៃកិច្ចប្រជុំមួយចំនួន។ ខ្ញុំសូមដកស្រង់៖ "សង្ឃនោះសួរថា អង្គការនិយាយអីនៅក្នុងកិច្ចប្រជុំ?" ហើយព្រះអង្គបានឆ្លើយទៅគាត់ថា៖ "គេកោះទៅប្រជុំញឹកញាប់ ហើយគេចំអកឡកឡាយឲ្យយើង"។ ហើយបន្ទាប់មកមាននៅក្នុង "អស់រាប់ពាន់ឆ្នាំមកហើយ ព្រះសង្ឃជាឈ្លើង ជាជន្លេន អាល្ងើល្ងើ អាចម្លូត"។ អ៊ីចឹង ខ្ញុំចង់ដឹងថា "ច្រើនពាន់ឆ្នាំមកហើយ ព្រះសង្ឃជាជន្លេន ជាឈ្លើងហ្នឹង" ព្រះអង្គស្តាប់ឮ នៅអង្គរកា ឬក៏ព្រះអង្គធ្លាប់ឮ នៅកន្លែងផ្សេងទៀតដែរ ដែលគេប្រមាថព្រះអង្គបែបនេះនោះ?

**ឆ៖** អ៊ីចេះ អាត្មាសូមជម្រាបពីរឿងដែលគេនិយាយ ពីរឿងពុទ្ធសាសនាជាឈ្លើង ជាជន្លេន អីនេះ។ ដល់អាត្មាទៅនៅកំពតហើយទេ ព្រោះអត់បានទៅ លោកតាវត្តអាត្មាហ្នឹងលោកមិនទាន់ចាកសិក្ខាបទទេ ដល់អាត្មាគេតែងតែហៅទៅប្រជុំ ហើយគេលើកឡើងជាញឹកញាប់ណាស់រឿងហ្នឹង។ អាចម្លូតនៅលើ អាល្ងើនៅក្រោមអីៗ ជន្លេន ឈ្លើង អីសព្វសារពើហ្នឹង។ ហើយអាត្មាតែងទៅទូលលោកថា "តេជគុណអើយ យើងមិនអាចនៅបានទេ ព្រោះករុណាទៅប្រជុំគេដាក់ផែនការធ្ងន់ៗណាស់ តេជគុណនៅមិនបានទេ ពរ"។ លោកចាស់ផង លោក៨០ជាងទៅហើយ លោកធ្វើអី លោកថា "អ្នំ ចាស់ហើយ ងាប់អីយកទៅ ខ្ជិលណាស់ ខ្ជិលរវល់"។ ហ្នឹងជម្រាបអ៊ីចឹងពរ។

[១១:០១:៤៨]

**ស៖** សូមអរគុណ ព្រះអង្គ។ តើព្រះអង្គអាចប្រាប់បានទេថា នៅពេលណាដែល-- ពេលណាដែលគេនិយាយប្រមាថថា ព្រះសង្ឃជាជន្លេន ជាឈ្លើងហ្នឹង? ហើយអ្នកណាដែលជាអ្នកនិយាយពាក្យហ្នឹង?

**ឆ៖** ពេលអង្គប្រជុំម្ដងៗពរ ទាំងភូមិ ទាំងឃុំអីគេនិយាយទាំងអស់ពរ ឲ្យតែប្រជុំ។

**ស៖** សូមអរគុណព្រះអង្គ។ ឥឡូវនេះ ខ្ញុំចង់អានសម្រង់មួយទៀតនៃកំណត់ហេតុស្ដាប់ចម្លើយអ្នកផ្សេង។ ខ្ញុំមិនអាចផ្ដល់ឈ្មោះបានទេ។ សាក្សីហ្នឹង គឺមានរហស្សនាម 2-TCW-847 ឃ្លាហ្នឹង នៅក្នុងហ្នឹងគាត់និយាយអំពីកិច្ចប្រជុំនៅអង្គរកាដែរ ដែលគេចាប់ផ្សឹកព្រះសង្ឃដែរនៅពេលនោះ។ ឯកសារហ្នឹង គឺលេខ <E319.1.33> ឃ្លាពាក់ព័ន្ធនោះ គឺនៅចម្លើយ-សំណួរ ១៤៦ដល់១៥៥។ ខ្ញុំនឹងអានហើយបន្ទាប់មកខ្ញុំនឹងសួរព្រះអង្គនូវសំណួរមួយចំនួន។ “សំណួរ១៤៦៖ ក្រោយថ្ងៃរំដោះ ១៧ មេសា ៧៥ តើមានរឿងអ្វីកើតឡើងចំពោះព្រះសង្ឃ? ចម្លើយ៖ ខ្ញុំឃើញគេផ្សឹកព្រះសង្ឃ។ សំណួរ៖ តើលោកឃើញនៅកន្លែងណា ហើយនៅពេលណា? ចម្លើយ១៤៧៖ ខ្ញុំបានឃើញគេផ្សឹកព្រះសង្ឃនៅវត្តអង្គរកា នៅក្នុងស្រុកត្រាំងកក់ ប្រហែលជានៅចុងឆ្នាំ១៩៧៥។ តើលោកឃើញគេផ្សឹកយ៉ាងដូចម្ដេចខ្លះ? ចម្លើយ១៤៨៖ គេរៀបចំការប្រជុំ ហើយគេផ្សឹកតែម្ដង។ នៅពេលនោះ គេផ្សឹកព្រះសង្ឃប្រហែលជា៣០ ទៅ៤០អង្គ។ សំណួរ៖ តើអ្នកណាជាអ្នកដឹកនាំការប្រជុំនៅពេលនោះ? ចម្លើយ១៤៩៖ កូនតាម៉ុក ជាចៅហ្វាយស្រុក គឺជាអ្នកដឹកនាំការប្រជុំនោះ។ សួរ៖ តើកូនរបស់ តាម៉ុក មានឈ្មោះអ្វី? ចម្លើយ១៥០៖ ឈ្មោះ ខុម ជាមនុស្សស្រី ជាចៅហ្វាយស្រុកត្រាំកក់មុនដំបូងបង្អស់គឺ មុនចៅហ្វាយស្រុកឈ្មោះ ជឹមទៅទៀត។ ខុម ជាប្រពន្ធរបស់ តាមុត ដែលជាប្រធានកងពលលេខ២។ សំណួរ៖ ហេតុអ្វីបានជាលោកដឹងអំពីរឿងផ្សឹកព្រះសង្ឃនេះ? ចម្លើយ១៥១៖ គេបានឲ្យខ្ញុំយកសំបុត្រទៅឲ្យគេ ពេលនោះ ខ្ញុំក៏ឃើញគេផ្សឹកព្រះសង្ឃ។ សួរ៖ តើពាក្យថា ផ្សឹក នេះលោកចង់សំដៅទៅលើការផ្សឹកដូចម្ដេច? ចម្លើយ១៥២៖ គេនិយាយថា មិនត្រូវឲ្យមានព្រះសង្ឃនោះទេ ហើយគេបានរៀបចំខោអាវខ្មៅមួយកំប្លេម្នាក់សម្រាប់ព្រះសង្ឃទាំងអស់នោះ។ គេមិនបានផ្សឹកព្រះសង្ឃតាមបែបសាសនានោះទេ។ សំណួរ៖ តើមានព្រះសង្ឃណាប្រកែក ឬមិនព្រមដោះស្បង់ចេញដែរឬទេ? ចម្លើយ១៥៣៖ អត់មានអ្នកណាហ៊ានប្រកែកនោះទេ។” ខ្ញុំសូមបញ្ឈប់ត្រឹមហ្នឹង។ នេះជាចម្លើយរបស់សាក្សីផ្សេងដែលគាត់បានឆ្លើយអំពីការប្រជុំនៅវត្តអង្គរកា។ ព្រះអង្គ តើព្រះអង្គនៅតែបញ្ជាក់ដដែលទេថា នៅប្រជុំនោះគឺថានៅឆ្នាំ៧៦ ក៏ប៉ុន្តែនៅក្នុងនេះគេនិយាយថា គឺនៅចុងឆ្នាំ៧៥ទេ។ អ៊ីចឹង ព្រះអង្គនៅតែរក្សាចម្លើយដដែលថានៅឆ្នាំ៧៦ ឬក៏នៅ

ចុងឆ្នាំ៧៥?

[១១:០៦:១១]

**ឆ៖** អឺចេះ អាត្មាជម្រាបអឺចេះថា ៧៦ ព្រះសង្ឃត្រូវសឹកអស់៧៦ គឺដើមឆ្នាំ៧៦ ចុង៧៥ ព្រោះមិនអាចនៅបានទេ។

**ស៖** សូមអរគុណព្រះអង្គ។ សាក្សីនេះ គាត់និយាយអំពីស្ត្រីដែលជាអ្នកដឹកនាំកិច្ចប្រជុំនុំង <គឺជាចៅហ្វាយស្រុកត្រាំកក់> ឈ្មោះ ខុម ជាកូនរបស់ តាម៉ុក។ តើព្រះអង្គធ្លាប់ឮឈ្មោះ ខុម នេះទេ? ហើយធ្លាប់ឃើញឈ្មោះ ខុម នេះនៅក្នុងកិច្ចប្រជុំណាមួយនៅអង្គរកាទេ?

**ឆ៖** មិនស្គាល់ទេញោម មិនស្គាល់ទេ អត់ស្គាល់ទេ។

**ស៖** សាក្សីគាត់និយាយថា ព្រះសង្ឃប្រហែល៣០ទៅ៤០អង្គត្រូវបានគេចាប់ផ្សឹកក្នុងពេលតែមួយ។ អឺចឹង តើព្រះអង្គអាចប្រាប់បានទេថា ព្រះសង្ឃប៉ុន្មានអង្គដែរ ដែលនៅវត្តអង្គរកានុំង ហើយគេចាប់ផ្សឹកនុំង? សរុបទាំងអស់ប៉ុន្មានអង្គដែរ?

**ឆ៖** ព្រះសង្ឃដែលនៅអង្គរកាហ្នឹង ប្រមូលពីវត្តសីហរតនារាម ខេត្តតាកែវ ស្នាក់នៅហ្នឹង ព្រោះវត្តអង្គរការហ្នឹងពីដើមជាអនុគុណស្រុកត្រាំកក់។ ពរ ឲ្យជុំគ្នាហ្នឹងពរ ជុំគ្នាហ្នឹង ដើម្បីគេឲ្យទៅធ្វើការនៅត្រពាំងអណ្ដើកហ្នឹង ពរ អឺចឹង។ ប៉ុន្តែព្រះសង្ឃដែលអស់គឺចុងឆ្នាំ-- ដើមឆ្នាំ៧៦ អស់ព្រះសង្ឃ។

[១១:០៨:២២]

**ស៖** អឺចឹង ព្រះអង្គមិនអាចរាប់ចំនួនបានទេ គឺចំនួនព្រះសង្ឃដែលបានចាប់ផ្សឹកនោះ។ ព្រះអង្គមិនដឹងថា តើ ១០, ២០ <រាប់សិបនាក់> ឬក៏១០០ <ឬក៏លើសហ្នឹង>អីទេ។ អឺចឹងមែនទេ ព្រះអង្គ?

**ឆ៖** ពរ បាទ អឺចឹងហើយពរ មិនបានរាប់ឲ្យទៀងទាត់ថាប៉ុន្មានៗ អត់ដឹងទេ អត់បានរាប់ទេ។

**ស៖** សូមអរគុណព្រះអង្គ។ តើព្រះអង្គធ្លាប់ឮព្រះសង្ឃមួយអង្គព្រះនាម "តាអ៊ិចៗ" ជាចៅអធិការវត្ត<មួយ> នៅត្រាំកក់ ព្រះអង្គធ្លាប់ឮព្រះនាមរបស់ព្រះសង្ឃហ្នឹងទេ តាអ៊ិច?

**ឆ៖** ឃ្លោក អ៊ិច ឧបជ្ឈាអាត្មា។ ឃ្លោក អ៊ិច ឧបជ្ឈាអាត្មាហ្នឹង ពរ វត្តអង្គរការហ្នឹង។

**ស៖** ព្រះអង្គដឹងថាតើមានរឿងអ្វីកើតឡើងចំពោះព្រះសង្ឃនុំងទេ? ហើយគាត់មានបានជំទាស់ទៅនឹងបញ្ជារបស់ខ្មែរក្រហមទេ?

**ឆ៖** អាត្មាមិនបានដឹងទេពរ បើលោកសឹកក្រោយគេពរ។

[១១:១០:១០]

**ស៖** សូមអរគុណ ព្រះអង្គ។ ឥឡូវនេះ ខ្ញុំចង់អានចម្លើយរបស់សាក្សីមួយផ្សេងទៀត ដែលគាត់បានផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះហើយ គឺក្នុងសំណុំរឿង០០២/០១ គាត់និយាយអំពីកិច្ចប្រជុំនៅវត្តអង្គរកា គឺឈ្មោះ ខៀវ នៅ។ គាត់ធ្វើសក្ខីកម្មនៅ<ថ្ងៃទី២០> ខែមិថុនា ឆ្នាំ<២០១២> ឯកសារនោះគឺ <E1/89.1> គឺនៅប្រហែលម៉ោង១៥:៣២នាទី។ គាត់និយាយថា៖ "ព្រះសង្ឃមកពីភ្នំពេញនិងតាកែវត្រូវបានគេប្រមូលផ្តុំដាក់<ជាមួយគ្នា>។ យើងដឹងថា អង្គការបញ្ជាឲ្យ<យើងឈប់ធ្វើជាព្រះសង្ឃ។ នេះគឺជារឿងដែលយើងបានធ្វើ។> ប៉ុន្តែខ្ញុំអត់ចាំ<កាលបរិច្ឆេទជាក់លាក់នោះ>ទេ។ គឺ<បន្ទាប់ពី>ខែមេសា ឆ្នាំ៧៥។"

បន្ទាប់មកទៀត នៅក្នុងម៉ោង១៥:<៥១>នាទី គាត់និយាយថា៖ "<ដូចខ្ញុំបានបញ្ជាក់ខាងដើមគឺ>ព្រះសង្ឃទាំងអស់ហ្នឹងមកពីតាកែវ និងមកពីភ្នំពេញ ហើយ<គេប្រមូលផ្តុំ>គ្នានៅវត្តអង្គរកា ខ្ញុំក៏នៅទីនុំងដែរ។ ខ្ញុំក៏ត្រូវបានគេចាប់ផ្សឹកដែរ ហើយខ្ញុំក៏<ត្រូវបានគេចាប់ផ្សឹកដំណាលគ្នា>ជាមួយអ្នកផ្សេងទៀត<ដែរ>។"

បន្ទាប់មកទៀតគឺ ឯកសារ E1/90.1 បន្ទាប់ពី ០៩:០៩នាទី ខៀវ នៅ គាត់បានឆ្លើយបន្តទៀតថា៖ "នៅសម័យនោះ គេប្រាប់ថា អង្គការឲ្យទៅវត្តអង្គរកា"។ ចុះមកក្រោមទៀតមក គេសួរថា៖ "តើដឹងថាអ្នកណាគេឲ្យមកវត្តអង្គរកាហ្នឹងទេ? ព្រះសង្ឃហ្នឹងមកដោយខ្លួនឯង ឬក៏គេ<បញ្ជា>ឲ្យមក? ចម្លើយ៖ ខ្ញុំអត់ដឹងអំពីបញ្ហាហ្នឹងទេ នៅពេលដែលយើងជជែកគ្នានោះ យើងដឹងថា អង្គការប្រាប់មកថាឲ្យយើងទៅវត្តអង្គរកាទាំងអស់គ្នា ទៅជួបជុំគ្នានៅទីនុំង"។ ហើយនៅម៉ោង០៩:២៤ គាត់ថា៖ "ខ្ញុំមិនមានឃើញព្រះសង្ឃណាមួយប្រកែកមិនព្រមផ្សឹកទេ។" អ៊ីចឹង ខ្ញុំចង់ដឹង ព្រះអង្គស្គាល់ព្រះសង្ឃ ខៀវ នៅ ហ្នឹងទេ? ហើយព្រះអង្គមានជួបគាត់ទេ នៅពេលដែលព្រះអង្គទៅជុំនៅវត្តអង្គរកានុំង?

**ឆ៖** ចម្រើនពរ ខៀវ នៅ ហ្នឹង កាលមុនមហាមន្ត្រី ភ្នំពេញដែរហ្នឹង មហាមន្ត្រីទេ ពរ។--

[១១:១៣:២០]

**ស៖** ខ្ញុំកំពុងតែរង់ចាំការបកប្រែឃ្លាចុងក្រោយនៃចម្លើយរបស់ព្រះអង្គ ព្រោះខ្ញុំអត់បានស្តាប់ឮអម្បាញ់មិញ។ សូមព្រះអង្គមានដីកាម្តងទៀត ព្រះអង្គថា ខៀវ នៅ ហ្នឹងជាព្រះសង្ឃ ហើយគង់នៅភ្នំពេញ។ ហើយព្រះអង្គបានមានសង្ឃដីកាបន្ថែមទៀត ក៏ប៉ុន្តែខ្ញុំអត់បានស្តាប់ឮតាមរយៈការបកប្រែទេ។ សូមព្រះអង្គមានសង្ឃដីកាម្តងទៀត។

**ឆ៖** លោក ខៀវ នៅ ហ្នឹង ពីដើមគាត់នៅមហាមន្ត្រី ពរ។ រួចដល់មក ក្រោយមកតែមិនដឹង

ទៅនៅឯណាមកឯណា អាត្មាមិនបានដឹងទេ មិនបានជួបគ្នាទេ។

**ស៖** សូមអរគុណព្រះអង្គ។ តាមរយៈសក្ខីកម្មរបស់គាត់នោះ គាត់បញ្ជាក់ថា ព្រះសង្ឃនៅភ្នំពេញ និងតាកែវ <មិនមែន>ទៅជុំគ្នានៅវត្តអង្គរកា <ដោយ>ការថៃដន្យទេ គឺខ្មែរក្រហមប្រមូលឱ្យទៅជួបជុំគ្នានៅទីនោះ។ អ៊ីចឹង ព្រះអង្គឯកភាពទេថា នៅពេលណាមួយនោះ គេនាំព្រះសង្ឃទាំងអស់នោះ គឺទៅកាន់វត្តហ្នឹងតែម្ដង?

**ឆ៖** ត្រូវហើយពរ ត្រូវហើយ មិនខុសអីទេ។

**ស៖** នៅពេលដែលគេបញ្ជាឱ្យ<>សឹកហ្នឹង តើ<>ព្រះអង្គមានជំទាស់ ឬក៏ប្រកែកថាមិនព្រមស្ដាប់តាមបញ្ជារបស់ខ្មែរក្រហមដែលឱ្យសឹកហ្នឹងទេ?

[១១:១៥:១៥]

**ឆ៖** អ៊ីចេះ អាត្មាសូមជម្រាបពីរឿងចាកសិក្ខាបទនេះ។ ព្រះអង្គមិនហ៊ានៗទេ មិនហ៊ានទេ ដោយចាស់ទុំខ្លះគាត់ថា ព្រះអង្គអើយនៅមិនបានទេ ព្រោះករុណានៅមូលដ្ឋាននេះហើយដឹងហើយ ព្រះអង្គ គេឱ្យធ្វើអីធ្វើហ្នឹងតាមគេទៅ ឱ្យបានសុខ។ ដូច្នេះ ព្រះអង្គទាំងអស់អត់មានជំទាស់អីទេ ធ្វើតាមអង្គការចាត់តាំងទាំងអស់ពរ។

**ស៖** អ៊ីចឹង ព្រះអង្គ<>ខ្លាចអី<ឱ្យពិតប្រាកដនៅពេលនោះ>?

**ឆ៖** គឺខ្លាចហ្នឹង ព្រោះៗអង្គការចាត់តាំង កាលណាបើហ៊ានប្រឆាំងអង្គការចាត់តាំង អាហ្នឹងមានរឿងផ្សេងទៀតហើយ ពរ។

**ស៖** សូមអរគុណ ព្រះអង្គ។ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីរយៈពេលដែលព្រះអង្គទៅកំពតគឺនៅវត្តដំណាក់ត្រយឹង។ ព្រះអង្គថា ព្រះអង្គបានជួបព្រះសង្ឃមួយអង្គនៅទីនោះ។ នៅពេលដែលព្រះអង្គទៅដល់វត្តនុង តើវត្តដំណាក់ត្រយឹង ហ្នឹងនៅ -- ព្រះសង្ឃនៅប្រើប្រាស់ដដែល ឬក៏ខ្មែរក្រហមបានយកវត្តហ្នឹង យកទៅប្រើប្រាស់ធ្វើអីផ្សេង?

[១១:១៧:០៥]

**ឆ៖** ពរមិនទាន់ទេ ព្រោះកាលហ្នឹងព្រះអង្គព្រះចៅអធិការលោកគង់នៅ អត់ទាន់ គេអត់ទាន់មានធ្វើអីទេ។ ខ្មែរក្រហមមិនទាន់ទេ ព្រះចៅអធិការគង់នៅពរ។ លោកមិនទាន់ទៅណាមកណាទេ លោកនៅជា -- ឃើញនៅបួសនៅឡើយកាលនោះ។

**ស៖** អ៊ីចឹង ព្រះសង្ឃដែលនៅគង់នៅក្នុងវត្តហ្នឹង មានរឿងអ្វីកើតឡើងចំពោះពួកគាត់ដែរព្រះ

អង្គនៅវត្តដំណាក់ត្រយឹងហ្នឹង?

**ឆ៖** គឺព្រះអង្គហ្នឹងមានរឿង ដោយគេចោទថាលោកបានដុតក្រមា ដុតសារុងអីចោល មិនព្រមចែកយុវជន មានរឿង។ កាលនុ៎ងលោកក៏បាន មានក្មួយលោកមួយធ្វើអីនៅក្នុងខេត្តកំពតនោះ លោកក៏ឲ្យក៏បររទេះសេះមកៗបាត់រហូតទៅមិនដឹងទៅណាទៅ។ ហ្នឹងអាត្មាដឹងទៅតាមគេប្រជុំប្រាប់។ ទើបមកជួបយុវជនឃុំ គេប្រជុំប្រាប់ថា លោកតាដំណាក់ត្រយឹងហ្នឹងទៅបាត់ហើយ ឥឡូវអង្គការចាប់យកបាត់ហើយ ប្រឆាំងអង្គការ។

[១១:១៨:៤០]

**ស៖** ព្រះអង្គអាចផ្តល់ឈ្មោះព្រះតេជព្រះគុណ ដែលប្រកែកមិនព្រមផ្សឹកហ្នឹងបានទេ? ហើយព្រះសង្ឃហ្នឹង គាត់មានតួនាទីអីដែរនៅក្នុងវត្តដំណាក់ត្រយឹងហ្នឹង?

**ឆ៖** ចម្រើនពរ ព្រះចៅអធិការវត្តឈ្មោះ សយ។ លោកចាស់ហើយ ៨០ជាងហើយព្រះជន្មលោក កាលនោះ។

**ស៖** តើព្រះអង្គដឹងថា ហេតុអីបានជាគាត់បាត់ខ្លួនទេ ហើយគាត់បានប្រព្រឹត្តកំហុសអីខ្លះដែរព្រះអង្គ?

**ឆ៖** ចម្រើនពរ មិនបានដឹងទេ។ ដឹងតាមរយៈយុវជនគេប្រជុំប្រាប់ថា លោកបាត់ហើយ បាត់ខ្លួនហើយ យកទៅកំពត ប៉ុណ្ណឹងបាត់ទៅពរ។ គេប្រជុំប្រាប់ថា បាត់ខ្លួនហើយ រឹងទទឹងនឹងអង្គការ មិនព្រមធ្វើតាមអង្គការ។ ប្រជុំប្រាប់ប៉ុណ្ណឹងបាត់ទៅ។

[១១:២០:០០]

**ស៖** ក្រៅពីព្រះតេជព្រះគុណ សយ តើមានព្រះសង្ឃផ្សេងទៀតនៅក្នុងវត្តដំណាក់ត្រយឹងដែលសុគតនៅក្នុងរបបខ្មែរក្រហមដែរទេ ព្រះអង្គ?

**ឆ៖** ពរ មិនមានឃើញទេ មិនឃើញទេ មិនឃើញមានទេ។ អស់ត្រឹមលោកហ្នឹងហើយ។

**ស៖** ដើម្បីសួរសំណួរមួយពាក់ព័ន្ធនឹងវត្តជុំគ្រៀលនៅខេត្តកំពត ខ្ញុំចង់ដឹងថា <មានពេលណាមួយ សូម្បី>ក្រោយរបបខ្មែរក្រហមហ្នឹង <តើ>ព្រះអង្គដឹងទេថា នៅក្នុងរបបខ្មែរក្រហមហ្នឹង វត្តជុំគ្រៀលហ្នឹង គេយកទៅធ្វើអ្វីដែរ?

**ឆ៖** ចម្រើនពរ អាត្មាដឹង ដោយសារអាត្មា៧៩, ឆ្នាំ៨០ ,៨១ អាត្មាមកនៅកំពតទេ ៨១ បានដឹង អាត្មាបានដឹង។ ពរ ៨១ទៅនៅកំពតហ្នឹងបាន នៅវត្តជុំគ្រៀលហ្នឹង បានឃើញសញ្ញាពេទ្យ ឃើញ

មន្ទីរពេទ្យអីទៅបានសួរចាស់ទុំទៅ គាត់ប្រាប់ថា កន្លែងនេះជាកន្លែងពេទ្យស្រែអំបិលៗ។ កន្លែងនេះ កន្លែងមូលដ្ឋានរបស់ស្រែអំបិលគេ មន្ទីរពេទ្យធំនៅវត្តហ្នឹង សម្រាប់កម្មករស្រែអំបិលទាំងអស់។ សាលារៀនសម្រាប់ឲ្យកម្មករដេក។

[១១:២១:៥៥]

**ស៖** ព្រះអង្គធ្វើការនៅជុំគ្រៀល បន្ទាប់ពីរបបខ្មែរក្រហម។ អ៊ីចឹងព្រះអង្គមានធ្លាប់ឃើញអតីតព្រះសង្ឃដែលធ្លាប់គង់នៅវត្តជុំគ្រៀលហ្នឹង ត្រឡប់មកគង់នៅវត្តហ្នឹងវិញទេ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅហើយនោះ?

**ឆ៖** ចម្រើនពរ អត់មានទេ ពរ បាត់អស់ហើយ។ អាត្មានៅកំពត ទៅនៅវត្តជុំគ្រៀលហ្នឹង៨១ បួសហើយ ឆ្នាំ៨០បានបួស ៨១ទៅនៅវត្តជុំគ្រៀល អត់មានឃើញព្រះសង្ឃដែលនៅធ្លាប់នៅហ្នឹងមកអត់មានទេ បាត់អស់ហើយ។ សួរចាស់ទុំថា ទៅណាបាត់អស់ទៅ បានអត់ឃើញមានមក? បានថា ទេ មិនដឹងទេ ប្រហែលស្លាប់អស់ហើយយ៉ាង អត់ឃើញមកបួសអ៊ីចឹង។

**ស៖** ខ្ញុំនឹងសួរសំណួរទូទៅមួយចំនួនពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា នៅក្រោមរបបខ្មែរក្រហម ហើយខ្ញុំនឹងបញ្ចប់ហើយ។ ព្រះអង្គមានថេរៈដីកានៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រះអង្គថា ព្រះសង្ឃមួយអង្គត្រូវបានសម្លាប់នៅស្រុកសំរោង នៅតាកែវ ឃុំសំរោង តាកែវ។ អ៊ីចឹងតើព្រះអង្គអាចរៀបរាប់អំពីអ្វីដែលព្រះអង្គបាន<ឃើញ ឬអ្វីដែលព្រះអង្គ>មានថេរៈដីកាទៅកាន់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង បានទេ ព្រះអង្គ?

[១១:២៣:៣២]

**ឆ៖** ចម្រើនពរ រឿងពាក់ព័ន្ធទៅដល់ព្រះសង្ឃដែលសុគតនៅវត្តអង្គប្រិយ៍ ឃុំសំរោងនេះ អាត្មាមិនបានឃើញផ្ទាល់ទេ ក៏ប៉ុន្តែមិត្តភក្តិអាត្មានៅអីហ្នឹង អ្នកបួសដែរ បួសដូចគ្នា។ ហើយបានមកជួបគ្នាប្រាប់ថា "អ្ហ៎! មិនកើតទេ លោកគ្រូអើយ គេសាហាវណាស់ មិនស្គាល់ព្រះសង្ឃ មិនស្គាល់ឧបាសកទេ ឲ្យតែទំនាស់នឹងគេវ៉ៃចោលហើយ វ៉ៃចោល"។ ហើយឥឡូវហ្នឹងម៉េចបានសួរថា "អ្នកណាវ៉ៃ?" ថា "អង្គការគេវ៉ៃចោលហើយ មួយអង្គដែរ ឥឡូវហ្នឹងលោកគ្រូ គ្រូនៅប្រឆាំងនឹងអង្គការគេ ឥឡូវវ៉ៃចោលហើយ កប់នៅក្បែរវត្តហ្នឹង ពរ"។ អាហ្នឹងៗមិត្តភក្តិរបស់អាត្មាដែលរៀនសូត្រជាមួយគ្នាប្រាប់។ បានប្រាប់ទៀតថា ឥឡូវកុំមានទំនាស់អីជាមួយអង្គការឲ្យសោះ ប្រើធ្វើអីឲ្យធ្វើទៅ អត់ធ្មត់ទៅ។ អត់បានទេ តែហ៊ានទំនាស់អង្គការ គឺអង្គការវ៉ៃចោលហើយ អត់ទុកទេ ព្រោះអង្គការ គេត្រូវការអ្នកណាដែលមិនចេះ

តវ៉ា។ អ្នកចេះតវ៉ាអាហ្នឹងអត់រស់ទេ ត្រូវស្លាប់។ អាហ្នឹងសូមបញ្ជាក់អ៊ីចឹង ពរ។

[១១:២៤:៥៤]

**ស៖** តើព្រះអង្គមានស្គាល់ -- មានដឹងថា មានព្រះសង្ឃណាដែលនៅតែពាក់ស្បង់ចីពរ ហើយនៅតែគោរពព្រះពុទ្ធសាសនា ហើយនៅគង់នៅក្នុងវត្តដដែល នៅចន្លោះពីឆ្នាំ៧៦ ទៅដល់ ឆ្នាំ៧៩នោះ? ឧទាហរណ៍នោះ ក្រោយឆ្នាំ៧៩មកនោះ ព្រះអង្គធ្លាប់ជួបព្រះសង្ឃណាដែលប្រាប់ព្រះអង្គថា គាត់នៅជាលោកដដែល នៅគង់ក្នុងវត្តដដែល អត់មានបញ្ហាអ្វីកើតឡើងចំពោះគាត់ទេ? តើមានករណីហ្នឹងកើតឡើងទេព្រះអង្គ?

**ឆ៖** ចម្រើនពរ ពាក្យនេះមិនសមស្របទេ។ សម័យ ៣ឆ្នាំ ៨ខែ ២០ថ្ងៃនេះ ពួកអ្នកបួសព្រះពុទ្ធសាសនាមិនមានសេសសល់ទេ។ មិនមានអង្គណាម្នាក់ហ៊ានលាក់ខ្លួន ពួនអាត្មាជាភេទអ្នកបួស អត់មានទេ ពរ។ ទូទៅទាំងប្រទេសកម្ពុជា គ្មានទេ អត់មានទេ គឺត្រូវតែចាកសិក្ខាបទ បញ្ចេញពលកម្មទាំងអស់គ្នា។ ចាស់ធ្វើតាមចាស់ ក្មេងធ្វើតាមក្មេង ពរ។ ចាស់ធ្វើមិនកើតក៏ធ្វើបង្គីពីរខ្សែដែរ ពរ។ យាយៗមើលក្មេងឲ្យគេដែរ ពរ។ យុវជន ក្មេងៗយុវជនឯណោះ ធ្វើការងារ។ អ្នកទំនេរអត់មានទេ ហើយអ្នកបន្លំខ្លួនថាបួសអត់មានទេ គឺសូន្យហើយ សម័យនោះសូន្យទាំងប្រទេសតែម្តង តាមអាត្មាដឹង។

[១១:២៦:២៧]

**ស៖** នៅពេលប្រជុំនៅក្នុងស្រុកត្រាំកក់ តើកម្មាភិបាល<ខ្មែរ>ក្រហមមានប្រាប់ថា ព្រះពុទ្ធសាសនាត្រូវបានលុបបំបាត់ចោលហើយ គឺថាលែងមានទៀតហើយ។ តើគេមានប្រាប់អ៊ីចឹងទេ នៅក្នុងពេលប្រជុំហ្នឹង ព្រះអង្គ?

**ឆ៖** ចម្រើនពរ គោលការណ៍របស់គេហ្នឹងពិតណាស់ គឺថា "ពុទ្ធសាសនាអស់មានហើយនៅកម្ពុជា ពរ។ បើមិនរីកចម្រើនទេ សាសនាអត់រីកចម្រើនទេ" គេនិយាយអ៊ីចេះ។ ព្រោះមនុស្សទំនេរវាច្រើន ទំនេរ អត់ការងារធ្វើ ដេកស្ងៀម អីស្ងៀម ឲ្យគេចិញ្ចឹម។ បើអ៊ីចឹងវប្បធម៌ហ្នឹង អត់មានទេៗ វប្បធម៌ស្ងៀមហ្នឹងអត់មានទេ មានតែវប្បធម៌បំពេញពលកម្មទូទៅ ហ្នឹងមាន។ សូមបញ្ជាក់ពរ ខ្លីទេ។

**ស៖** សូមអរគុណព្រះអង្គ។ ខ្ញុំមានសំណួរចុងក្រោយមួយ បន្តពីសំណួរមុន។ ព្រះអង្គបានមានថេរ:ដីកាអំពីវត្តអង្គរកានៅស្រុកត្រាំកក់ ហើយនិងដំណាក់ត្រយឹងនៅកំពត ហើយនិងជុំគ្រៀលនៅកំពត តើព្រះអង្គធ្លាប់ឃើញ ឬក៏ធ្លាប់ឮគេថា ព្រោះវត្តផ្សេងទៀតនោះ គេយកទៅធ្វើអីទេ នៅខេត្តតាកែវ និងខេត្តកំពតហ្នឹង នៅក្នុងអំឡុងរបបខ្មែរក្រហមហ្នឹង? នៅពេលដែលអត់មានព្រះពុទ្ធសាសនាអ៊ីចឹង ៗខ្ញុំ

ចង់ដឹងថា គេយកវត្តហ្នឹងទៅធ្វើអ្វីដែរ ព្រះអង្គ?

[១១:២៨:១០]

**ឆ៖** ចម្រើនពរ ភាគច្រើនធ្វើគុកដាក់អ្នកទោស ពរ ភាគច្រើនគឺយកធ្វើគុកតែម្តង។ ព្រះវិហារធ្វើគុក ព្រោះចោះជញ្ជាំងសងខាងអីចេះ ដាក់ដែកបង្គួត រនុកដាក់សោច្រវាក់ជើង ភាគច្រើន ពរ។ ភាគច្រើនគុក មានតិចទេដែលធ្វើទ្រុងជ្រូក មានតិចទេទ្រុងជ្រូក ភាគច្រើនយកទៅធ្វើគុកអស់ ដាក់អ្នកទោស។

**ស៖** សំណួរចុងក្រោយ បន្តពីចម្លើយរបស់ព្រះអង្គ ព្រះអង្គមានថេរៈដីកាថា "វត្តហ្នឹងគេយកទៅធ្វើគុក"។ អ៊ីចឹងព្រះអង្គមានចាំឈ្មោះទេថាវត្តណាខ្លះដែលខ្មែរក្រហមយកទៅធ្វើជាគុកហ្នឹងព្រះអង្គ?

**ឆ៖** ទេ មិនចាំទេ បើច្រើន ពរ។ ភាគច្រើនណាស់គ្រប់វត្ត ព្រោះវត្តវាស្រួលជាងផ្ទះ។ វត្តច្រើនធ្វើបេតុង ចោះជញ្ជាំង ចោះប្រហោងប៉ុនៗដែក ប៉ុនដែក២០លីហ្នឹង ពរ ២០លី ប៉ុនមេជើង អាហ្នឹង ធ្វើរនុក ហើយតម្រាបវាទៅ ដាក់រនុកតែមួយទេ ភាគច្រើន។ នៅកំពតក៏មានដែរកំពត កំពង់ត្រឡាច នៅអង្គរជ័យ អូរឈើទាល គឺមានសឹងទាំងអស់តែម្តង។ គុកក្នុងគុកដាក់អ្នកទោស។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណព្រះអង្គដែលបានឆ្លើយ ហើយប្រកបដោយភាពអត់ធ្មត់។

លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងសម្រាក សុំសួរទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទំនងចំណាយពេល ត្រូវការពេលវេលាប៉ុន្មានក្នុងការសួរព្រះតេជព្រះគុណ ឯម អឿង?

[១១:៣០:៣២]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំត្រូវការប្រហែលជា ៣០នាទី លោកប្រធាន ព្រោះថាដោយសារព្រឹកមិញនេះ យើងយឺតពេលអស់ប្រហែលជាកន្លះម៉ោងហើយ មុននឹងចាប់ផ្តើមសួរសំណួរនោះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចុះខាងក្រុមការពារក្តីទំនងប្រើពេលវេលាអស់ទេ ដែលៗពេលវេលាដែលចែកឲ្យកន្លះថ្ងៃ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថា ក្រុមយើងខ្ញុំអាចបញ្ចប់នៅថ្ងៃរសៀលនេះបាន ល្មាចនេះបាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយដូច្នេះ ដើម្បីឲ្យប្រាកដថា ការស្តាប់សក្ខីកម្មរបស់ព្រះតេជព្រះគុណ ឯម ភឿង ហ្នឹង បានចប់សព្វគ្រប់នៅក្នុងថ្ងៃនេះ អង្គជំនុំជម្រះសម្រេចថា នៅរសៀលនេះ ចាប់ផ្តើមធ្វើសវនាការចាប់ផ្តើមពី ម៉ោងមួយម្ភៃនាទី ដើម្បីបង្កើនល្បឿន ឲ្យជៀសវាងការប៉ះពាល់ទៅពេលវេលាដែលអង្គជំនុំជម្រះបានបែងចែកឲ្យភាគីការពារក្តី។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយនិងម្ភៃនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ សូមភាគី និងមន្ត្រីដែលគាំទ្រដល់កិច្ចដំណើរការសវនាការជ្រាប។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីអ្នកជំនាញ ដល់ព្រះតេជព្រះគុណ ឯម ភឿង នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ ហើយនិងឲ្យនិមន្តព្រះអង្គមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយនិងម្ភៃនាទី។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ ត្រឡប់មកចូលបន្ទប់ -- ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយនិងម្ភៃនាទី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣២ នាទី ដល់ម៉ោង ១៣:២២ នាទី)*

[១៣:២២:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីព្រះតេជព្រះគុណ ឯម ភឿង។ សូមអញ្ជើញ!

**លោក វ៉ែន ពៅ៖**

សូមអរគុណលោកប្រធាន។ ជាបឋមខ្ញុំករុណាសូមថ្វាយបង្គំព្រះតេជព្រះគុណ ឯម អឿង និងសូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ខ្ញុំបាទឈ្មោះ វ៉ែន ពៅ ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំនឹងសួរសំណួរដល់ព្រះអង្គនូវសំណួរមួយចំនួន បន្ទាប់ពីខ្ញុំសួរចប់ គឺសហភាតាខ្ញុំ គឺលោកស្រី ម៉ារី គាត់នឹងមានសំណួរខ្លះទៀតដែលត្រូវសួរព្រះអង្គ។ សំណួររបស់ខ្ញុំករុណាដែលនឹងសួរព្រះអង្គនៅពេលនេះ ភាគច្រើនគឺពាក់ព័ន្ធទៅនឹងអ្វីដែលព្រះអង្គបានឆ្លើយទៅនឹងកំណត់ហេតុស្ដាប់ចម្លើយដែលព្រះអង្គបានធ្វើជាមួយនឹងសហ -- ជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត គឺដែលមានលេខឯកសារ E3/5133។

លោកប្រធាន ខ្ញុំសូមអនុញ្ញាតអានលេខ -- ដកស្រង់ពីឯកសារនេះ គឺដែលមានលខ ERN ជាភាសាខ្មែរគឺលេខ 00165260, ERN ជាភាសាអង់គ្លេស 00223199, ERN ជាភាសាបារាំង 00702334។

[១៣:២៤:៤៣]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** សំណួរនៅពេលនោះ គឺសួរព្រះអង្គពាក់ព័ន្ធនឹងមុន ១៧ មេសា ៧៥ បន្តិច គឺនៅក្នុងនោះសំណួរសួរថា៖ “តើព្រះតេជព្រះគុណមានដឹងថាព្រះសង្ឃដែលនៅគង់នៅក្នុងវត្តនោះមានប៉ុន្មានដែរ? គឺសំដៅលើវត្តសំពៅមាសដែលព្រះអង្គគង់នៅ។” នៅពេលនោះ ព្រះអង្គបានឆ្លើយថា៖ “មិនបានដឹងចំនួនពិតប្រាកដទេ តែដឹងថាមានចំនួនច្រើន ព្រោះមានព្រះសង្ឃដែលមក -- ដែលរត់មកពីតាមខេត្តនានាស្នាក់នៅច្រើនផង”។ សំណួររបស់ខ្ញុំករុណាដែលសួរព្រះអង្គថា តើព្រះអង្គបានដឹង ឬមានអ្នកណាទូលព្រះអង្គទេថា តើហេតុអ្វីបានជាមានព្រះសង្ឃមកតាមខេត្តផ្សេងៗមកស្នាក់នៅវត្តដែលព្រះអង្គកំពុងគង់នៅនោះ?

**ព្រះតេជព្រះគុណ ឯម អឿង៖**

**ឆ៖** ចម្រើនពរ ព្រះសង្ឃតាមខេត្តនានា លោកនិមន្តមករាជធានីដោយពេលនោះមានការជិះជាន់លោកច្រើនពេក ដល់លោកនៅមិនបាន លោករត់មករាជធានី ពរ។

[១៣:២៥:៥៨]

**ស៖** សូមអរព្រះគុណ។ តើព្រះអង្គអាចបញ្ជាក់បានទេ ព្រះអង្គមានដីកាថា មានការជិះជាន់ច្រើន តើខាងណា ទ័ពខាងណា ទាហានខាងណាជាអ្នកជិះជាន់នោះ?

**ឆ៖** សូមចម្រើនពរ ពេលនោះមិនទាន់រំដោះបានទេ ពេលនោះមិនទេណ៎ា មិនទាន់រំដោះទេណ៎ា។ ខាងនេះហៅថា ខ្មែររំដោះកាលនោះ នៅសាធារណរដ្ឋនៅឡើយ នៅព្រះសង្ឃភៀសមកនៅភ្នំពេញ ពរ។ ទម្លាក់គ្រាប់បែកពីអាមេរិកាំង និងពួកតំបន់រំដោះចេះតែធ្វើបាបលោក លោកនៅមិនកើតបានរត់មករាជធានីភ្នំពេញ។

**ស៖** អ៊ីចឹងបានន័យថា ព្រះសង្ឃមួយចំនួនដែលរត់ចូលមកទីក្រុងភ្នំពេញមុន ១៧ មេសា ៧៥ ភ្លាមៗនោះ គឺដោយសារតែសង្គ្រាម មែនទេព្រះអង្គ?

**ឆ៖** លោកមានប្រសាសន៍អំមិញត្រូវហើយ ដោយសារសង្គ្រាម បានលោករត់ចូលភ្នំពេញព្រោះនៅស្រែមិនសុខ។

**ស៖** សូមអរព្រះគុណ។ សំណួររបស់ខ្ញុំករុណាជាបន្តទៀតនេះគឺចង់បញ្ជាក់ឱ្យច្បាស់ថែមទៀតថា តើក្រៅពីព្រះអង្គបានឃើញមានព្រះសង្ឃមួយចំនួនដែលភៀសខ្លួនចូលមកតាមវត្តទីអារាមនានានៅទីក្រុងភ្នំពេញនោះថា តើព្រះអង្គមានបានឃើញ ឬមានអ្នកណាទូលព្រះអង្គថាមានព្រះសង្ឃត្រូវរបួស ឬក៏មានសុគតដោយសារការប្រយុទ្ធគ្នា ឬក៏ដោយសារសង្គ្រាមនោះទេ នៅពេលនោះ?

**ឆ៖** រឿងសុគត រឿងរបួសអីហ្នឹង មិនបានដឹងទេ ពរ ពេលនោះ។

[១៣:២៨:០៥]

**ស៖** សូមអរព្រះគុណ។ សំណួរខ្ញុំករុណាជាបន្តទៀត ចង់សួរព្រះអង្គពាក់ព័ន្ធនឹងថ្ងៃជម្លៀស ១៧ មេសា ១៩៧៥។ ព្រះអង្គបានមានដីកាពីព្រឹកមិញរួចហើយថា នៅយប់ថ្ងៃ១៧ មេសា ១៩៧៥ ម៉ោងដប់យប់ ពួកទាហានខ្មែរក្រហមបានមកធ្វើការគំរាមកំហែងសម្លុតព្រះសង្ឃឱ្យចេញពីទីវត្តនោះ។ សំណួររបស់ខ្ញុំករុណាសួរថា តើនៅយប់នោះព្រះអង្គបានឃើញ ឬមានអ្នកណាប្រាប់ព្រះអង្គថា មានព្រះសង្ឃនៅក្នុងវត្ត ដែលព្រះអង្គគង់នៅនោះត្រូវបានផ្សឹកភ្លាមៗទេនៅយប់ថ្ងៃជម្លៀសនោះបាទ?

**ឆ៖** ចម្រើនពរ ពេល១៧ មេសា មិនបានដឹងទេពរ នៅភ្នំពេញហ្នឹងមិនបានដឹងទេ ព្រោះកំពុងតែភ័យភិតគ្រប់គ្នា ភ័យភិតៗ ពរ ព្រោះមិនដឹង ពួកខ្មែរក្រហមចូលទៅហ្នឹង មិនដឹងជាសុខ ឬមិនសុខអត់ទាន់ដឹងទេពេលហ្នឹង អត់ទាន់ដឹងទេៗ។ ដល់តែពេលម៉ោងដប់បានគេថា៖ "អ្ហែ! ព្រះសង្ឃត្រូវតែចេញ។ ប្រជាជនទាំងអស់ចេញពីរាជធានីៗ អត់នៅទេ។ ៧ថ្ងៃ អត់យកអីទេ យកតែយាមមួយ ហើយ

ឆត្រមួយបានហើយ ហើយចីពរមួយបានហើយ"។ ទាំងគេទាំងអាត្មា ទូទៅទាំងអស់គ្នាអ៊ីចឹង ក៏ចេញមក ថ្ងៃ១៧ មេសា ហ្នឹង ម៉ោងដប់យប់ហ្នឹងមក។

**ស៖** សូមអរគុណព្រះអង្គ។ សំណួររបស់ខ្ញុំករុណាជាបន្តទៀតគឺ ពាក់ព័ន្ធនឹងអ្វីដែលព្រះអង្គបានមានដីការួចហើយ កាលពីព្រឹកមិញផងដែរថា ការជម្លៀសចេញនេះគឺក្នុងរយៈពេល១ខែជាងបានព្រះអង្គត្រូវបានជម្លៀសពីភ្នំពេញរហូតដល់វត្តអង្គរកា នៅស្រុកត្រាំកក់។ ខ្ញុំករុណាចង់សួរព្រះអង្គថា ក្នុងរយៈពេល១ខែជាងនៃការធ្វើដំណើរជម្លៀសចេញនេះ តើព្រះអង្គមានបានឃើញ ឬមានអ្នកណាទូលព្រះអង្គថា មានគេចាប់ផ្សឹកព្រះសង្ឃ ឬក៏ព្រះសង្ឃត្រូវរបួស ឬអត់អាហារអីតាមផ្លូវដែរទេបាទ?

[១៣:៣០:១៥]

**ឆ៖** ពរ មិនបានដឹងទេ រឿងហ្នឹងមិនបានដឹងទេ ពរ ព្រោះរៀងៗខ្លួន រៀងខ្លួន។ អាត្មាមានសិស្សមួយក្រុមអ៊ីចឹងទៅ គេមានសិស្សគេមួយក្រុមអ៊ីចឹងទៅពរ។ រៀងខ្លួន មិនបានដឹងថាអ្នកណាយ៉ាងម៉េច អត់ដឹងទេៗ ពេលហ្នឹង ពរ ភ័យរៀងខ្លួន ពរ។

**ស៖** សូមអរគុណព្រះអង្គ។ ករុណាចង់បញ្ជាក់សំណួរមួយទៀតដែរ ពាក់ព័ន្ធនឹងពីព្រឹកមិញដែរ ព្រះអង្គបានមានដីកាថា នៅថ្ងៃ១៧ មេសា ៧៥ នោះ ពួកខ្មែរក្រហមបានឃាត់ទុកព្រះសង្ឃប្រហែល ២០អង្គ។ នៅក្នុងនោះព្រះអង្គបានមានដីកាថា ដូចឮមានព្រះនាមសម្តេចសង្ឃ ហួត តាត។ តើព្រះអង្គចាំបានទេ តើនៅពេលនោះសម្តេចសង្ឃ ហួត តាត លោកមានឋានៈជាអ្វីដែរនៅពេលនោះ?

**ឆ៖** ចម្រើនពរ ពេលនោះសម្តេចសង្ឃរាជ លោកជាងារជា "សម្តេចសង្ឃរាជ ហួត តាត" សង្ឃរាជ ពរ។

**ស៖** សូមៗអរគុណ ព្រះអង្គ។

**ឆ៖** ពរ។

[១៣:៣១:២៥]

**ស៖** ករុណាមានសំណួរមួយចំនួនទេ គឺពាក់ព័ន្ធទៅនឹងការដ្ឋានត្រាំកក់គឺសំដៅលើវត្តអង្គរការ។ តាមៗពិតព្រះអង្គមានដីកាច្រើនហើយ ដែលសហព្រះរាជអាជ្ញាបានសួរពាក់ព័ន្ធបញ្ហានេះ។ ប៉ុន្តែមានចំណុចមួយចំនួនដែលខ្ញុំករុណាត្រូវសួរបញ្ជាក់បន្ថែមឡើងវិញទៀត គឺព្រះអង្គបានមានដីកាហើយថា អស់ព្រះសង្ឃចាប់ពីដើមឆ្នាំ១៩៧៦។ តើៗចម្លើយនេះ ព្រះអង្គបានន័យថាអស់ព្រះសង្ឃនៅ -- ព្រះសង្ឃទូទាំងប្រទេសនៅក្នុងរបបខ្មែរក្រហម គឺសំដៅតែនៅអស់ព្រះសង្ឃនៅវត្តអង្គរកានោះទេ?

**ឆ៖** តាមសន្និដ្ឋាននេះ ថាប្រហែលជាអស់ហើយមើលទៅ ព្រោះនៅកន្លែងនុ៎ងអស់មានព្រះសង្ឃហើយ អស់មានហើយ ពរ។

**ស៖** សូមអរគុណព្រះអង្គ។ ពាក់ព័ន្ធនឹងចំណុចមួយទៀត គឺនៅឆ្នាំ១៩៧៥ ដល់ ៧៦ ដែលព្រះអង្គថា អស់ព្រះសង្ឃបានន័យថានៅពេលមានព្រះសង្ឃ។ ខ្ញុំករុណាចង់សួរថា នៅពេលនុង់ តើបើសិនបើមានអ្នកស្លាប់ តើអ្នកភូមិអាចមានសិទ្ធិ ឬអង្គការគេអនុញ្ញាតឲ្យគេមកនិមន្តព្រះសង្ឃទៅឲ្យធ្វើបុណ្យធ្វើទានឲ្យអីទេបាទ?

[១៣:៣៣:០៣]

**ឆ៖** ចម្រើនពរ បើៗមុន៧៦ ប្រសិនបើមានអាចទៅបានពរ។ ដល់៧៦ឡើងទៅ មិនមានទេអត់មានព្រះសង្ឃនិមន្តទៅធ្វើបុណ្យកើតទៀតទេ។ មានតែឧបាសកនាយអាយយកទៅបូជា យកទៅកប់នេះពរ។ ព្រោះអាត្មាសឹកហើយហ្នឹង អាត្មាបានធ្វើជាអាចារ្យនេះឲ្យទៅកប់ខ្មោចកប់អីហូរហែដែរហ្នឹងកាលហ្នឹងពរ។

**ស៖** ចុះនៅវត្តអង្គរកានោះ តើអង្គការ ឬក៏មេដឹកនាំខ្មែរក្រហមប្រចាំតំបន់នោះមានអនុញ្ញាតឲ្យមានពិធីបុណ្យផ្សេងៗអីទេនៅក្នុងវត្តអង្គរកានៅសម័យនោះ?

**ឆ៖** មិនមានទេ ចម្រើនពរ អត់មានទេ។

**ស៖** អរព្រះគុណ។ នេះៗជាសំណួរចុងក្រោយរបស់ខ្ញុំករុណា។ ហើយសំណួរនេះខ្ញុំករុណាចង់សួរថាព្រះអង្គធ្លាប់គង់នៅវត្តអង្គរកាជាមួយព្រះសង្ឃមួយចំនួន ដែលៗគេប្រមូលមកពីខេត្តតាកែវ។ តើនៅបន្ទាប់ពី១៧ -- បន្ទាប់ពីថ្ងៃដួលរលំនូវរបបខ្មែរក្រហមទៅ តើព្រះអង្គមានបានជួបព្រះសង្ឃអស់ទាំងនោះទេ ដែលៗធ្លាប់រស់នៅវត្តអង្គរកាជាមួយព្រះអង្គដែរ? តើមាននៅអ្នកនៅរស់រានមានជីវិត ឬក៏អ្នកបានជួបប៉ុន្មានអ្នកដែរព្រះអង្គ?

[១៣:៣៤:៣៦]

**ឆ៖** ដូចមិនបានឃើញ មើលមិនបានឃើញមានទេ។ អាត្មាចុះឡើងទៅហ្នឹងទៅ មិនឃើញមានអត់ឃើញមានអ្នកណានៅ សួរគេ ថា “អត់មានទេ លោកគ្រូអើយបាត់អស់ហើយ”។

**លោក វ៉ែន ពៅ៖**

សូមអរគុណព្រះអង្គ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

អរគុណលោកប្រធាន។

ជម្រាបសួរព្រះតេជព្រះគុណ! ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាមេធាវីរបស់ក្រុមដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរខ្លីៗមួយចំនួនដើម្បីចោទសួរទៅព្រះតេជព្រះគុណនៅវសៀលនេះ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សំណួរទី១ របស់ខ្ញុំ គឺខ្ញុំចង់ដឹងថា តើព្រះតេជព្រះគុណ<មានបទពិសោធន៍>យ៉ាងម៉េច <ខ្លះ>នៅក្រោមរបបខ្មែរក្រហមនោះ ដោយមិនប្រណិប័តន៍សាសនា តើព្រះតេជព្រះគុណមាន -- ទទួលអារម្មណ៍យ៉ាងម៉េចដែរ ដែលមិនបានប្រណិប័តន៍សាសនាព្រះពុទ្ធនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនេះ?

**ព្រះតេជព្រះគុណ ឯម អឿង៖**

**ឆ៖** ចម្រើនពរ ដូចគេដូចឯងអ៊ីចឹងពរ ព្រោះទៅជាប្រជារាស្ត្រហើយ នៅក្រោមបង្គាប់របស់ផងគេ គេបញ្ជាតាមគេបញ្ជា ធ្វើអីធ្វើនឹងគេ។ ប្ដេជ្ញាថាសុំជីវិតរស់នៅ ឲ្យៗតែរស់នៅ ស្អីក៏ធ្វើដែរ ជំនាន់៣ឆ្នាំ៨ខែហ្នឹងពរ។

**ស៖** ខ្ញុំករុណាសូមអរគុណ។ ព្រះតេជព្រះគុណបានឆ្លើយកាលពីព្រឹកមិញទៅសហព្រះរាជអាជ្ញាថា ព្រះតេជព្រះគុណនៅតែបន្តសូត្រធម៌ ដោយលួចសូត្រធម៌។ តើព្រះតេជព្រះគុណបញ្ជាក់ថាព្រះតេជព្រះគុណឆ្លើយយ៉ាងដូច្នេះទេកាលពីព្រឹកមិញ?

**ឆ៖** ចម្រើនពរ ឆ្លើយ លួចសូត្រយប់ៗស្ងាត់ៗ។

[១៣:៣៧:០២]

**ស៖** ព្រះតេជព្រះគុណអាចផ្ដល់ព័ត៌មាន ឬក៏ពន្យល់បន្ថែមទាក់ទងទៅនឹងការលួចសូត្រធម៌ពេលយប់នេះដែរឬទេ? <តើមាននរណាខ្លះចូលរួម?> ខ្ញុំករុណាចង់សួរថាតើលួចសូត្រធម៌ញឹកញាប់ប៉ុនណាដែរ? ហើយសូត្រធម៌<ហ្នឹងត្រូវបានរៀបចំឡើងយ៉ាងដូចម្ដេចដែរ? តើព្រះអង្គអាចរៀបរាប់លម្អិតបានដែរ ឬទេ>?

**ឆ៖** ចម្រើនពរ អាត្មាធ្លាប់ហាត់រៀនសូត្រមក យើងគ្រាន់តែនឹកឃើញគុណព្រះពុទ្ធ គុណព្រះធម៌ គុណព្រះសង្ឃតែប៉ុណ្ណឹងទេ តែមិនបានសូត្រច្រើនទេពរៗ។ ខ្លាចគេឮដែរហ្នឹង លួចខ្សឹបៗ ហើយដេកលក់ទៅហើយ។ មុនៗដំណេកគឺសូត្រជានិច្ចរាល់ថ្ងៃអ៊ីចឹង ប្រាប់ត្រង់ហើយអាហ្នឹង។

**ស៖** ខ្ញុំករុណាសូមអរគុណ។ ខ្ញុំចង់ដឹងថា តើព្រះតេជព្រះគុណមានប្រពន្ធហើយ ឬនៅ<ក្នុង

របបកម្ពុជាប្រជាធិបតេយ្យ គឺកាន់តែជាក់ច្បាស់នោះ គឺ>ចន្លោះឆ្នាំ១៩៧៦ ដល់ ១៩៧៩?

**ផ៖** ចម្រើនពរ មិនដែលមានទេ តាំងពីដើមមករហូតដល់ថ្ងៃនេះ ត្រឹមថ្ងៃហ្នឹងអត់ដែលមានទេ ម្នាក់ឯងរហូត អត់ដែលមានប្រពន្ធកូនអីទេ។

[១៣:៣៨:៣៩]

**ស៖** ខ្ញុំករុណាសូមអរគុណ។ ខ្ញុំសូមដកស្រង់ផ្នែកមួយនៃកិច្ចសម្ភាសន៍របស់ព្រះតេជព្រះគុណ <ជាមួយ>មជ្ឈមណ្ឌលឯកសារកម្ពុជា <កាលពីខែមករា ឆ្នាំ២០០៥> ជាភាសាបារាំង <ត្រង់ទំព័រ ៥> គឺ ERN 00655661, ជាភាសាអង់គ្លេសគឺ 00350101, ERN ជាភាសាខ្មែរគឺ 00088474។ សំណួរដែលខ្ញុំទើបតែសួរអំម្បាញ់មិញនេះ គឺត្រូវបានៗចោទសួរសំណួរនេះទៅព្រះតេជព្រះគុណហើយ នៅឆ្នាំ២០០៥។ ខ្ញុំករុណាសូមអានផ្នែកនេះ៖ "សំណួរ៖ ក្រោមរបបខ្មែរក្រហមបន្ទាប់ពីព្រះតេជព្រះគុណបានសឹក តើខ្មែរក្រហមបានបង្ខំព្រះអង្គឲ្យរៀបការដែរឬទេ? ចម្លើយ៖ បាទ ប៉ុន្តែខ្ញុំបានជំទាស់។ សំណួរ៖ តើការជំទាស់របស់ព្រះតេជព្រះគុណធ្វើឲ្យខ្មែរក្រហម<>ខឹងសម្បាដែរឬទេ? ចម្លើយ៖ អាត្មានឹងរៀបរាប់ប្រវត្តិរបស់អាត្មា ប្រជាអ្នកនៅខាងនោះ អ្នកនៅភូមិស្រុកនោះចាស់ៗ នោះដែលស្គាល់ខ្ញុំ តាំងពីតូចមកនោះ ប្រាប់ខ្មែរក្រហមថា កុំឲ្យធ្វើបាបខ្ញុំ។ ពួកគេទាំងអស់នោះ ស្គាល់ខ្ញុំតាំងពីខ្ញុំនៅតូចៗ ហើយម្យ៉ាងទៀត ដោយសារជារឿងមួយដែលយើងមិនត្រូវនិយាយ ព្រោះថាជាជំនឿសាសនា នៅពេលដែលគេបង្ខំឲ្យខ្ញុំរៀបការ ខ្ញុំចម្លើយថា ខ្ញុំមិនត្រូវការស្រីទេ ពីព្រោះថាខ្ញុំមានម្ហូបអាហារ ហើយមានអ្នកថែរក្សាខ្ញុំ បើខ្ញុំឈឺ ខ្ញុំទៅ<>មន្ទីរពេទ្យ។ អ៊ីចឹងខ្ញុំមិនត្រូវការ<ធ្វើឲ្យជីវិតខ្ញុំកាន់តែលំបាកនោះទេ។ មិនចាំបាច់ធ្វើឲ្យជីវិតកាន់តែលំបាក ហើយខ្ញុំពុំមានពេលវេលាដើម្បីមើលថែចិញ្ចឹមប្រពន្ធនោះទេ ពីព្រោះខ្ញុំត្រូវធ្វើការងាររាល់ថ្ងៃ>។ ដល់អ៊ីចឹងគេជឿខ្ញុំហើយ គេក៏ឈប់ធ្វើទុក្ខបុកម្នេញខ្ញុំទៀតទៅ"។ អ៊ីចឹងខ្ញុំសួរព្រះតេជព្រះគុណថា តើព្រះតេជព្រះគុណបានមានដីកាយ៉ាងដូច្នេះដែរឬទេ?

**ផ៖** ចម្រើនពរ និយាយមែនៗពរ។ គេបង្ខំដែរ តែអាត្មាមិនព្រមយកគ្រួសារ អត់យកទេ គួបផ្សំនឹងចាស់ទុំគាត់ជួយ គាត់ប្រាប់ផង ហើយនិងបុណ្យកុសលផងពរ។

[១៣:៤១:១៥]

**ស៖** តើព្រះតេជព្រះគុណអាចជម្រាបជូនតុលាការ<ដែរ>ឬទេថា អ្នកណាអ្នកបង្ខំព្រះតេជព្រះគុណឲ្យរៀបការនៅពេលនោះ?

**ផ៖** លោកប្រធានភូមិ។

**ស៖** តើគាត់មានបានពន្យល់ព្រះតេជព្រះគុណថា ពីមូលហេតុដែលត្រូវតែរៀបការដែរឬទេ? អ៊ីចឹងខ្ញុំសូមសួរម្ដងទៀត តើគេ -- លោកប្រធានភូមិនោះមានបានពន្យល់ព្រះតេជព្រះគុណថា អំពីមូលហេតុដែលត្រូវរៀបការដែរឬទេ?

**ឆ៖** គេអត់មាននិយាយអីទេ គេគ្រាន់តែថា "លោកពូចាស់ហើយ ល្មមយកគ្រួសារនឹងគេទៅហើយ"។ អាត្មាថា "មិនបាច់ទេ មិនបាច់យកទេ។ ព្រោះអង្គការមានពេទ្យហើយ អាហារទិព្វ បាយទិព្វ ទិព្វទាំងអស់ ជំងឺក៏ទិព្វដែរ ឈឺត្រូវចូលពេទ្យ មិនបាច់មានគ្រួសារអីថែទាំទៀតទេ មិនបាច់ទេ ខ្លួនឯងដោះស្រាយខ្លួនឯងទៅ ពេទ្យគេមានហើយ"។ ប៉ុណ្ណឹងទៅគេក៏លែងថាអីទៅ ទល់តែបែក៧៥ទៅ។

**ស៖** តើសំណើហ្នឹង គឺសំណើដោយទទូចតែម្ដង ឬក្រោយពីពេលដែលព្រះតេជព្រះគុណប្រាប់ថា ព្រះតេជព្រះគុណមិនចង់រៀបការហើយ ដូចនៅក្នុងចម្លើយៗរបស់ព្រះតេជព្រះគុណដែលបានឆ្លើយនេះថា ព្រះតេជព្រះគុណថា មិនចង់ឲ្យមានបញ្ហាអីជំពាក់ជំពិនអីជាមួយនឹងស្រីទេ។ ពេលហ្នឹងមក គេឈប់រករឿងព្រះតេជព្រះគុណ ឬយ៉ាងម៉េច?

**ឆ៖** ពរ គេអត់ដែលថា អីទៀតទេ។ ឈប់រករឿងតែម្ដង ចាប់ពីពេលហ្នឹងរហូតទល់នឹងចប់ទៅ។

[១៣:៤៣:១៥]

**ស៖** ខ្ញុំករុណាសូមអរគុណ។ តើនៅពេលនោះ នៅសម័យនោះ មានព្រះសង្ឃផ្សេងទៀតដែលត្រូវបានបង្ខំឲ្យផ្សឹក -- ឲ្យសឹក ហើយបង្ខំឲ្យរៀបការដែរឬទេ?

**ឆ៖** មាន ពរ មិត្តភក្តិអាត្មាម្នាក់បាន គេបង្ខំឲ្យរៀបការទាល់តែបាន ពរ។ ព្រោះបានលក្ខន្តិកៈជាមួយគ្នាថា បើរំដោះប្រទេសថ្ងៃណាបានសុខសាន្ត យើងបួសវិញទាំងអស់គ្នា ក៏ប៉ុន្តែគាត់ចាញ់បោកគេ គេឲ្យរៀបការ ហើយរៀបការនឹងគេទៅពរ។

**ស៖** តើហេតុអ្វី -- តាមប្រាប់ព្រះតេជព្រះគុណនោះ គាត់បានសុខចិត្តរៀបការជាមួយគេ ហើយព្រះតេជព្រះគុណថា មិនព្រមទេ។ ហើយព្រះតេជព្រះគុណថា រឿងរ៉ាវរបស់ព្រះតេជព្រះគុណ ជារឿងពិសេសមួយ។ អ៊ីចឹងខ្ញុំករុណាចង់សួរព្រះតេជព្រះគុណថា តើហេតុអីក៏ព្រះតេជព្រះគុណថា រឿងរបស់ព្រះតេជព្រះគុណនេះ ជារឿងពិសេសមួយខុសគេ?

**ឆ៖** ពរ រឿងប្លែកជាងគេដោយអាត្មាមិនបានយកគ្រួសារអី គេអត់ថាអីដែរ ពរ។ ក្រៅពីអាត្មាគេបង្ខំទាំងអស់ ប្ដេជ្ញាគ្រាប់គ្នា ១០គូ ២០គូ ៥០គូអ៊ីចឹងទៅ តែអាត្មាមួយអាត្មាបានប្រកែកដាច់អហង្ការ

រហូតទល់នឹងនា៧៥ មកអត់មានបញ្ហាអីតទៅទៀតទេក៏ចប់ទៅ។

[១៣:៤៥:០៩]

**សៈ** នៅពេលដែលយើងអានចម្លើយរបស់លោកស្រី -- ព្រះតេជព្រះគុណទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រះតេជព្រះគុណមានដីកាថា មានចាស់ទុំ<នៅក្នុងភូមិ>ស្គាល់ព្រះតេជព្រះគុណជាច្រើនតាំងពីតូច។ អ៊ីចឹងសំណួររបស់ខ្ញុំករុណា ចង់សួរថា តើដោយសារតែអ្នកចាស់ទុំក្នុងភូមិស្គាល់ព្រះតេជព្រះគុណតាំងពីតូចទន្ទឹងហើយ បានជាគេមិនរករឿងព្រះអង្គ នៅពេលដែលព្រះអង្គឆ្លើយថា មានដីកាថា មិនចង់មានប្រពន្ធ?

**ឆៈ** ចម្រើនពរ ព្រោះមូលដ្ឋានៗ ហ្នឹងគាត់ជួយតែម្ដងមូលដ្ឋាន ព្រោះអាត្មានៅបួសតាំងពីក្មេងតូចមកហ្នឹង គាត់ស្គាល់ ស្គាល់តាំងពីតូចមកអ៊ីចឹងទៅ ដល់ពេលហ្នឹងហើយ គាត់បានជួបថា គាត់ប្រាប់កម្មាភិបាលគេហ្នឹង ថាមិនបាច់ធ្វើបាបគាត់ទេ ព្រោះខ្ញុំស្គាល់គាត់ពីក្មេង តាំងពីតូចៗមកនោះ។ ធ្វើអីគាត់នៅបួសរហូតហ្នឹង ទាល់គ្នាជំនាន់ហ្នឹង បានសឹកហ្នឹង មិនដែលធ្វើទាហាន ធ្វើប៉ូលិសនឹងគេទេ។ ចម្រើនពរ ប៉ុណ្ណឹងទេ។

[១៣:៤៦:២៣]

**សៈ** ខ្ញុំករុណាសូមអរគុណ។ ព្រះតេជព្រះគុណបានឆ្លើយថា មានការរៀបការជាក្រុម១០ ទៅ២០គូ។ ខ្ញុំករុណាចង់ដឹងថា តើព្រះតេជព្រះគុណបានចូលមានវត្តមាននៅក្នុងពិធីការនេះដោយផ្ទាល់ដែរឬទេ?

**ឆៈ** ពរ បានចូល ពរ។ អាត្មាចូលទៅ គេហៅអាត្មាឲ្យជយន្តោអ្នករៀបចំការទាំងអស់ ពរ។ ការរោងបាយ ទៅ គេហៅអាត្មាទៅឲ្យទៀត ទៅជាអ្នកធ្វើអាចារ្យទៅ។ សូត្រធម៌ឲ្យអ្នកការថ្មីទាំងអស់ ពរ សូត្រធម៌ឲ្យគេ ព្រោះគេស្គាល់អាត្មាថាចេះ ជាអ្នកចេះធម៌អាថ៌នោះ។

**សៈ** បើអ៊ីចឹង ព្រះតេជព្រះគុណអាចកំណត់ពេលវេលាបានទេ ថាពេលដែលព្រះតេជព្រះគុណសូត្រធម៌ឲ្យការគេនោះ នៅឆ្នាំណាដែរ? គឺថាអម្បាញ់មិញ ព្រះតេជព្រះគុណថាដល់ឆ្នាំ១៩៧៦នោះលែងមាន<ការសូត្រធម៌>ទៀតហើយ។ អ៊ីចឹងខ្ញុំករុណាចង់សួរថា តើពេលដែលព្រះតេជព្រះគុណសូត្រធម៌ឲ្យពិធីការគេនោះ មុនឆ្នាំ៧៦ ឬក៏ក្រោយឆ្នាំ៧៦?

**ឆៈ** ជំនាន់ ប៉ុល ពត ពរ ប្ដេជ្ញា។ អាត្មាសឹកហើយពរ។ ៧៧, ៧៨ ប្ដេជ្ញា ពរ។ អត់មានលោកទេ សុទ្ធតែបាសកទាំងអស់ ប៉ុន្តែគេស្គាល់អាត្មាថា អាត្មាអ្នកបួស ធ្លាប់ចេះធម៌ គេហៅទៅជួយគេ

ប្រសិទ្ធិពរឲ្យអ្នកប្ដេជ្ញាថ្មីៗទាំងអស់នោះ។

[១៣:៤៨:១៧]

**ស៖** អ៊ីចឹង ដើម្បីឲ្យច្បាស់លាស់នោះ គឺថានៅឆ្នាំ១៩៧៧ និង៧៨នោះ នៅក្រោយពេលដែលព្រះតេជព្រះគុណត្រូវបានផ្សឹកហើយនោះ គេបានសុំឲ្យព្រះតេជព្រះគុណសូត្រធម៌ក្នុងពិធីការទាំងអស់នេះ <ខ្ញុំចង់ដឹងថា តើនរណាសុំឲ្យព្រះតេជព្រះគុណសូត្រធម៌ហ្នឹង?> តើខ្ញុំយល់នេះ ត្រឹមត្រូវដែរឬទេព្រះតេជព្រះគុណ?

**ឆ៖** ពរ ត្រឹមត្រូវហើយ ពរ ព្រោះកម្មាភិបាលគេស្គាល់អាត្មា ហើយគេហៅទៅ។

**ស៖** ព្រះតេជព្រះគុណអាចឆ្លើយសង្ខេបបានទេ តើពិធីរៀបការទាំងអស់នេះ ប្រព្រឹត្តទៅនៅពេលណា? នៅពេលថ្ងៃ? នៅពេលល្ងាច ឬក៏ពេលយប់ ហើយឬក៏ប្រែប្រួលទេ? ហើយចំនួនគូនោះ មានប៉ុន្មានគូដែរ? ហើយចំនួននោះ ក៏ប្រែប្រួលដែរឬក៏យ៉ាងណា? ហើយអ្នកណា<ធ្វើជាអធិបតីក្នុង>ពិធីរៀបការទាំងអស់នេះ ព្រះតេជព្រះគុណ? នេះជាសំណួរចុងក្រោយរបស់ខ្ញុំ។

**ឆ៖** ពរ នៅភូមិអាត្មាហ្នឹង មានពិធីតែម្ដងទេ ពរនៅរោងបាយ។ ពេលយប់ពរ ពេលយប់រៀបចំប្ដេជ្ញានៅពេលយប់ ប្រហែល៣០គូឡើងទៅពរ មិនប្រាកដទេ មិនចាំ ប្រហែលប៉ុណ្ណឹង។ នៅនឹងរោងបាយតែម្ដង ហូបបាយហើយ គេរៀបចំពិធីហ្នឹងតែម្ដង ប្ដេជ្ញា។

[១៣:៥០:០៥]

**ស៖** ខ្ញុំករុណាសូមអរគុណ។ ខ្ញុំសួរថា តើព្រះតេជព្រះគុណមានចាំថា អ្នកណា<ធ្វើជាអធិបតីភាពក្នុង>ពិធីរៀបការនុ៎ងដែរឬទេ?

**ឆ៖** នៅហ្នឹងភូមិ ប្រធានភូមិគេរៀបចំ ប្រធានភូមិរៀបចំ គណៈកម្មការភូមិគេទាំងអស់ហ្នឹងគេរៀបចំប្ដេជ្ញាហ្នឹង។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំករុណាសូមអរគុណព្រះតេជព្រះគុណ។ លោកប្រធាន ខ្ញុំអស់សំណួរសួរហើយលោកប្រធានសូមអរគុណច្រើន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយបន្តទៅនេះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីដែលចាប់ផ្ដើមពីក្រុមមេធាវីការពារក្ដីលោក នួន ជា មុនក្នុងការសួរដេញដោលសាក្សីព្រះតេជព្រះគុណ ឯម គឿង។ ហើយ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មុននឹងផ្តល់វេទិកាជូនទៅ សូមមន្ត្រីរដ្ឋបាលតុលាការបង្វែរសម្រួលនូវក្បាលមីក្រូហ្វូនឲ្យងាកមកខាងលិចវិញ។

បាទ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះព្រះតេជព្រះគុណ ឯម ភឿង។

[១៣:៥១:១៧]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សួន វិសាល៖**

សូមក្រាបថ្វាយបង្គំព្រះតេជព្រះគុណ ឯម ភឿង។ សូមគោរពតុលាការ! ខ្ញុំបាទឈ្មោះ សួន វិសាល ជាមេធាវីការពារក្តីឲ្យលោក នួន ជា។ ហើយបន្តទៅនេះ ខ្ញុំសូមសួរសំណួរព្រះតេជព្រះគុណមួយចំនួន។

**ស៖** សំណួរទី១ របស់ខ្ញុំករុណាគឺទាក់ទងទៅនឹងការគោរពបូជាសាសនា។ ព្រះតេជព្រះគុណទើបមានសង្ឃដីកាអម្បាញ់មិញថ្មីៗនេះថា ពេលមានពិធីការរៀបការជាមួយ -- បានន័យថាមានការរៀបការជាក្រុមអីច្រើនអ៊ីចឹងគឺ ប្រធានភូមិបានអញ្ជើញព្រះតេជព្រះគុណទៅធ្វើពិធីសូត្រធម៌នៅទីនោះ។ ខ្ញុំករុណាចង់សួរថា តើនៅពេលដែលពិធីផ្សេងៗទៀត ឧទាហរណ៍ ថាមានសាកសពស្លាប់ ឬក៏មានពិធីសែនព្រេនអីទៀត តើព្រះតេជព្រះគុណទៅធ្វើរបៀបនេះដែរឬទេបាទ?

[១៣:៥២:១០]

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** ចម្រើនពរ មិនមានទេៗ។ មានតែម្តងហ្នឹងគត់ ទល់នឹងបែក ៧៥។

**ស៖** បាទ សូមអរគុណព្រះតេជព្រះគុណ។ មុននឹងសំណួរហ្នឹងតិច ខ្ញុំករុណាបានឮព្រះតេជព្រះគុណមានសង្ឃដីកាថា នៅពេលពិធីមានសាកសពស្លាប់អីគឺ ប្រធានភូមិបានអញ្ជើញព្រះតេជព្រះគុណទៅធ្វើអាចារ្យ ហើយនៅក្នុងពិធីនោះ តើព្រះតេជព្រះគុណធ្វើពិធីយ៉ាងម៉េចដែរ?

**ឆ៖** ចម្រើនពរ នៅភូមិរបស់អាត្មាហ្នឹង ជំនាន់នោះ ជំនាន់ ប៉ុល ពត នោះ កាលណាមានសាកសពទៅគេឲ្យទៅជួយៗ តាមយើងចេះទេពរ ធ្វើអាចារ្យផង ធ្វើលោកផង ម្នាក់ឯងអ៊ីចឹងទៅ បូជាទៅ យកកប់ទៅពរ។ បានបូជា កប់ប៉ុណ្ណឹងទៅអត់អីច្រើនទេ។

**ស៖** សូមអរគុណ។ តើនៅក្នុងពិធីនោះព្រះតេជព្រះគុណរៀបចំរបៀបព្រះពុទ្ធសាសនា ឬក៏

តាមរបៀបអីផ្សេង?

**ឆ៖** ចម្រើនពរ--

**ប្រធានអង្គជំនុំ៖**

ព្រះតេជព្រះគុណ កុំអាលទាន់ឆ្លើយតប! មេធាវីផ្អាក សម្រាកបន្តិចសិន ដោយសារមានបញ្ហាម៉ាស៊ីនប្រតិចារឹក។

[១៣:៥៤:០០]

*(មានបញ្ហាបច្ចេកទេស)*

[១៣:៥៩:០១]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដោយសារបញ្ហាបច្ចេកទេសម៉ាស៊ីនប្រតិចារឹកមានបញ្ហា ហើយទំនងចំណាយពេលវេលាយូរ។ អ៊ីចឹងផ្អៀតឱកាសសម្រាក១៥នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងពីរដប់នាទី សូមអញ្ជើញចូលមកវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការ -- ដើរវិញ។

បាទ ឥឡូវបន្តទៀតអ៊ីចឹងលោកមេធាវី បាទ ឥឡូវមិនសម្រាកទេបន្តទៀត ព្រោះម៉ាស៊ីនដំណើរការវិញហើយ។

**សួរដោយលោក សួន វិសាល៖**

**ស៖** ព្រះតេជព្រះគុណ គឺខ្ញុំករុណាទើបតែនឹងសួរ ប៉ុន្តែព្រះតេជព្រះគុណគឺមានចាំសំណួររបស់ខ្ញុំព្រះករុណាដែរទេ មុននេះបន្តិច?

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតាំងសំណួរនោះសាជាថ្មីម្តងទៀតតែម្តងទៅ!

[១៤:០០:០៥]

**សួរដោយលោក សួន វិសាល៖**

**ស៖** ខ្ញុំករុណា សួរព្រះតេជព្រះគុណថា តើនៅពេលដែលព្រះតេជព្រះគុណមកធ្វើអាចារ្យនៅពិធីមួយៗ តើព្រះតេជព្រះគុណធ្វើពិធីនោះតាមរបៀបពុទ្ធសាសនា ឬក៏របៀបផ្សេងបាទ?

**ព្រះតេជព្រះគុណ ឯម អឿង៖**

**ឆ៖** ពរ ទៅៗហ្នឹងធ្វើតាមសាសនាពរ វាគ្មានអីទេ អត់មានអីទេពរ គ្រាន់តែទៅៗទៅ ណ៎

លោកគ្រូអាចារ្យទៅជួយហែយកសពតែប៉ុណ្ណឹង។ ហែទៅដុតទៅ យកកប់ទៅកប់ហើយ ប៉ុន្តែអត់មានអីទេ។ ហើយអនិច្ចា អនិច្ចំ អ្នកឯងប៉ុណ្ណឹងប៉ុនទេ អត់ទេ ហើយកប់ទៅពរ។ ចប់អស់ប៉ុណ្ណឹង។ ឧបកិច្ចទៅណា គ្មានបាយអុជធូបអីទេពរ។

**ស៖** ព្រះតេជព្រះគុណ មានសូត្រជយន្តោអីទេ ឬក៏យ៉ាងម៉េចទេនៅពេលនុង?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបព្រះតេជព្រះគុណ ចាំមើលក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យសញ្ញាភ្លើងក្រហមជាមុនសិន។

[១៤:០១:០៨]

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** ពរ សូត្រ ពរ។ នៅភូមិអាត្មាសូត្របាន មិនអីទេ គេឲ្យអាត្មាសូត្របាន ពរ។

**សួរដោយលោក សួន វិសាល៖**

**ស៖** អរគុណព្រះតេជព្រះគុណ ខ្ញុំករុណាសួរបន្តទៀត។ ថាតើធ្វើរបៀបហ្នឹង តើព្រះតេជព្រះគុណធ្វើរហូតដល់បែកឆ្នាំ១៩៧៩ ឬក៏ឈប់នៅពេលណាមួយ?

**ឆ៖** ៧៨ លែងៗមានហើយពរ អស់មានហើយៗ។

**ស៖** អរគុណ ព្រះតេជគុណ។ ខ្ញុំករុណាសួរសំណួរបន្ទាប់ទៀត។ នៅពេលមួយនោះ គឺថាព្រះតេជព្រះគុណបានមានបន្ទូលថា នៅពេលដែលមេភូមិឲ្យព្រះតេជព្រះគុណរៀបការ គឺព្រះតេជព្រះគុណត្រូវបានគេបង្ខំ។ ខ្ញុំករុណាចង់ដឹងថា តើគេបង្ខំព្រះតេជព្រះគុណតាមរបៀបណា? គេប្រើពាក្យសម្ដីរបៀបណា ឬក៏ចាប់ -- ចង់ចាប់ព្រះតេជព្រះគុណ ឬក៏ធ្វើបាបទុក្ខបុកម្នេញក្រុមគ្រួសារព្រះតេជព្រះគុណធ្វើយ៉ាងម៉េច ដែលព្រះតេជព្រះគុណ ចាត់ថាជាការបង្ខំនោះ?

**ឆ៖** ចម្រើនពរ ពាក្យនេះអត់ថាបង្ខំ អត់មានថាបង្ខំទេពរ។ បើប្រជាជនផ្សេងៗ អាហ្នឹងគេបង្ខំឲ្យ ព្រោះអត់មានស្គាល់គ្នាផង ហ្នឹងបង្ខំហើយ ពរ។ នារីមកពីនាយពីណាពីនោះ បុរសដើរដល់មកប្រកាសថា ប្ដេជ្ញា។ ឥឡូវអ្នកនេះនិងនាងនេះប្ដេជ្ញាគ្នាទៅណា ហ្នឹងហើយ ប៉ុន្តែមិនដែលស្គាល់គ្នាទេ។ អានេះចូលលក្ខណៈបង្ខំហើយពរ បង្ខំហើយអាហ្នឹង មិនដែលស្គាល់គ្នាផង អាហ្នឹងបង្ខំហើយអាហ្នឹងពរ។ តែអាត្មាអត់បានធ្វើអ៊ីចឹងទេ អាត្មាអត់មានបង្ខំគេទេ អត់បង្ខំទេ អាត្មាថាមិនយក ក៏គេអត់បង្ខំពរ។

[១៤:០៣:០៧]

**ស៖** នៅពេលដែលព្រះតេជ -- គេឲ្យព្រះតេជព្រះគុណរៀបការអ៊ីចឹង ព្រះតេជព្រះគុណបដិសេធមិនព្រមរៀបការ តើគេក្រោយមកគេមានធ្វើទុក្ខបុកម្នេញអីព្រះតេជព្រះគុណអីថែមទៀតទេ ឬក៏ចង់ចាប់ព្រះតេជព្រះគុណអីទេ?

**ឆ៖** អត់មានទេពរៗ អត់មានទេ រហូតទាល់បែក៧៥តែម្តង អត់ដែល -- អត់មានទេ។

**លោក សួន វិសាល៖**

សូមអរព្រះគុណព្រះតេជព្រះគុណ ខ្ញុំបាទអស់សំណួរហើយ។ លោកប្រធានបាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ លោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ព្រះអង្គ ខ្ញុំករុណាមានសំណួរពីរបីដែលត្រូវសួរទៅព្រះអង្គ។ សូមព្រះអង្គជួយបញ្ជាក់បន្ថែមបន្តិច អំពីការសូត្រធម៌នៅក្នុងពេលរៀបការ។ តើព្រះអង្គពិតជា -- តើសូត្រស្អីដែរ ពិតប្រាកដហ្នឹងនៅពេលដែលព្រះអង្គចូលរួមក្នុងពិធីរៀបការ<ទាំងអស់នេះ> ហើយថាមានសូត្រធម៌ហ្នឹង សូត្រធម៌ស្អីដែរ?

[១៤:០៤:២៣]

**ព្រះតេជព្រះគុណ ឯម អឿង៖**

**ឆ៖** ចម្រើនពរ តាមពិធីរៀបការហ្នឹង អាត្មាទៅគ្រាន់តែ--

**ប្រធានអង្គជំនុំ៖**

ព្រះតេជព្រះគុណ កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់ដ៏ខ្លីមួយ។ ខ្ញុំមិនចង់ផ្តាច់សហភាតាខ្ញុំទេ។ ក៏ប៉ុន្តែគឺថាចម្លើយរបស់ព្រះតេជព្រះគុណហ្នឹង គឺព្រះអង្គបាននិយាយតែអំពីពិធីរៀបការមួយ<ប៉ុណ្ណោះ> ដែលព្រះអង្គមានវត្តមាន <គឺមិនមែនច្រើនដងនោះទេ>។ ហើយឥឡូវនេះ បើតាមសំណួរនេះ គឺថាសំណួរហាក់

ដូចជាសំណួរចង់ឲ្យយល់ខុសពីនេះ។ អ៊ីចឹង សូមឲ្យគាត់បំភ្លឺ លោកប្រធាន។

[១៤:០៥:០៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ព្រះអង្គៗ អាចមានសង្ឃដីកាប្រាប់អង្គជំនុំជម្រះថា តើក្នុងពិធីរៀបការហ្នឹង ព្រះអង្គមានបានសូត្រធម៌មែនទេ?

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** បានសូត្រធម៌ ព្រោះភូមិប្ដេជ្ញាបានម្ដង សូត្រម្ដងហ្នឹង ចប់៧៥ហ្នឹងម្ដង។ <ជយយន្ដោ> រលាស់ទឹកឲ្យអ្នករៀបប្ដេជ្ញាថ្មីហ្នឹង ពរ។ តាមសំណូមពររបស់ប្រធានភូមិគេអញ្ជើញទៅ។

**ស៖** អរគុណព្រះអង្គ។ ឥឡូវនេះសូមបង្ហាញព្រះអង្គអំពីកិច្ចសម្ភាសន៍ដែលព្រះអង្គបានឆ្លើយជាមួយនឹងអង្គការមួយហៅថា <ឌី.ស៊ី>.ខេម មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ២០០៥ <គឺនៅខែមករាឆ្នាំ២០០៥>។ ព្រះអង្គចាំទេដែលមានជនបរទេសដែលទៅសម្ភាសន៍ព្រះអង្គយកចម្លើយពីព្រះអង្គនោះនៅចាំបានទេពេលហ្នឹង?

**ឆ៖** យូរពេកហើយ ភ្លេចហើយ យូរពេកហើយ។

**ស៖** ប្រសិនណាជាខ្ញុំករុណា ប្រាប់ឈ្មោះ គឺឈ្មោះ អៀន ហារី តើព្រះអង្គអាចនៅចាំឈ្មោះនេះបានទេ?

[១៤:០៦:៣២]

**ឆ៖** គ្រាន់តែបានដឹងថា មាននារីស្រីម្នាក់ អាមេរិកាំងទៅសម្ភាសដល់កុដិ ពរ។ ជនជាតិអាមេរិកាំង ស្រី។

**ស៖** អរគុណព្រះអង្គ។ ដូច្នេះ ហាក់បីដូចជាថាកិច្ចសម្ភាសន៍របស់ព្រះអង្គជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា <នៅខែមករា> ឆ្នាំ២០០៥ គឺត្រូវបាន អៀន ហារីស *(Ian Harris)* យកចម្លើយរបស់ព្រះអង្គ មកប្រើប្រាស់ <នៅក្នុងសៀវភៅរបស់គាត់ ដោយ>សរសេរពីប្រធានបទមួយ ដែលនិយាយថា "ព្រះពុទ្ធសាសនាក្នុងសម័យ ប៉ុល ពត"។ ខ្ញុំករុណាសូមយោងទៅសៀវភៅរបស់ អៀន ហារីស ត្រង់ទំព័រ២៧២ <ដែលមានចំណងជើងថា ព្រះពុទ្ធសាសនានៅក្នុងសម័យ ប៉ុល ពត> គឺមាន ERN 00704135។ ករុណា <គឺថាវាមិនច្បាស់លាស់>តើ អៀន ហារីស អាចសន្និដ្ឋានបានដោយរបៀបណា ឥឡូវនេះខ្ញុំករុណាសូមអាន<អត្ថបទពីរបី ពី>សៀវភៅនេះ <> ដើម្បីចង់សុំសួរបញ្ជាក់ពីព្រះអង្គ

<ថាតើព្រះអង្គដឹងអំពីរឿងទាំងអស់នេះដែរឬទេ ឬក៏ព្រះអង្គបាននិយាយអំពីរឿងនេះទៅកាន់ព្រះសង្ឃផ្សេងទៀត ដែលដឹងអំពីរឿងនេះ?>។ ខ្ញុំករុណាចាប់អានពីទំព័រ១៤៩ គឺ <E3/2818> ERN ជាភាសាអង់គ្លេស 0070412*(ស៊ីក)* ហើយខ្ញុំករុណាសូម<អានជូនព្រះអង្គ ហើយ>ឲ្យព្រះអង្គមានយោបល់មើល តើព្រះអង្គយល់យ៉ាងដូចម្តេចដែរ?

"នៅពេលដែលឥរិយាបថចំពោះបញ្ហានេះ គឺយើងថាអាចថាជាជំហរ ជាទ្រឹស្តីរបស់ខ្មែរក្រហម។ តថភាពពិតគឺមានលក្ខណៈខុសគ្នាទៅវិញ។ ឧទាហរណ៍ <ការរៀបចំព្រះរាជពិធីបុណ្យសពព្រះមាតារបស់សម្តេច សីហនុ គឺព្រះមហាក្សត្រយានី> កុសមៈ <នៅក្នុងព្រះរាជវាំង នៅក្នុងខែកញ្ញា> ឆ្នាំ១៩៧៥<។ បើទោះវាមិនមែនធ្វើឡើងជាសាធារណៈក៏ដោយ ក៏>ពិធីបុណ្យសពនោះ<>ត្រូវបានព្រះសង្ឃនិមន្តចូលរួម<មួយចំនួន ដែលបានចូលរួមជាមួយខ្មែរក្រហម នៅដើម>ទសវត្សរ៍៧០ ហើយត្រូវបានចូលរួមដោយសម្តេច សីហនុ, ខៀវ សំផន និង <សុន សេន>។ ម្តាយរបស់ នួន ជា ក៏បានទទួលការសូត្រធម៌តាមបែបព្រះពុទ្ធសាសនានៅវត្តគរ <ក្នុងខេត្តបាត់ដំបង នៅ>ក្នុងអំឡុងពេល<ដូចគ្នានេះផងដែរ>។ ហើយក៏<មានភស្តុតាងមួយចំនួន បានបង្ហាញពីលទ្ធភាពដែលអាច>មានការសូត្រធម៌អាចំ៍នៅក្នុងពេលដែលគេធ្វើបុណ្យសពមនុស្សតូចតាចនោះផងដែរ"។

សំណួររបស់ខ្ញុំករុណា សួរថាតើព្រះអង្គបានដឹងអំពីបញ្ហាទាំងអស់នេះដែរទេ ឬក៏មានអ្នកណាម្នាក់ប្រាប់ព្រះអង្គ ដែលថាមានពិធីបុណ្យបូជាសពនៅក្នុងពិធីបូជាសពព្រះមាតារបស់សម្តេច នរោត្តម សីហនុ និងម្តាយរបស់ នួន ជា ព្រះអង្គជ្រាបទេ?

[១៤:១០:០២]

**ឆៈ** ពរ មិនបានជម្រាបទេៗពរ ព្រោះដឹងថា ព្រះមហាក្សត្រយានីសុគតនៅស្រុកចិនឯណោះម្តាយសីហនុពរ។

**សៈ** តើព្រះអង្គ<>ក៏មិនបានដឹងទេអំពីពិធីបូជាសពរបស់ម្តាយ នួន ជា នៅឯបាត់ដំបងនោះព្រះអង្គជ្រាបទេ?

**ឆៈ** ពរ មិនជ្រាបទេពរ មិនជ្រាបទេ។

**សៈ** ព្រះអង្គចាំទេចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩ ដែលនិយាយ -- មាត្រា២០នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យដែលនិយាយអំពីការសូត្រធម៌ បួងសួង គោរពព្រះពុទ្ធសាសនា ព្រះអង្គមានជ្រាបចំពោះមាត្រានេះទេ?

**ឆ៖** ពរ មិនជ្រាបទេៗ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតអានមាត្រា២០ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យគឺ E3/259 ERN ជាអង់គ្លេសគឺ 00184838។ ខ្ញុំមិនមាន ERN ជាភាសាខ្មែរទេ ប៉ុន្តែមាត្រា<២០> គឺអានដូចតទៅ៖ "ប្រជាពលរដ្ឋគ្រប់រូប--

[១៤:១១:៤៦]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់លោក កូប៉េ!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ តាមទម្លាប់នៅចំពោះមុខតុលាការយើងនេះគឺត្រូវតែផ្តល់លេខយោងដែលមាននៅអ៊ីនធឺហ្វេស គ្រាន់តែខ្ញុំមិនគិតថាឯកសារនេះមាននៅក្នុងអ៊ីនធឺហ្វេសទេ។ ហើយយើងខ្ញុំអត់មានឃើញមានបញ្ជីឯកសារនេះនៅក្នុងបញ្ជីភាគីការពារក្តីទេលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ជាការត្រឹមត្រូវហើយ។ <សំណួរនេះបាន>សួរពីព្រឹកមិញហ្នឹង ប៉ុន្តែ<វាគឺជាការពិភាក្សាដេញឯកសារមួយដ៏ទូលំទូលាយ> នៅវគ្គទី១ <នៃសវនាការនេះ។ ដូច្នេះ ខ្ញុំជឿជាក់ថាព្រះរាជអាជ្ញា គឺធ្លាប់ដឹងអំពីបទប្បញ្ញត្តិនេះ>។ ដូច្នេះ បើសិនលោកប្រធានអនុញ្ញាត ខ្ញុំសូមអាន<បទប្បញ្ញត្តិនេះដូចខាងក្រោម៖>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ព្រះអង្គគឺមាត្រា២០នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យនិយាយថា "ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជឿជំនឿ ឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនមានជំនឿអ្វី ឬក៏មិនជឿសាសនាណាក៏បាន។ មិនអនុញ្ញាតឲ្យមានសាសនាប្រតិកិរិយាដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជាដាច់ខាត"។ នេះគឺជាបទប្បញ្ញត្តិនៅក្នុងមាត្រាមួយនៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ <ឆ្នាំ១៩៧៦> តើព្រះអង្គមានជ្រាបអំពីមាត្រានេះទេ?

**ព្រះតេជព្រះគុណ ឯម អឿង៖**

**ឆ៖** ពរ មិនបានឃើញផ្ទាល់ទេ ប៉ុន្តែឮគេនិយាយពរ មិនបានឃើញផ្ទាល់ទេ ឮគ្រាន់តែឮតៗគ្នាមានឮ។

[១៤:១៣:៣៤]

**ស៖** ព្រះអង្គមានចាំថា មេឃុំ កម្មាភិបាលខ្មែរក្រហម ឬក៏ប្រជាជននិយាយអំពី<សេរីភាពខាង>ជំនឿសាសនានេះ <ឬក៏ព្រះអង្គមិនដែលបានឮអំពីទ្រឹស្តីនេះ ឬការពិភាក្សានេះពីមុនមក>ទេ?

**ឆ៖** សម័យ ប៉ុល ពត អត់មានអ្នកនិយាយទេ អត់មានទេៗ ប៉ុល ពត អត់មានទេ។ រឿងអ្វីៗទាំងអស់ធ្វើគទាំងអស់។

**ស៖** អរគុណព្រះអង្គ។ ករុណាចូលទៅប្រធានបទមួយទៀតដែលនិយាយនៅក្នុងសៀវភៅនេះ គឺ អៀន ហារីស នេះ ហើយគាត់បានពិភាក្សាអំពីបញ្ហាសង្គ្រាមស៊ីវិលចន្លោះពី៧០ ទៅ៧៥ ដែលថាវត្តអារាមជាច្រើនត្រូវបានបំផ្លិចបំផ្លាញ ដែលគាត់សរុបថាវត្តអារាមពីរភាគបីត្រូវបានបំផ្លិចបំផ្លាញ <ហើយមានវត្តជាច្រើនក៏ត្រូវបានបំផ្លិញបំផ្លាញ>ដោយសារតែការទម្លាក់គ្រាប់បែករបស់អាមេរិកាំង។ ព្រះអង្គមានព្រះបន្ទូលថាម៉េចដែរពាក់ព័ន្ធទៅនឹងការបំផ្លិចបំផ្លាញវត្តអារាម>ក្នុងអំឡុងសង្គ្រាមស៊ីវិល <ឬក៏ការ>បំផ្លិចបំផ្លាញ<ដោយការទម្លាក់គ្រាប់បែករបស់អាមេរិកាំង>?

**ឆ៖** ពរ មានថាម៉េច បើកាលហ្នឹងសម័យសាធារណរដ្ឋ លន់ នល់ គាត់កាន់កាប់ហ្នឹង។ នៅក្រោមរបស់អាមេរិកាំងត្រួតត្រា ពួកអាមេរិកាំងបានទម្លាក់អ៊ីចឹងមែន បានទម្លាក់គ្រាប់បែក ពរ។

**ស៖** តើត្រឹមត្រូវទេដែលថាវត្តជាច្រើនត្រូវបានបំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែកពីកប៉ាល់ហោះរបស់អាមេរិកាំងនោះ?

**ឆ៖** ពរ ត្រូវខ្លះមិនត្រូវខ្លះ កន្លែងហ្នឹង ពរ។ នៅតាមជនបទមានមួយចំនួនតូចទេ ដែលគ្រាប់បែក បើតាមទីក្រុងអត់មានទេ អត់មានប៉ះពាល់ទេវត្ត។

**ស៖** តែព្រះអង្គអត់ដឹងតួលេខទេ<? តើត្រឹមត្រូវដែរឬទេ ដែលថា>វត្តអារាមពីរភាគបីត្រូវបានបំផ្លិចបំផ្លាញ<នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិល? ឬក៏>ព្រះអង្គ<មិនបាន>ដឹងអំពីចំនួនតួលេខនេះទេ?

**ឆ៖** មិនបានដឹងទេៗ។

**ស៖** សូមអធ្យាស្រ័យ តើព្រះអង្គមានដឹងអំពីការដុតបំផ្លាញគម្ពីរព្រះពុទ្ធសាសនាដែរឬទេ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង?

[១៤:១៦:៣១]

**ឆ៖** ពរ សម័យកម្ពុជាប្រជាធិបតេយ្យក្រោមការត្រួតត្រា ប៉ុល ពត ហ្នឹងអស់តែម្តង ព្រោះគម្ពីរស្លឹករឹតគេទៅហែកដេរធ្វើជាម្លូក សម្រាប់ពលករពាក់ធ្វើកសិកម្ម ពរ។ គម្ពីរផ្សេងៗទៀត ក្រដាសហ្នឹងគេហែក បានឃើញផ្ទាល់ ពរ ហើយយើងមិនហ៊ានថាគេទេ។ សូម្បីតែរូបព្រះបត់គេគូររូបព្រះនៅក្នុងព្រះបត់ហ្នឹង ក៏គេយកទៅដែរ ពរ។ ពរ គេយកទៅហែកខ្លះធ្វើជាដួន ខ្លះធ្វើជាម្លូកអីពាក់អីចឹង ហ្នឹងឃើញ។ ឃើញផ្ទាល់តែម្តងអាហ្នឹង។

**ស៖** សូមអរគុណព្រះអង្គ។ សំណួរមួយចំនួនទៀតទាក់ទងទៅនឹងអ្វីដែលបានកើតឡើងនៅស្រុកត្រាំកក់។ ព្រះអង្គមានសង្ឃដីកាថា ប្រសិនជាខ្ញុំករុណាចាំមិនច្រឡំទេ ពេលម៉ោងការងារ គឺចាប់ពីពេលព្រលឹម រហូតដល់ម៉ោងប្រាំមួយល្ងាច ព្រះអង្គមានសង្ឃដីកាថា អីចឹងឬក៏យ៉ាងម៉េចព្រឹកមិញហ្នឹង?

**ឆ៖** មិនដឹងទេ មិនបានដឹងទេ ពរ។ បើអាត្មាធ្លាប់ជួបតែពេលយប់ទេ ពេលព្រឹកមិនដែលជួបទេរឿងប្តេជ្ញាហ្នឹង ពរ។

**ស៖** ខ្ញុំករុណារៀបសំណួរឡើងវិញ នៅពេលដែលព្រះអង្គ<ធ្វើការងារ ដូចជា> លើកទំនប់ប្រឡាយនោះ គឺព្រះអង្គធ្វើការរហូតមកដល់ម៉ោងប្រាំមួយល្ងាច អីចឹងមែនទេ?

**ឆ៖** ត្រឹមត្រូវហើយៗ។

**ស៖** តើនេះជាម៉ោងធ្វើការធម្មតា<ទូទៅ? តើចំនួនម៉ោងធ្វើការជាមធ្យមប៉ុន្មានដែរ? តើមានពេលខ្លះ ព្រះអង្គក៏ធ្វើការនៅពេលល្ងាច ឬក៏មិនដែលទេ>?

**ឆ៖** សម័យ៣ឆ្នាំ ៨ខែ ២០ថ្ងៃ គ្មានឈប់មុនម៉ោងទេ មានតែលើសម៉ោង ពរ។ បើថាប្រាំម៉ោងប្រាំមួយ ម៉ោងប្រាំមួយម៉ោងប្រាំពីរហើយ មិនដែលមានមុនម៉ោងទេតាមអាត្មាធ្វើខ្លួនឯងផ្ទាល់ ធ្វើផ្ទាល់ខ្លួនឯង ពរ។

**ស៖** តើ<ម៉ោងធ្វើការនេះ មានតែ>ពេលខ្លះ<ប៉ុណ្ណោះឬ ដូចជានៅអំឡុងរដូវច្រូតកាត់ ឬក៏វាកើតញឹកញាប់>? តើព្រះអង្គចាំទេ?

**ឆ៖** មើលម្តងទៀតមើល ពរ។ ពរ តើចង់ដឹងយ៉ាងម៉េចអារឿងហ្នឹង?

**ស៖** ពេលធ្វើការងារនៅពេលយប់ គឺធ្វើម្តងម្កាលទេ ឬក៏ធ្វើជាញឹកញាប់ដែរព្រះអង្គ?

**ឆ៖** ញឹកញាប់ដែរ បើខែវស្សាដកសំណាប ពរ។ ឡើងមកបាយហើយដកទៀត ម៉ោងដប់បានឈប់ អាហ្នឹងវស្សា រាល់ថ្ងៃហើយ ក្នុងវស្សាហ្នឹងកន្លែងអាត្មានៅ។

[១៤:២០:០៦]

**ស៖** តើការងារនេះ ធ្វើតែក្នុងរយៈពេលជាក់លាក់ណាមួយ<នៃឆ្នាំ តើ>ត្រឹមត្រូវទេ ព្រះអង្គ?

**ឆ៖** រដូវវស្សា ពរ។ រួចហើយក៏ពន្យារដែរ ពន្យារពេលខែប្រាំងលើកទំនប់ លើកប្រឡាយហ្នឹង គឺពន្យារខ្លះ ពរ។

**ស៖** សំណួរមួយចុងក្រោយទៅលើប្រធានបទហ្នឹង និយាយអំពីចំណីអាហារចង្អាន់នេះវិញ តើព្រះអង្គ--

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ មានបញ្ហាបកប្រែភាសា។

មន្ត្រីរដ្ឋបាលតុលាការជួយពិនិត្យការបកប្រែភាសា។

*(មានបញ្ហាបកប្រែភាសា)*

បាទ សូមអញ្ជើញបន្តទៀត! ហើយសូមសំណួរសួរចុងក្រោយអំមិញម្តងទៀត លោក វ៉ិចទ័រ កូប៉េ។

[១៤:២១:២៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំករុណា គឺនិយាយអំពីចំណីអាហារ របបអាហារ។

**ប្រធានអង្គជំនុំ៖**

ចាំៗបន្តិច លោក វ៉ិចទ័រ។ អស់ថ្មខ្លួនគាត់ទេ? មើលអ្នកបកប្រែ ម្នាក់គាត់តើ!

បាទ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំករុណាសួរឡើងវិញព្រះអង្គ។ ព្រះអង្គមានសង្ឃដីកាអំពីចំណីអាហារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលព្រះអង្គទីនោះ។ តើព្រះអង្គអាចមានសង្ឃដីកា ថាតើចំណីអាហារដែលគេផ្តល់ឲ្យព្រះអង្គ ឬក៏អ្នកដទៃហ្នឹង មានភាពប្រសើរឡើងទេ នៅឆ្នាំ៧៦ និង៧៧ តើពី៧៦ ទៅ៧៧ហ្នឹង វាគ្រាន់បើជាងពី ៧៥ទេ?

[១៤:២២:៤១]

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** ចម្រើនពរ ដោយឡែកនៅភូមិអាត្មាហ្នឹង ប្រជាជនគេចែកបីផ្នែក។ មួយផ្នែក គឺអ្នកមានកម្លាំងពលំខ្លាំងធ្វើពលកម្មសមរមុខ អាហ្នឹងមួយផ្នែក។ មួយផ្នែកទៀត គឺធ្វើការធម្មតា។ មួយផ្នែក

ទៀត គឺចាស់ជរា។ ដូច្នេះ ពី៧៥ មកដល់៧៦អីហ្នឹង ក៏មិនទាន់បរិបូណ៌ដែរអាហ្នឹង។ ដល់មុនបែក៧៩ នេះ បានកែកម្មពិធីអាហារហូបចុកខ្លះ។ ពរ នៅភូមិអាត្មាហ្នឹងមានបាយរឹងខ្លះ ពរ បាយរឹង មានបបរខ្លះ មានបាយរឹងខ្លះ។ ដោយជាមធ្យោបាយថាឥឡូវ យើងយូរឆ្នាំទៅហើយ ឥឡូវដោះស្រាយជីវភាពឥឡូវ ល្មមគួរសមហើយ ឥឡូវដាំបាយខ្លះទៅចុងភៅ ឲ្យបងប្អូនហូប កុំឲ្យបបរច្រើនពេក។ ព្រោះហ្នឹង ៧៧, ៧៨ ពរ ជួយបានប៉ុណ្ណឹង។

**ស៖** បើខ្ញុំករុណាយល់មិនច្រឡំទេ ស្ថានភាពចំណីអាហារ<មានភាពល្អប្រសើរនៅក្នុងឆ្នាំ> ៧៨ <និងឆ្នាំ>៧៩ គឺ<មានភាពល្អប្រសើរជាង>រយៈពេល២ឆ្នាំ<ដំបូង>នៃរបបកម្ពុជាប្រជាធិបតេយ្យ<>?

**ឆ៖** ពរ ប្រសើរគួរសម ពរ។ វាប្រសើរតែបាយទេ តែម្ហូបហ្នឹងអត់ដដែលទេ។ ព្រលឹត ល្ពៅ ស្ពត់ ប៉ុណ្ណឹងទេពរ អត់មានអី មានតែទឹកៗហ្នឹង តែបាយ បានបាយ។

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

[១៤:២៤:៥៣]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ។ សូមក្រាបថ្វាយបង្គំព្រះអង្គ ខ្ញុំព្រះករុណា គង់ សំអុន ជាមេធាវីរបស់លោក ខៀវ សំផន ហើយតទៅនេះ ខ្ញុំព្រះករុណាមានសំណួរមួយចំនួនដើម្បីទូលព្រះអង្គ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ពីព្រឹកមិញនេះ ព្រះករុណាខ្ញុំបានស្តាប់ឮព្រះអង្គមានថេរៈដីកាទាក់ទងរឿងការប្រជុំនៅវត្តអង្គរកា ហើយក្នុងការប្រជុំនេះ ឃើញថាមានការបកស្រាយខុសគ្នា ការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាដែលបានលើកអំពីសក្ខីកម្មរបស់សាក្សីម្នាក់ផ្សេងទៀត ហើយនិងការចូលរួមរបស់ព្រះអង្គនៅពេលនោះ។ ករុណាខ្ញុំចង់សួរបញ្ជាក់ព្រះអង្គថា តើព្រះអង្គចូលរួមប្រជុំនៅក្នុងវត្តអង្គរកាទាក់ទងទៅនឹងការដាក់ផែនការលាចាកសិក្ខាបទនោះ ពីដើមរហូតដល់ចប់ដែរទេនៅពេលនោះ?

[១៤:២៦:០៦]

**ព្រះតេជព្រះគុណ ឯម រឿង៖**

**ឆ៖** ចម្រើនពរ រឿងប្រជុំដាក់ផែនការដើម្បីឲ្យអ្នកបួសលាចាកសិក្ខាបទនៅវត្តអង្គរកាថ្ងៃនោះ ពរ អាត្មាចូលរួមមិនចប់ទេ។ ព្រោះអាត្មាមកភ្នំពេញ មកក្រោយគេដែរ ពរ មកអត់ទាន់ ប្រជុំលើកក្រោយបានទាន់ពរ។

**ស៖** អ៊ីចឹងព្រះអង្គបានចូលរួមប្រជុំតាមការមានសង្ឃដឹកាកន្លងមកថា មានតែម្តងទេ ដែលព្រះអង្គបានចូលរួម។ អ៊ីចឹង តាមអ្វីដែលព្រះអង្គបានមានថេរៈដីកាអម្បាញ់មិញនេះគឺថា មានការប្រជុំមុននឹងព្រះអង្គនិមន្តទៅដល់វត្តអង្គរកានោះដែរ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ដល់ពេលអាត្មាទៅដល់ហ្នឹង អាត្មាដឹងតែពេលដែលអាត្មាទៅដល់ទេ ដែលមុនអាត្មាមិនបានដឹងទេ ប៉ុន្តែអាត្មាទៅដល់ហ្នឹង បានដឹង ដឹងគេប្រជុំដើម្បីឲ្យព្រះសង្ឃដែលនិមន្តមកអំពីទិសនានាហ្នឹងត្រូវចាកសិក្ខាបទទៅ ហ្នឹងដឹង។

**ស៖** ចុះព្រះអង្គដឹងថា មានការប្រជុំផ្សេងទៀតទេ ពីមុនព្រះអង្គទៅដល់? ឬមួយក៏មិនមានការនិយាយប្រាប់ថាមានការប្រជុំហ្នឹងទេ?

**ឆ៖** អាត្មាមិនបានជួបផ្ទាល់ទេ ឮគេថា ឮគេនិយាយទេរឿងហ្នឹង។

**ស៖** បាទទាក់ទងទៅនឹងការប្រជុំដែលព្រះអង្គបាននិមន្តចូលរួមហ្នឹង ព្រះអង្គចាំបានថាប្រជុំនៅពេលវេលាជាក់លាក់ណាដែរ? អាចចាំបានថ្ងៃទី ឬក៏ខែនៃការប្រជុំនោះទេ?

**ឆ៖** មិនបានចាំទេ ដោយមិនបានគិតគូរផង។ រឿងប្រជុំរឿងអីហ្នឹងអត់គិតគូរទេ ព្រោះអត់បានចាំទេរឿងហ្នឹង មិនដឹងថ្ងៃទីប៉ុន្មានខែអីៗ អត់បានចាំទេ។ អត់មានអារម្មណ៍នឹងចាប់ភ្លឹកផង។

[១៤:២៨:៣៥]

**ស៖** ព្រះអង្គអាចចាំបានទេថា មានអ្នកចូលរួមប្រជុំប៉ុន្មាននាក់ដែរនៅពេលនុ៎ង?

**ឆ៖** ឃើញគេឧទ្ទេសនាមថា មានប្រធានភូមិ មានអីហ្នឹង ភូមិមានក្រុមចូលប្រជុំហ្នឹង។

**ស៖** ជាចំនួនមនុស្សដែលចូលរួមទាំងគ្រហស្ថទាំងសង្ឃ មានប៉ុន្មាននាក់ដែរ? មានប៉ុន្មានអង្គប៉ុន្មាននាក់ដែរ? តេជគុណអាចចាំបានទេ?

**ឆ៖** បើប្រជុំគេសម្រាប់តែអ្នកព្រះសង្ឃ អត់គ្នាច្រើនទេ អត់ទេ។ ក្នុងវត្តហ្នឹង បើប្រជុំសម្រាប់ព្រះសង្ឃតែម្តង អត់ច្រើនទេ។ បើប្រជុំសម្រាប់បាសកហ្នឹងវាច្រើន។ ព្រោះព្រះសង្ឃពីរ *(ឮមិនច្បាស់)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពរ ព្រះសង្ឃមិនច្រើនទេ។

**ស៖** ព្រះអង្គអាចចាំបានថា អ្នកណាជាអ្នកដឹកនាំការប្រជុំ ឬក៏ជាគណៈអធិបតីនៅការប្រជុំនោះទេ ការប្រជុំដែលព្រះអង្គមានវត្តមាន?

**ឆ៖** ដល់ពេលប្រជុំ គេឧទ្ទេសនាមមានអី មានត្រឹមសមាជិកឃុំ ភូមិ ក្រុមប៉ុណ្ណឹង ពរ។

**ស៖** ការប្រជុំនុ៎ង មានការឆ្លើយឆ្លងមតិគ្នារវាងអ្នកចូលរួមប្រជុំដូចជា ព្រះសង្ឃ ឬក៏អ្នកចំណុះជើងវត្តហ្នឹង ជាមួយនឹងអ្នកដែលជាបើកការប្រជុំហ្នឹងទេ ជាគណៈអធិបតីហ្នឹងទេ?

**ឆ៖** ចម្រើនពរ មិនមានទេ អត់មាននរណាមានមតិអីទេ អង្គការចាត់តាំងយ៉ាងណា គឺយ៉ាងហ្នឹងហើយ ចប់ហើយ។ អត់មានអ្នកណាហ៊ានតៗតាំងសួររកខុសរក អត់មានទេ អត់មានទេពរ ថាម៉េចទៅអ៊ីចឹងហើយ។

**ស៖** ព្រះអង្គអាចពន្យល់បន្ថែមពីគោលដៅនៃការប្រជុំដែលព្រះអង្គបាននិមន្តចូលរួមនោះ ថាតើជាការប្រជុំ ដើម្បីផ្សឹកព្រះសង្ឃ ឬក៏ដើម្បីឲ្យព្រះសង្ឃលាចាកសិក្ខាបទ? ព្រោះតាមការបកស្រាយរបស់ព្រះអង្គកន្លងមកនេះ ឃើញថាមានការប្រើប្រាស់ពាក្យខុសគ្នា។ ព្រះអង្គមានថេរៈដីកាអំពីការលាចាកសិក្ខាបទ ប៉ុន្តែតំណាងសហព្រះរាជអាជ្ញា បានសួរពីការផ្សឹកព្រះសង្ឃ។ អ៊ីចឹង សូមព្រះអង្គបកស្រាយបន្ថែមទៅលើការកំណត់គោលដៅ ឬក៏ការប្រើប្រាស់នូវពាក្យថាជា "ការផ្សឹក" ឬក៏ "ការលាចាកសិក្ខាបទ"? ហើយតើពាក្យនេះ វាខុសគ្នាដូចម្តេចដែរ?

[១៤:៣១:៥៦]

**ឆ៖** ចម្រើនពរ ពាក្យថា "សឹក" "ចាកសិក្ខាបទ" ហ្នឹងមិនខុសគ្នាទេ ពរ ព្រោះក្លាយភេទពីៗអ្នកបួសមកបាសកដូចគ្នាទេ ពរ មិនខុសគ្នាទេ។ គ្រាន់តែមួយថា ឥឡូវព្រះអង្គចាកសិក្ខាបទ ខ្លះថាសឹកទៅ ប៉ុណ្ណឹងទេពរ អត់មានអីទេ បាសកដូចគ្នាទេ។ តែៗ "ចាកសិក្ខាបទ" ក៏មកបាសក "សឹក" ក៏មកបាសកដូចគ្នាទេ ពរ។

**ស៖** បាទ សូមអរព្រះគុណ។ ទាក់ទងទៅនឹងផែនការនៃការឲ្យលាចាកសិក្ខាបទ តើការកំណត់នូវផែនការឲ្យលាចាកសិក្ខាបទនោះ មានកំណត់នូវថិរវេលាពិតប្រាកដ ហើយមានការកំណត់នូវចំនួនព្រះសង្ឃដែលត្រូវឲ្យលាចាកសិក្ខាបទក្នុងពេលជាក់លាក់ ឬមួយក៏ព្រះសង្ឃដែលស្ថិតនៅក្នុងវត្តអង្គរកានៅពេលនោះ គឺមានជម្រើសថា ក្នុងរយៈមួយថា ខ្លួនព្រះអង្គចង់លាចាកសិក្ខាបទនៅពេលណាក៏បានក្នុងរយៈពេលដែលគេកំណត់?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចម្រើនពរ បើតាមអាត្មាចាំដែលគេបាននិយាយណែនាំយើង កាលសម័យនោះ ជាភេទជាអ្នកបួសនោះ ឲ្យយើងប្រើពេលវេលាខ្លី កុំឲ្យយូរ ព្រោះខាតពេលវេលា។ នៅភេទជាអ្នកបួសហ្នឹង ធ្វើការងារអីមិនកើតនឹងគេទេ។ អាហារភោជនក៏លំបាកគេដែរ បើអ៊ីចឹងទៅបាសកទៅវាងាយ។ ធ្វើរម៉ានក៏បានដែរបាយ បើអ្នកបួសបានតែព្រឹក ហើយថ្ងៃត្រង់ ដល់ល្ងាចអត់បាននឹងគេ។ បើអ៊ីចឹង គេថានៅមិនកើតទេ ត្រូវតែចាកទៅ។ ព្រោះសម័យនេះ មិនមែនៗសម័យពីដើមទៀតទេ សម័យៗហ្នឹងសម័យបដិវត្តន៍ៗពរ អត់មានអ្នកណាមួយទៅទំនេរបានទេ។ បើអ៊ីចឹង បដិវត្តន៍ធ្វើចលនាទាំងអស់គ្នា។ នរណាតួនាទីអីធ្វើហ្នឹងទៅ កសិកម្មៗទៅ នរណាឧស្សាហកម្ម ឧស្សាហកម្មទៅ ហ្នឹងហើយ។ និយាយប៉ុណ្ណឹងពរ។

[១៤:៣៤:១៩]

**ស៖** បាទ សូមអរព្រះគុណព្រះអង្គ។ ព្រះអង្គបានឃើញដោយព្រះអង្គឯង ទាក់ទងទៅនឹងការលាចាកសិក្ខាបទរបស់ព្រះសង្ឃដែលបានធ្វើឡើងមុនៗព្រះអង្គដែរទេ ក្នុងពេលដែលព្រះអង្គគង់នៅវត្តអង្គរកា?

**ឆ៖** ពរ មុនហ្នឹងអាត្មាមិនបានដឹងទេ ព្រោះអាត្មានៅរាជធានីឯណោះ អាត្មានៅភ្នំពេញឯណោះ អាត្មាមកក្រោយ។ ដឹងតែថាអាត្មាដែលមកដល់អង្គរកាទេ ពីមុនមិនបានដឹងទេពរ។

**ស៖** ករុណាចង់ពិតទូលព្រះអង្គ ទាក់ទងនឹងពេលដែលព្រះអង្គគង់នៅវត្តអង្គរការ ហើយពេលនោះគឺថា តើព្រះអង្គបានឃើញព្រះសង្ឃដែលបានលាចាកសិក្ខាបទមុនព្រះអង្គលាចាកសិក្ខាបទដែរទេ?

**ឆ៖** អាត្មាគ្រាន់តែបានមកជួប ឃើញអន្ទិតអស់ហើយៗ មកជួបគ្នាថា “ករុណាសឹកអស់ហើយ ករុណាសឹកហើយ ព្រះអង្គមកក្រោយក៏មិនយូរប៉ុន្មានដែរ សឹកដូចគ្នាហ្នឹងហើយ។ អង្គការគេមិនឲ្យនៅទេ ហ្នឹងអ្នកសឹកមុនបានប្រាប់អ៊ីចឹងពរ។

**ស៖** ប៉ុន្តែព្រះអង្គបានចូលរួមក្នុងពិធីផ្សឹក ឬក៏លាចាកសិក្ខាបទហ្នឹងណាមួយទេ មុនៗព្រះអង្គផ្សឹក ដោយព្រះអង្គឯងផ្ទាល់នេះ?

[១៤:៣៦:០០]

**ឆ៖** អាត្មាមិនបានចូលរួមនឹងគេទេ ព្រោះអាត្មាសឹកជាមួយនឹងលោកគ្រូអាត្មា លោកតា ឃ្លោក អ៊ុច នេះតែម្តង លោកអ្នកសឹកឲ្យអាត្មា។

**ស៖** សម្រាប់ព្រះអង្គផ្ទាល់ ព្រះអង្គលាចាកសិក្ខាបទនៅពេលណា?

**ឆ៖** ៧៦។

**ស៖** ព្រះអង្គចាំខែទេ? ចាំខែបានទេក្នុង ៧៦ហ្នឹងក្នុងចន្លោះខែណាដែរ?

**ឆ៖** នឹកមិនឃើញ មិនបានចាំទេ នឹកមិនឃើញ។ មីងមាំងអស់ពេលហ្នឹង មីងមាំងអស់នឹកមិនឃើញទេ។

**ស៖** ករុណាចង់ទូលសួរព្រះអង្គទាក់ទងទៅនឹងការរស់នៅជាព្រះសង្ឃ នៅក្នុងវត្តអង្គរកាក្នុងពេលដែលព្រះអង្គនិមន្តពីភ្នំពេញទៅ។ ព្រះអង្គមានថេរៈដីកាថា បានធ្វើដំណើរប្រហែល២ខែពីភ្នំពេញរហូតទៅដល់វត្តអង្គរការ។ អ៊ីចឹងវាអាចក្នុងខែមិថុនា ឆ្នាំ១៩៧៥ ព្រះអង្គបានទៅដល់វត្តអង្គរការនោះហើយ។ ហើយករុណាចង់សួរថា តើជីវភាពរបស់ព្រះអង្គ និងព្រះសង្ឃដទៃទៀត ដែលគង់នៅក្នុងវត្តអង្គរការក្នុងចន្លោះពីខែមិថុនា ឆ្នាំ១៩៧៥ រហូតដល់ដាច់ឆ្នាំ១៩៧៥នោះ មានស្ថានភាពបែបម៉េចដែរព្រះអង្គ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបព្រះតេជព្រះគុណ!

[១៤:៣៨:០៥]

**ព្រះតេជព្រះគុណ ឯម គឿង៖**

**ឆ៖** ពរ ពេលហ្នឹងព្រះសង្ឃជីវភាពលោកថយហើយ។ ប្រជាជនមិនសូវនៅភូមិករហើយជម្លៀសទៅឆ្ងាយៗហើយពរ។ ព្រះសង្ឃថយហើយជីវភាព ធ្វើផ្ទាល់ខ្លួនឯង។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ព្រះករុណាចង់សួរបញ្ជាក់ថា តើមានឧបាសក ឬអ្នកដែលចំណុះជើងវត្តបានយកចង្ហាន់ ឬក៏តេយ្យទានយកមកប្រគេនព្រះសង្ឃទេនៅចន្លោះពេលព្រះអង្គគង់នៅវត្តអង្គរការ?

**ឆ៖** ចម្រើនពរ ក្នុងរយៈកាល៧៥នេះនៅមាន យាយតាមួយចំនួនដែលគាត់មកសមាទាននៅមានខ្លះពរ តែមិនច្រើនទេ មានខ្លះ ហ្នឹង៧៥ ពរ។

**ស៖** ចុះតើចំនួនអ្នកដែលមកយកចង្ហាន់មកប្រគេនព្រះសង្ឃនៅ -- គង់នៅវត្តហ្នឹងមានចំនួនថយចុះពីពេលចាប់ផ្ដើមរហូតដល់ចុង៧៥ ឬមួយក៏វាមានលក្ខណៈនៅពេលដែលដាច់ គឺដាច់ឆ្នាំចិតសិបដើមឆ្នាំ៧៦ហ្នឹងតែម្ដង?

**ឆ៖** ចម្រើនពរ ដល់អស់ព្រះសង្ឃ ក៏ដាច់ហើយ ពុទ្ធបរិស័ទអីហើយ។ ព្រះសង្ឃទាំងឡាយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ដែលបានដឹងរឿងពិត ដោយសារតាៗហ្នឹងគាត់មកវត្ត គាត់ថាដំណាលប្រាប់។ ប្រាប់ហេតុផល អំពីគាត់មូលដ្ឋាន គាត់នៅនឹងមូលដ្ឋានហ្នឹងគាត់ដឹងរឿង ពរ សកម្មភាពយ៉ាងម៉េចៗ គាត់ប្រាប់ហេតុផលអស់ហើយ បានទាំងព្រះសង្ឃខ្លួនឯងហ្នឹងក៏មានបញ្ហាហ្នឹង ដឹងរឿងតាមតាៗអស់ហ្នឹង។ ហើយអង្គការគេយកអាវខោមកឲ្យទៀតក៏ដឹងរឿងហ្នឹងទៅក៏សឹកទៅពរ ប្រាប់ត្រង់ប៉ុណ្ណឹង។ អស់មានឧបាសក អស់មានយាយតាមកចូលទៅវត្តទៀតហើយ អស់មានហើយ។

[១៤:៤០:១០]

**សៈ** បាទ ករុណាចង់សួរព្រះអង្គទាក់ទងនឹងព្រះអង្គៗឯងផ្ទាល់ នៅពេលដែលលាកចាកសិក្ខាបទ ជាការសម្រេចចិត្តរបស់ព្រះអង្គអង្គឯង ឬក៏មានការរៀបចំពិធីដោយបង្ខំណាមួយដើម្បីឲ្យព្រះអង្គលាចាកសិក្ខាបទដែរទេ?

**ឆៈ** ចម្រើនពរ រឿងចាកសិក្ខាបទនេះ បើមិនបង្ខំ ដូចបង្ខំដែរពរ ព្រោះគេឲ្យមធ្យោបាយហើយទៅហើយពរ។ មកជួបគេថា "ខ្ញុំករុណាអត់មានអីទេតេជគុណអើយ ជួបតេជគុណមានតែ នេះគួរសមតេជគុណអាវមួយខោមួយទ្រនាប់ជើងមួយប៉ុណ្ណឹងទេគួរសម អត់មានអីតទៀតទេ ព្រោះកន្លែងបដិវត្តន៍អត់មានកន្លែងអី អត់មានភេទអីដូចតេជគុណតទៅទៀតទេ"។ គ្រាន់តែថាប៉ុណ្ណឹងទេពរ ប៉ុណ្ណឹងពាក្យថាបង្ខំហើយពរ បង្ខំហើយអាហ្នឹង។

**សៈ** បាទ ព្រះអង្គ កាលពីព្រឹកមិញនៅម៉ោងប្រហែលដប់ព្រឹក ព្រះអង្គមានថេរៈដីកាថាព្រះអង្គនៅមិនកើត ព្រោះអត់មានអ្នកឧបត្ថម្ភ មានព្រះសង្ឃសឹកបណ្ដើរៗ។ អ៊ីចឹង ការដែលសម្រេចចិត្តរបស់ព្រះអង្គ ដោយសារគ្មានអ្នកឧបត្ថម្ភ បានន័យថាគ្មានអ្នកយកចង្ហាន់មកប្រគេនព្រះអង្គ ហើយទើបព្រះអង្គសម្រេចលាចាកសិក្ខាបទ ឬមួយក៏មានហេតុផលអ្វីផ្សេងដែលនាំឲ្យព្រះអង្គត្រូវតែលាចាកសិក្ខាបទនៅពេលនោះ?

[១៤:៤២:០២]

**ឆៈ** អ៊ីចេះ សូមជម្រាបញោមជ្រាប។ រឿងសម័យនោះ ជារឿងមួយដែលយើងគួរកត់សម្គាល់ ព្រោះគេមានមធ្យោបាយគេ គេនយោបាយខ្ពស់ ដើម្បីឲ្យយើងទាំងអស់ហ្នឹងមិនអាចនៅបានទេពរ។ អ្នកបួសបែកពីភ្នំពេញទៅទាំងអម្បាលម៉ានអត់មាននៅកើតទេ ត្រូវៗតែចាកសិក្ខាបទទាំងអស់គ្នាទៅជាប្រជារាស្ត្រពរ។ ព្រោះគេនិយាយៗថា គេធ្វើបដិវត្តន៍អត់អ្នកណាមួយដេកស៊ីទេ ត្រូវតែពលកម្មទាំងអស់គ្នា មិនថាចាស់មិនថាក្មេងមិនថាប្រុសមិនថាស្រីទេ ត្រូវពលកម្មទាំងអស់គ្នា គេបដិវត្តន៍ហ្នឹងហើយអត់

មានអ្នកណាមួយដេកស៊ីទេ។ នេះមធ្យោបាយរបស់គេ។ និយាយដដែលៗតែអ៊ីចឹងពរ ហ្នឹងហើយ អត់មានអង្គណានៅបានទេពរ។ អាហ្នឹងហើយដែលយើងមិនអាចនៅបានពរ ត្រូវតែសម្រេចចិត្តថា គេម៉េចយើងម៉េច ទៅហ្នឹងគេហ្នឹងឯងទៅ។ ព្រោះពាក្យនេះវាអាជ្ញាមួយខ្លាំងហើយ អាជ្ញាហើយ។ បដិវត្តន៍អត់មានអ្នកណាមួយទំនេរកើតទេ ត្រូវតែធ្វើការរកស៊ីទាំងអស់គ្នា កសិករទាំងអស់គ្នា ពលករទាំងអស់គ្នា ទូទាំងប្រទេសអត់មានអ្នកណាមួយដេកស្ងៀមបានទេ។ អង្គការចាត់តាំងថាអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការកិច្ចសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនិងអ្នកជំនាញដល់ព្រះតេជព្រះគុណ ឯម ភឿង នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យនិមន្តព្រះអង្គមកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអរអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

បាទ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមក្រាបថ្វាយបង្គំព្រះអង្គត។ករុណាចង់សួរបន្តទាក់ទងទៅនឹងពេលវេលាដែលព្រះអង្គ

គង់នៅវត្តអង្គរកា។ មុននេះ ព្រះអង្គមានថេរៈដីកាអំពីការឱ្យធ្វើពលកម្ម ហើយទៅព្រះអង្គបានចូលរួមធ្វើពលកម្មដែរ ក្នុងនាមជាព្រះសង្ឃ ដែលព្រះអង្គមានថេរៈដីកាថា មានការជីកប្រឡាយអីជាដើម។ ព្រះអង្គអាចជម្រាបអង្គជំនុំជម្រះបានទេថា មានព្រះសង្ឃប៉ុន្មានអង្គដែលធ្វើការក្នុងក្រុមរបស់ពេលព្រះអង្គនៅពេលនោះ?

**ព្រះតេជព្រះគុណ ឯម ភឿន៖**

**ឆ៖** ចម្រើនពរ គេចែកជាក្រុមៗ មាន១០អង្គ មាន២០អង្គ ពរ។ ចែកក្រុមៗមិនឱ្យគរកម្លាំងគ្នាទេ មិនឱ្យគរកម្លាំងទេ គេចាត់ចែង។

[១៥:០៣:២៤]

**ស៖** ព្រះអង្គក្រៅពីជីក -- មានជីកប្រឡាយ ក្រៅពីជីកប្រឡាយនេះ មានធ្វើអ្វីទៀតព្រះអង្គនៅពេល -- ក្នុងឋានៈដែលជាព្រះសង្ឃហ្នឹង?

**ឆ៖** នៅភេទជាព្រះសង្ឃដាំដំឡូងៗ លើកប្រឡាយ ដាំដំឡូង ដាំបន្លែ ពរ។

**ស៖** ព្រះអង្គអាចបញ្ជាក់ផងទេថា តើការជីកប្រឡាយ ដាំដំឡូង ដាំបន្លែនេះ វាខុសនឹងពុទ្ធបញ្ញត្តិដែរឬទេ?

**ឆ៖** រឿងទាំងអស់នេះ បើយើងគិតទៅលើច្បាប់ពុទ្ធសាសនាហៅថា វិន័យ ពរ។ ព្រះសង្ឃជីកដីខុស ខុសវិន័យ ដាំបន្លែខុសពីជីកដី ដាំដំឡូងខុសពីជីកដី ខុសៗៗវិន័យ ពរ។

**ស៖** បាទ សូមអរព្រះគុណ។ ព្រះអង្គអាចបញ្ជាក់ថា អាហ្នឹងជាវិន័យ ខុសវិន័យហ្នឹង ជាប្រភេទវិន័យយ៉ាងម៉េច? វាជាការដាច់អាបត្តិ ឬមួយក៏ជាក្នុងលក្ខខណ្ឌអ្វីដែលត្រូវហាមឃាត់សម្រាប់ព្រះសង្ឃដែរទេ?

[១៥:០៥:១២]

**ឆ៖** វាហាម មកហាម ហាមមិនឱ្យព្រះសង្ឃធ្វើទេកន្លែងហ្នឹង។ និយាយឱ្យចំវាហៅថា អាបត្តិបសុទិយៈ ពរ ឧកាបាដេ មិនគរុទេ លហុក្រាបប្រណិប័តន៍ពរ។

**ស៖** បាទ សូមព្រះអរគុណ។ ទាក់ទងទៅនឹងការលាចាកសិក្ខាបទរបស់ព្រះអង្គ ព្រះអង្គអាចបញ្ជាក់បានទេ ថានៅពេលនោះ តើព្រះអង្គធ្វើដូចម្តេចដែរ ទាក់ទងទៅនឹងអាការលាចាកសិក្ខាបទនៅថ្ងៃចុងក្រោយ ដែលព្រះអង្គឈប់ក្លាយជាភេទសង្ឃហ្នឹង?

**ឆ៖** ចម្រើនពរ ភេទអ្នកបួសក្លាយទៅ*(ឮមិនច្បាស់)* ឱ្យមានកសិណម្នាក់អ្នកដឹងឮ រកមនុស្ស

ត្រឹមត្រូវ កុំឲ្យឆ្គួតបានហើយ បាសកទៅសឹក សឹកបានហើយ ពរ។ មានកសិណសាក្សីដឹងឮថា នេះសឹកហើយៗ កុំឲ្យមនុស្សឆ្គួត មិនយកជាការបានទេ មិនត្រឹមត្រូវ ដឹងឮ បានកសិណសាក្សី ទៅបានហើយ ប៉ុណ្ណឹង។

[១៥:០៦:២៨]

**ស៖** ករុណា ចុះសម្រាប់ព្រះអង្គផ្ទាល់ តើអ្នកណាជាកសិណរបស់ព្រះអង្គ នៅពេលដែលព្រះអង្គលាចាកសិក្ខាបទ?

**ឆ៖** គ្នីគ្នានៅនឹងគ្នាហ្នឹង ដឹងឮ ព្រោះមិត្តភក្តិគ្នានៅជាមួយគ្នាហ្នឹង ធ្វើការជាមួយគ្នា ពរ ដឹងហើយ។ តៗគ្នាទៅ បន្តិចនោះសឹកៗ សឹកៗតៗគ្នាទៅ។

**ស៖** ករុណាចង់ទូលព្រះអង្គ ទាក់ទងនឹងព្រះអង្គផ្ទាល់ នៅពេលដែលព្រះអង្គសឹកថា តើព្រះអង្គមានគ្រូឧបជ្ឈាអ្នកឲ្យសឹក អ្នកឲ្យអ្វីដែលសម្រាប់ឲ្យសឹក ឬមួយក៏ព្រះអង្គសឹកនៅទីកន្លែងណាដោយឯកឯង?

**ឆ៖** សឹកនៅវត្តអារាម មិនមែនសឹកនៅតាមផ្ទះតាមសម្បែងទេ សម័យនោះ ពរ។ ព្រោះយើងតាំងខ្លួនយើងជាអ្នកបួសត្រឹមត្រូវ បួសមុខឧបជ្ឈាត្រឹមត្រូវ មិនមែនសឹកពីសពាសទេ សឹករកវត្តអារាមត្រឹមត្រូវ។ ព្រោះពេលសឹកហ្នឹងមិនទាន់មាន មិនទាន់គេ មិនទាន់រើបដិមាករទេ មិនទាន់រើរូបទេ នៅទេ នៅមានព្រះក្នុងវិហារ សាលាឆាន់នៅមានទាំងអស់ ពរ។ យើងយកព្រះរតនត្រ័យទាំងបី ពរ ហើយមានសកិណសាក្សីយើងដឹងឮ ថាឥឡូវសឹកហើយ ពរ។

**ស៖** អរគុណព្រះគុណ។ ករុណាចង់ទូលព្រះអង្គថា ដែលពេលព្រះអង្គសឹកនោះ អ្នកណាជាសាក្សីរបស់ព្រះអង្គ នៅពេលដែលព្រះអង្គផ្ទាល់ព្រះអង្គឯង សឹកលាចាកសិក្ខាបទហ្នឹងណ៎ា ព្រះអង្គអាចជម្រាបជូនអង្គជំនុំជម្រះបានទេ?

[១៥:០៨:២៣]

**ឆ៖** អីមិនបាន ឧបជ្ឈាអាត្មាកសិណសាក្សី។

**ស៖** បាទ សូមអរព្រះគុណព្រះអង្គ។ ករុណាចង់សួរបញ្ជាក់ព្រះអង្គទាក់ទងចំណុចមួយដែលព្រះអង្គបានសង្ឃដីការួចហើយ ទាក់ទងទៅនឹងពាក្យករុណាបានសួរ ការសឹក ហើយនិងករុណាចង់សួរពីការផ្សឹក ហើយនិងការលាចាកសក្ខិបទ។ ហើយសម្រាប់ពាក្យខ្មែរហ្នឹង វាមាន "សឹក" មាន "ផ្សឹក" ហើយនិងមាន "ការលាចាកសិក្ខាបទ"។ ព្រះអង្គអាចបញ្ជាក់ពាក្យទាំងបីនេះបានទេ ពីព្រោះពីមុន ខ្ញុំ

កុរុណាសួរពាក្យពីរ។ សូមនិមន្តព្រះអង្គ។

**ឆ៖** ផ្សឹក សឹក ចាកសិក្ខាបទ ពរ។ ចាក គឺបរិច្ចាគ។ យើងលាព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទៅជាភាវៈជាឧបាសក ពរ។ ហ្នឹងសឹកហើយណ៎ា ដល់ចាកធម៌ហើយ ចាកណ៎ា ព្រោះចាក ពរ។ ពាក្យទាំងអស់ហ្នឹង ទីបញ្ចប់មកនៅត្រឹមតែសឹកដដែលទេ ពរ។ សឹកក៏អ៊ីចឹង តែប៉ុណ្ណឹង មិនបាច់និយាយច្រើនពេកទេ ពរ និយាយប៉ុណ្ណឹងបានហើយ ពរ។ នៅត្រឹមដដែលហ្នឹង នៅតែសឹកដដែលហ្នឹង ពរ។ ចាកសិក្ខាបទក៏សឹក។ ផ្សឹក ក៏សឹក ពរ ដូចតែគ្នាទេ។ ទីបញ្ចប់ គឺបាសកដូចគ្នា ពរ។ គ្រាន់ជានាម គ្រាន់ជាគុណកិរិយាប៉ុណ្ណឹងទេ ពរ។ ខុសគ្នាតែពាក្យខ្មែរទេ ប៉ុណ្ណឹងទេ។

[១៥:១០:១៣]

**ស៖** អរព្រះគុណព្រះអង្គ។ ចុះបើករុណាថែមពាក្យនេះមួយ គេចំណាំនិយាយពាក្យថា "ចាប់ផ្សឹក" ឬក៏ "ផ្សឹកដោយបង្ខំ" "ចាប់ផ្សឹក"។ ថាតើវាមានអត្ថន័យខុសគ្នាខាងដើមពីពាក្យដែលព្រះអង្គមានថេរៈដីកាអំមិញទេ?

**ឆ៖** គឺមានបុគ្គលណាម្នាក់ប្រើអាជ្ញាឲ្យអ្នកបួសណាម្នាក់សឹកទៅជាឧបាសកពរ ហើយសម័យប៉ុល ពត គឺអ៊ីចឹងតែម្តង សម័យ ប៉ុល ពត គឺអាជ្ញាអ៊ីចឹងតែម្តងៗ ត្រូវតែសឹក នៅមិនបានទេ ពរ ត្រូវតែសឹក។ អ្នកបួសអត់នៅបានទេ បដិវត្តន៍ៗកសិកម្ម។ នេះជម្រាបអ៊ីចឹងតែម្តង។

**ស៖** បាទ សូមអរព្រះគុណ។ ពីព្រឹកមិញព្រះអង្គបានលើកឡើងថា ព្រះអង្គស្គាល់លោក ខៀវ នៅ។ តើព្រះអង្គនៅចាំឈ្មោះនេះទេ ដែលព្រះអង្គថាគង់កាលពីមុន ៧៥នោះ គង់នៅវត្តមហាមន្ត្រី។ តើអ៊ីចឹងត្រឹមត្រូវទេព្រះអង្គ?

**ឆ៖** កាលហ្នឹងៗ គាត់នៅមហាមន្ត្រីបួសដូចគ្នា ពរ មហាមន្ត្រី។

**ស៖** ព្រះអង្គស្គាល់លោក ខៀវ នៅ ហ្នឹងបួសជាព្រះសង្ឃយូរវស្សាប៉ុនណាដែរទេ?

**ឆ៖** ស្គាល់ហ្នឹង ដោយសារនៅភ្នំពេញដូចគ្នា ពរ។ ត្រង់លោកបួសប៉ុន្មានវស្សា អាត្មាមិនបានដឹងទេ ប៉ុន្តែស្គាល់នៅភ្នំពេញដូចគ្នា នៅរៀននៅភ្នំពេញដូចគ្នា។

**ស៖** បាទ សូមអរគុណព្រះអង្គ។ ករុណាសូមអានជូននូវសក្ខីកម្មរបស់លោក ខៀវ នៅ លេខ E1/90.1 ត្រង់ម៉ោង ០៩:៣០:១៥ ដែលជាប្រតិចារឹកចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២។ ខ្ញុំករុណាសូមអានជូនព្រះអង្គ ដកស្រង់៖ "ដាក់កំណត់ឲ្យច្បាស់លាស់មិនបានទេ ប៉ុន្តែមើលទៅមិនយូរទេ ពេលនោះប្រហែលជា១ឆ្នាំ ២ឆ្នាំប៉ុណ្ណោះ" (សូមទោស)។

**លោក គង់ សំអុន៖**

សូមទោស លោកប្រធានខ្ញុំសុំអនុញ្ញាតពិនិត្យឯកសារសិន។

[១៥:១៣:៤៣]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមបញ្ជាក់ម្តងទៀត ម៉ោង -- នៅម៉ោង ០៩:៣៨:២៤ ឯកសារដដែល គឺខុសគ្នាតែមួយទំព័រទេជាភាសាខ្មែរ។ សួរ សូមអានជូន -- សូមទោសឆ្លើយ៖ "ខ្ញុំមិនបានដឹងទេដល់ចាមអីនោះ។ ខ្ញុំមិនដឹងទេ។ ដឹងជាផ្លូវការមែនទែនគឺមិនដឹង។ មួយទៀតលោកប្រើពាក្យចាប់ផ្សឹក អត់មានចាប់ទេ គ្រាន់តែប្រាប់ឲ្យលាចាកសិក្ខា។ ប្រើពាក្យថាចាប់ ហ្នឹងហួសហើយ អត់ឃើញចាប់ មិនឃើញចាប់ ហើយមិនឮថាចាប់។" ព្រះអង្គស្តាប់បានទេ ថាតើព្រះអង្គមានប្រតិកម្មយ៉ាងដូចម្តេចទៅនឹងសក្ខីកម្មរបស់លោក ខៀវ នៅ នេះ?

**ព្រះតេជព្រះគុណ ឯម រឿង៖**

**ឆ៖** ព្រោះរឿងរបស់គាត់ទេហ្នឹង គាត់អ្នកដោះសាររបស់គាត់ទេហ្នឹង។ រឿងអាត្មាផ្សេង រឿងគាត់ផ្សេង។

**ស៖** ព្រះអង្គមានអ្វីចង់មានថេរៈដីកាអ្វីបន្ថែមទៅលើពាក្យថា "ចាប់សឹក" ហើយនិង "លាចាកសិក្ខាបទ" នេះដែរទេ?

[១៥:១៥:១៦]

**ឆ៖** សូមជម្រាបអ៊ីចេះថា ចាប់គឺមានបុគ្គលណាមួយមកបង្ខំៗ បង្ខំឲ្យៗចាកសិក្ខាបទ ឲ្យសឹកពរៗ។ មួយចាកដោយខ្លួនឯង គេគ្រាន់តែណែនាំប្រាប់ប្រាមទៅ ក៏សឹកទៅ។ មួយទៀតគេបង្ខំ ត្រូវតែសឹកនៅមិនបានទេ។ គេដឹងតែអ៊ីចឹង។

**ស៖** ករុណា សូមអរព្រះគុណ។ ចុះទាក់ទងនឹងករណីរបស់ព្រះអង្គផ្ទាល់ ដែលព្រះអង្គបានលាចាកសិក្ខាបទនៅចំពោះព្រះភក្ត្ររបស់គ្រូឧបជ្ឈារបស់ព្រះអង្គ។ តើព្រះអង្គអាចពន្យល់ថា វាជាការចាប់ផ្សឹកដែរទេ?

**ឆ៖** សូមចម្រើនពរ អ៊ីចេះថា ខាងដើមវាមានហេតុរួចហើយ បានខាងចុងមានបច្ច័យ ពរ។ គឺកុំតែមានហេតុ អត់មានបច្ច័យទេណ៎ា ស្តាប់បានទេពរ ប៉ុណ្ណឹងបាន ពរ។

**ប្រធានអង្គជំនុំ៖**

ទៅមុខទៀត លោកមេធាវី!

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ព្រះអង្គអាចជម្រាបបានពីពេលវេលាដែលព្រះអង្គចេញពីវត្តអង្គរកាទៅ តើព្រះអង្គទៅចេញទៅណា ក្រោយពីលាចាកសិក្ខាបទ?

**ព្រះតេជព្រះគុណ ឯម ភឿង៖**

**ឆ៖** មកស្រុកបន្ទាយមាសៗ ខេត្តកំពត។

**ស៖** ឃុំ សហករណ៍អីដែរ ព្រះអង្គ?

**ឆ៖** សហករណ៍ឃុំសំរោង ស្រុកបន្ទាយមាស។

**ស៖** ព្រះអង្គគង់នៅ -- រស់នៅកន្លែងហ្នឹងរហូត ឬមួយក៏ព្រះអង្គកាលនុំងបានប្ដូរទីកន្លែររស់នៅដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ ព្រះតេជព្រះគុណ!

**ព្រះតេជព្រះគុណ ឯម មឿង៖**

**ឆ៖** កន្លែងនេះកន្លែងមូលដ្ឋាន ក៏ប៉ុនវាឲ្យចល័តរហូតពរ។ ព្រោះអាត្មាកងចល័ត កងឈានមុខរហូតទល់គ្នានឹងបែក៧៥ តែម្ដង។ ចល័តរហូតរបស់ចល័តរហូត ព្រោះកន្លែងនេះជាកន្លែងមូលដ្ឋាន។

[១៥:១៨:១៦]

**សួរដោយលោក គង់ សំអុន៖**

**ស៖** ពេលព្រះអង្គៗ នៅក្នុងស្រុកបន្ទាយមាសហ្នឹង -- បន្ទាយមាស ឬទូកមាស ព្រះអង្គសូម?

**ឆ៖** ស្រុកបន្ទាយមាស ពរ។

**ស៖** ករុណា។ បន្ទាយមាសហ្នឹង ព្រះអង្គមានដូរទៅដូរឃុំ ដូរភូមិ ឬក៏ដូរស្រុកទៅផ្សេងទៀតទេ បន្ទាប់ពីការរស់នៅៗស្រុកបន្ទាយមាសនោះ?

**ឆ៖** អត់មានដូរទេពរ។

**ស៖** មុននេះ ព្រះអង្គមានថេរៈដីកាអំពីពាក្យថា “អង្គការ” ជាច្រើនលើកដែលព្រះអង្គ ពេលដែលគេហៅប្រជុំ ព្រះអង្គក៏មានសង្ឃដីកាថា អង្គការជាអ្នកចាត់ចែងហៅប្រជុំ ឬក៏ធ្វើសេចក្ដីសម្រេចអីជាដើម។ ព្រះអង្គ ក្នុងនាមព្រះអង្គផ្ទាល់ ក្នុងពេលនោះ តើព្រះអង្គយល់ថាពាក្យ “អង្គការ” នេះ ព្រះអង្គ

សំដៅទៅលើអ្វីដែរទេ?

**ឆ៖** ចម្រើនពរ ពេលហ្នឹងដូចអាត្មាមិនយល់អីទេ "អង្គការ" ហ្នឹង មិនដឹងអង្គការថ្នាក់ណាៗ អត់ដឹងផង។ មកប្រធានភូមិថា "អង្គការៗ អង្គការ*(ឮមិនច្បាស់)*" មិនដឹងនៅឯណាអង្គការ មិនដែលឃើញផង អង្គការនៅឯណា អត់ដឹង។ សួរពីណាឲ្យធ្វើ ថា "អង្គការឲ្យធ្វើ អង្គការចាត់តាំង"។ មិនដឹងនៅឯណាអង្គការ អត់ដឹងផង។

**ស៖**ករុណា ព្រះអង្គមានបានពិភាក្សា ឬក៏សួរនាំថា តើអង្គការជាអ្នកណា? ជាអ្វី? ឬក៏ជាអ្នកទទួលខុសត្រូវយ៉ាងដូចម្ដេចដែរទេ ក្នុងពេលនុ៎ង?

[១៥:២០:០៧]

**ឆ៖** ចម្រើនពរ ពេលហ្នឹងមានសួរដែរ សួរអង្គការហ្នឹងនៅឯណាទៅ? ថ្នាក់ណាដែលថ្នាក់លើ? ពរ។ សួរគេទៅ គេថា "បើដឹងអង្គការនៅឯណា អ្នកណាខ្លះអង្គការ ថ្នាក់លើមិនដឹងថ្នាក់លើនៅៗឯណា?" អាត្មាមិនដឹងដែរ ដល់អាហ្នឹងគេថាអាហ្នឹងថ្នាក់លើៗទៅ អ៊ីចឹងចប់ហើយពរ។ អត់ដេញដោលគេទេ មិនប៊ានដេញដោលទេ ដេញដោលច្រើនពេក គេថាដឹងច្រើនម្ល៉េះ ចេះអី អាហ្នឹងអត់ទេ មិនបាច់ឲ្យនៅទេ។ ដឹងថាអង្គការចប់ហើយ។

**ស៖** សម្រាប់ព្រះអង្គផ្ទាល់ តើព្រះអង្គយល់ថាអង្គការជាអ្វីទៅ?

**ឆ៖** គឺជាៗ ពាក្យមួយនៅសម័យនោះ ពាក្យមួយពរ ជាពាក្យមួយសម័យ ប៉ុល ពត ហ្នឹង គេប្រើអង្គការហ្នឹងពរ ពាក្យហ្នឹង ពរ។ ប៉ុន្តែពាក្យ "អង្គការ" នេះ អង្គការហ្នឹង មិនដឹងជាបុគ្គលណាខ្លះទេ អង្គការហ្នឹង អាត្មាមិនដឹងអីទេ ពរ។ គេថា "អង្គការមជ្ឈិមៗ ចាត់តាំងមក" ពរ ប៉ុន្តែអង្គការហ្នឹងបុគ្គលណាខ្លះៗ នៅមជ្ឈិមហ្នឹងចាត់តាំងមក មិនដឹងៗទេ ពរ។ សួរប្រធានភូមិៗថា "បងអ្នំា! អង្គការនៅឯណាវ៉ឺ? ចាត់តាំងមិនឈប់មិនឈរម្ល៉េះវ៉ឺ?" គេថា "ថ្នាក់លើ ខ្ញុំក៏មិនស្គាល់ដែរទេ ថ្នាក់លើ អង្គការថ្នាក់លើៗចាត់តាំងមកអ៊ីចឹង"។ ហ្នឹងចប់ហើយ អត់ប៊ានសួរទេ ប៉ុណ្ណឹងចប់ហើយ អត់ប៊ានសួរទេ។

**ស៖** បាទ សូមអរគុណព្រះអង្គ។ តើព្រះអង្គមានដែលឮអ្នកដែលនិយាយពីអង្គការហ្នឹង គេសំដៅទៅលើខ្លួនគេ ឧទាហរណ៍ដូច គណៈឃុំ ឬក៏ភូមិ ឬក៏សហករណ៍ ឬអ្នកណាដែលជួបទាក់ទងជាមួយព្រះអង្គថាគេជាអង្គការដែរទេ?

**ឆ៖** គេថាថ្នាក់លើប៉ុណ្ណឹងចប់ហើយ ឆ្លើយថ្នាក់លើ។ ពរ សួរគេទៅ គេថាថ្នាក់លើអង្គការថ្នាក់លើ ចាត់តាំងមកបញ្ជាមក។ គេនិយាយតែប៉ុណ្ណឹង ហើយមិនប៊ានដេញដោលសួរច្រើនផង មិនប៊ាន

ដេញដោលសួរផង សួរច្រើនពេកទៅខ្លាចគេរករឿងទៀត ថាយើងចង់ចេះដឹងអី អ៊ីចេះនេះ ជំនាន់ហ្នឹង អ៊ីចឹង។

[១៥:២២:៣៤]

**ស៖** បាទ សូមអរគុណព្រះអង្គ។ តើព្រះអង្គយល់ពីការសម្ងាត់យ៉ាងដូចម្ដេចដែរ? ហើយបានអនុវត្តយ៉ាងដូចម្ដេចដែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង។

**ឆ៖** ពរ មានប្រសាសន៍ម្ដងទៀត ដើម្បីបញ្ជាក់គ្នា។

**ស៖** មុននេះព្រះអង្គមានថេរៈដីកាថា មិនហ៊ានសួរ មិនហ៊ាននិយាយ ហើយករុណាចង់សួរបញ្ជាក់ថា តើព្រះអង្គធ្លាប់ឮពីគោលការណ៍នៃការសម្ងាត់ដែរឬទេ? ហើយព្រះអង្គធ្លាប់អនុវត្តយ៉ាងដូចម្ដេចដែរ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ដល់ចំណោទនេះអាត្មាស្ដាប់មិនទាន់បាន ដូចស្ដាប់មិនទាន់បាន មិនដឹងចង់ៗដឹងពីរឿងអីសួរឆ្ងល់សួរមកហ្នឹង ចង់ឲ្យអាត្មាបញ្ជាក់ពីរឿងអី?

**ស៖** ករុណា ចង់សួរជាទូទៅ តើព្រះអង្គអាចប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ជាមួយកម្មាភិបាល ឬជាមួយមិត្តភក្តិអីបានដោយសេរីដែរទេ?

[១៥:២៤:០៣]

**ឆ៖** ចម្រើនពរ សម័យ ៣ឆ្នាំ ៨ខែ ២០ថ្ងៃហ្នឹង ទំនាក់ទំនងហ្នឹងដូចជាមិនសូវមានទេ ពរ។ មិនសូវមានទេ សូម្បីតែបងប្អូនឯងហ្នឹងក៏ស្ទើតែមិនហ៊ាននិយាយរកគ្នាផង ពរ សម័យនោះ។ ហ្នឹងនិយាយត្រង់តែម្ដង កន្លែងអាត្មាគឺអ៊ីចឹងហ្នង កន្លែងអាត្មា។ យប់ឡើងមិនហ៊ានដែលនិយាយចូលគ្នាទេ ពេលធ្វើការ ធ្វើរៀងខ្លួន ពេលសម្រាកគឺសម្រាកដេកក្រើបពរ ត្រូវដល់ម៉ោងឡើងធ្វើទៀត អត់ហ៊ានព្រោកប្រាជ្ញគ្នាទេ មិនហ៊ានព្រោកប្រាជ្ញ សួរមនុស្ស អត់ទេអីអត់មានទេ ហ្នឹងសម័យហ្នឹងគឺពរ។ កាលណាអ្នកនិយាយច្រើន អ្នកហ្នឹងរឿងច្រើនជាងគេ និយាយច្រើនគឺត្រូវគ្រោះថ្នាក់ ពរ។ សូមជម្រាបអ៊ីចឹងតែម្ដង ព្រោះកន្លែងអាត្មាគឺអ៊ីចឹងតែម្ដង អ្នកណានិយាយច្រើន អ្នកណាចេះដឹងច្រើនជាងគេអ្នកហ្នឹងគ្រោះថ្នាក់ហើយ បើល្ងង់គួរសមបន្តិចល្ងង់ ពរ អាត្មាធ្វើល្ងង់ហ្នឹងជំនាន់ហ្នឹងបានៗរស់ ទាំងអស់។

**លោក គង់ សំអុន៖**

បាទ សូមអរព្រះគុណព្រះអង្គ ហើយករុណាអស់សំណួរហើយ។ លោកប្រធាន ខ្ញុំសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

បាទ ព្រះតេជព្រះគុណ ឯម ភឿង អង្គជំនុំជម្រះសូមអរគុណចំពោះព្រះតេជព្រះគុណដែលបាននិមន្តមកដល់ផ្តល់សក្ខីកម្មជូនដល់អង្គជំនុំជម្រះសាលាដំបូងក្នុងរយៈពេលមួយថ្ងៃនេះ។ ហើយសក្ខីកម្មរបស់ព្រះអង្គនឹងរួមវិភាគទានក្នុងការស្វែងរកការពិតនៅក្នុងរឿងក្តីនេះ។ ឥឡូវនេះ រហូតដល់ពេលនេះ បានដល់ទីបញ្ចប់ហើយ ហើយវត្តមានរបស់ព្រះអង្គនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ។ ព្រះតេជព្រះគុណអាចវិលត្រលប់ទៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនព្រះតេជព្រះគុណ ឯម ភឿង វិលត្រលប់ទៅកាន់ទីវត្តអារាមដែលព្រះអង្គគង់នៅ ឬក៏ទីកន្លែងគោលដៅណាដែលព្រះអង្គមានបំណងចង់ទៅបានហើយ។

ព្រះតេជព្រះគុណនិមន្ត។

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[១៥:២៦:៤០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ដោយយាសារថាយើងមានពេលកន្លះម៉ោងទៀត ជាជាងការពិនិត្យ <ឡើងវិញអំពីបញ្ហាព្រឹកមិញនេះ>នៅថ្ងៃស្អែក <ដោយយកពេលវេលារបស់ភាគីក្នុងការសួរដេញដោលសាក្សីសម្រាប់ថ្ងៃស្អែកនោះ។> ខ្ញុំសូមយោងទៅអ៊ីម៉ែលដែលបានទទួលពីសហព្រះរាជអាជ្ញានៅថ្ងៃរសៀលហ្នឹងទាក់ទងនឹងឯកសារនៅក្នុងសំណុំរឿង០០៤។ សហព្រះរាជអាជ្ញារងបានសរសេរមកកាន់លោកប្រធាន និងមកកាន់មេធាវីការពារក្តីបន្ថែមទៅលើ<កំណត់ហេតុស្តាប់ចម្លើយសាក្សី>មុន <ដែលយកចេញពី>ក្នុងសំណុំរឿង០០៤ <គឺមានចំនួន២០ គឺ>អ៊ីម៉ែលដែលយើងទើបទទួលនៅរសៀលនេះ គឺមាន១<ចំនួនច្រើនផ្សេងទៀត គឺ>ឯកសារ៨៩ និង<>១៩០ទៀត <ដែលនឹងយកចេញពីសំណុំរឿង០០៤ ដាក់បញ្ចូលនៅក្នុងសំណុំរឿងនេះ។ គឺមានចំនួន ៨៩ និង១៩០ បូកនឹងឯកសារមុនទៀត គឺ>សរុបទាំងអស់គឺមានរហូតដល់<៣៣៤>ឯកសារពីសំណុំរឿង០០៤ ដែលត្រូវយកមកប្រើនៅក្នុងសំណុំរឿងនេះ។ <យើងអាចមើលត្រួសៗប៉ុណ្ណោះចំពោះ>ឯកសារ២០ <នៃសំណុំរឿង០០៤> ដែលយើងខ្ញុំបានទទួលនៅថ្ងៃរសៀលនេះ ខ្ញុំគ្រាន់តែបង្ហាញសង្ខេបទេ ដែលយើងខ្ញុំយល់ឃើញថា សាក្សីម្នាក់បានផ្តល់

សក្ខីកម្មអំពី<ថ្នាក់>ដឹកនាំនៅស្រុកត្រាំកក់។ សាក្សីម្នាក់អាចផ្ដល់សក្ខីកម្មជាលម្អិតអំពីអតីតលេខាស្រុក១០៥ និងសាក្សីម្នាក់ទៀតជាមេឃុំ<មួយ នៅក្នុងស្រុកត្រាំកក់> ប្រហែលជាអាចផ្ដល់សក្ខីកម្មទៅនឹង<>សាក្សី<មួយចំនួនដែលនឹងមកនាពេលខាងមុខ ដែលម្នាក់ជា>នីរសារមកពីស្រុកត្រាំកក់អាចផ្ដល់សក្ខីកម្មទៅលើកម្មាភិបាល<ម្នាក់ និងអំពី>ការចែកចាយលិខិតស្នាមនានា <ទៅកាន់ឃុំនានា នៅក្នុង>ស្រុកត្រាំកក់។ <វាហាក់បីដូចជា យ៉ាងហោចណាស់ក៏មាន>សាក្សីម្នាក់<>នៅក្នុងចំណោម<កំណត់ហេតុស្ដាប់ចម្លើយសាក្សីចំនួន២០នោះ> គឺ<ជាអ្នកទោស>ដែលរស់រានមានជីវិតពីគុកក្រាំងតាចាន់ <ហើយកូនរបស់អ្នកទោសនោះត្រូវបានសម្លាប់នៅក្រាំងតាចាន់>។

ខ្ញុំយល់ឃើញថាចម្លើយទាំងអស់នេះ វាមានការពាក់ព័ន្ធទៅនឹងសាក្សីដែលត្រូវចូលខ្លួនមកនេះ។ ហើយយើងខ្ញុំក៏កំពុងតែរង់ចាំយ៉ាងហោចណាស់ឯកសារចំនួន២៧០ទៀតដែរ ដែលត្រូវយកមកប្រើប្រាស់<នៅក្នុងសវនាការវគ្គនេះ>។ ខ្ញុំមិនដឹងថាត្រូវប្រើពាក្យពេចន៍ណាដើម្បីរៀបរាប់អំពីចំនួនឯកសារទាំងអស់នេះ ហើយមិនដឹងដោះស្រាយរបៀបណានោះទេ។ ប៉ុន្តែលទ្ធភាពពិតដែលអាចធ្វើទៅបាន គឺត្រូវអនុញ្ញាតឲ្យមេធាវីការពារក្ដីក្នុងការស្នើសុំពន្យារកិច្ចដំណើរការនីតិវិធី ដើម្បីពិនិត្យទៅលើឯកសារទាំង២៧០ហ្នឹង ដើម្បីរកឲ្យឃើញថាតើវាមានការពាក់ព័ន្ធយ៉ាងណានោះ។ បើយើងបន្តកិច្ចដំណើរការនីតិវិធីបែបនេះ ហើយយើងគ្រាន់តែបង្ហាញឯកសារមួយចំនួនតូច ឬក៏គ្រាន់តែហុចឯកសារទៅវិញទៅមក <ហើយនៅពេលដែលយើងមានឯកសារទាំងអស់នោះហើយ គឺយើងអាចនឹងត្រូវកោះហៅសាក្សីទាំងអស់នោះម្ដងទៀត>។ ដូច្នេះ ខ្ញុំមិនដឹងថា មធ្យោបាយដោះស្រាយត្រឹមត្រូវត្រូវធ្វើយ៉ាងណានោះទេ។ <ក៏ប៉ុន្តែមធ្យោបាយនោះ គឺត្រូវបន្តដំណើរការទៅមុខនោះ ចុះបើក្នុងករណីដែលវាផ្ទុយអំពីអ្វីដែលបាននិយាយដោយសហព្រះរាជអាជ្ញាមុននេះ ថាវាមានចំនួនតិចទេ ប៉ុន្តែចំនួនសរុបបែរជាមាន> ៣៣៤ <ឯកសារឯណោះ គឺដូចដែលខ្ញុំនិយាយអ៊ីចឹង គឺវាជាការរំខានណាស់។> ខ្ញុំយល់ឃើញថា គួរតែមានការពិភាក្សាគ្នាឲ្យបានត្រឹមត្រូវ ថាតើត្រូវដោះស្រាយបញ្ហាទាំងនេះដោយរបៀបណា?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីការពារក្ដីលោក ខៀវ សំផន!

សហព្រះរាអាជ្ញារងអង្គុយចុះសិន ចាំស្ដាប់ភាគីម្ខាងឲ្យអស់សិន ហើយត្រៀមលក្ខណៈសម្បត្តិឲ្យសមស្រប ដើម្បីធ្វើការឆ្លើយតបខ្លី ដោះស្រាយបញ្ហា ដើម្បីអង្គជំនុំជម្រះមានមូលដ្ឋានក្នុងការយកបញ្ហានេះទៅដោះស្រាយ ថាគួរតើចាត់ការយ៉ាងម៉េច?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[១៥:៣១:០៣]

**កញ្ញា អង់គា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំគាំទ្រដូចព្រឹកមិញដែរ ទៅនឹងការសង្កេតរបស់លោក កូប៉េ គឺយើងក៏មានការព្រួយបារម្ភបែបនេះដែរ។ ដូចដែលខ្ញុំបានលើកឡើងកាលពីព្រឹកមិញហ្នឹង យើងមានបញ្ហា<ជាក់ច្បាស់មួយ គឺ>ពាក់ព័ន្ធទៅនឹងការរៀបចំខ្លួន សម្រេបទៅនឹងអ្វីដែលត្រូវបានចាត់ទុកថា វាមានភាពពាក់ព័ន្ធទៅនឹងឯកសារទាំងនោះ <សម្រាប់សាក្សីទាំងឡាយដែលនឹងមកផ្ដល់សក្ខីកម្មនាពេលឆាប់ៗនេះ>។ ឯកសារទាំងនោះមិនមែនថា និយាយអំពីសាក្សីណាមួយជាក់លាក់នោះទេ ចំពោះយើង យើងគិតថា វាមិនមែនជាឯកសារពាក់ព័ន្ធប៉ុន្មានទេ ពីព្រោះថា នៅពេលដែលសាក្សីជាច្រើននិយាយអំពីកន្លែងតែមួយ <និងនិយាយអំពី>លក្ខខណ្ឌធ្វើការនៅក្នុងសហករណ៍ ឬក៏នៅក្នុងមន្ទីរសន្តិសុខ ចំពោះយើងនោះ ក្នុងក្របខ័ណ្ឌនៃការសួរសំណួរនោះ គឺយើងអាចតទល់បានទៅនឹងឯកសារ ហើយនិងសក្ខីកម្មជាច្រើន ដើម្បីឲ្យយើងអាចពិភាក្សាគ្នាឈានទៅមុខបាន<នៅទីនេះ នៅចំពោះមុខអង្គជំនុំជម្រះ>។

ទោះជាយ៉ាងណាក៏ដោយ យោងទៅតាមអ្វីដែលលោក កូប៉េ បានលើកឡើង ហើយនិង<បានរំឭកយើងនោះ គឺបានលើកឡើងថា --ខ្ញុំដឹងថា>ខាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី<ក៏ស្ថិតនៅក្នុងជំហរដូចគ្នាផង>ដែរ <ប៉ុន្តែបើសិនជាពួកគាត់អាចសម្របខ្លួននឹងស្ថានភាពនេះបាន គឺពួកគាត់មានសិទ្ធិធ្វើដូច្នោះបាន។ ប៉ុន្តែចំពោះខាង>យើងជាមេធាវីការពារក្ដី យើងត្រូវតែអាចមានភាពប្រមើលមើលបានទៅលើឯកសារដែលនឹងស្ថិតនៅក្នុងសំណុំរឿង ហើយដែលអាចឲ្យយើងសួរសាក្សីដែលនឹងមកនាពេលខាងមុខនោះ។ ដូច្នេះ យើងស្នើសុំឲ្យអង្គជំនុំជម្រះមេត្តាស្វែងរកដំណោះស្រាយឲ្យបានឆាប់រហ័ស ពីព្រោះថាយើងនៅមានសាក្សីស្ដីអំពីក្រាំងតាចាន់ និងត្រាំកក់ ដែលនឹងមកបន្ថែមទៀត។ ដូច្នេះ ឯកសារដែលបានដាក់នៅថ្ងៃនេះនោះ គឺយើងមិនអាចពិនិត្យមើលឲ្យបានលម្អិតបានទេ។ យើងត្រូវការពេលវេលាបន្ថែម ដើម្បីធ្វើការវិភាគទៅលើឯកសារទាំងនេះ។ ដូច្នេះ វាមានផលប៉ះពាល់ទៅលើការត្រៀមរៀបចំខ្លួនសម្រាប់សួរសាក្សីនាពេលខាងមុខនេះហើយ។ ហើយប្រសិនបើយើងឲ្យ -- ចង់ឲ្យមានការចំណេញពេលនោះ គឺថាយើងមិនគួរណាហៅសាក្សីមកហើយ ហើយបន្ទាប់មកហៅមកម្ដងទៀត ពីព្រោះថា យើងឃើញមានឯកសារពាក់ព័ន្ធនៅពេលក្រោយមកទៀតនោះទេ។ អ៊ីចឹងយើងមិនអាចហៅមកម្ដងហើយម្ដងទៀតទេ។ ដូច្នេះ ខ្ញុំគិតថា គួរតែអង្គជំនុំជម្រះធ្វើការសម្រេចមួយឲ្យបានជាក់លាក់ ឬមួយក៏អាចផ្ដល់ពេលវេលាឲ្យមេធាវីការពារក្ដីដើម្បីពិនិត្យមើលទៅលើឯកសារទាំងអស់នេះ។ ហើយ

ខាងដើមបណ្ដឹងរដ្ឋប្បវេណី គាត់ថា មិនបាច់ចាំមានត្រូវការពេលវេលាបែបនេះទេ ក៏ប៉ុន្តែយើងខាងការពារក្ដី គឺយើងចាំបាច់ត្រូវការពេលវេលាបែបនេះណាស់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៥:៣៣:៣៩]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ បន្ថែមទៅលើសំណូមពររបស់មេធាវី ក្រុមមេធាវីការពារក្ដីខ្ញុំបាទ សូមបង្ហាញពីការលំបាករបស់យើងក្នុងការពិនិត្យទៅលើឯកសារដែលបានកំណត់នៅក្នុងសំណុំរឿង០៣, ០០៤នេះ។ ដោយសារយើងខាងមេធាវីការពារក្ដីមិនមានលទ្ធភាពប្រើប្រាស់ជាអេឡិចត្រូនិកទេ។ ឯកសារជាអេឡិចត្រូនិក យើងអង់អាចចូលបានទេ ហើយយើងទទួលបានតែកូពី។ ឯកសារកូពីនេះ គឺយើងមានតែមួយកូពីទៀត ហើយយើងមិនត្រូវបានអនុញ្ញាតឲ្យធ្វើការកូពីបំបែកតទៀតទេ តាមលក្ខខណ្ឌនៃការប្រើប្រាស់ឯកសារទាំងអស់នេះ។ ដូច្នេះ ការប្រើប្រាស់នេះវាធ្វើឲ្យយើងមានការលំបាកមិនទាន់ពេលវេលា ខាតពេលវេលាច្រើន ហើយនៅពេលដែលឯកសារកាន់តែមានច្រើនទៅៗ ការប្រើប្រាស់នៅលើក្រដាស នៅហាតកូពីនេះ វាកាន់តែមានភាពស្មុគស្មាញសម្រាប់មេធាវីផងដែរ។ ដូច្នេះ បន្ថែមទៅលើសំណើរបស់ក្រុមមេធាវីការពារនេះ យើងខ្ញុំសូមឲ្យបន្ថយលក្ខខណ្ឌមួយចំនួនក្នុងការប្រើប្រាស់នេះ ដែលអនុញ្ញាតឲ្យយើងអាចប្រើជាឯកសារអេឡិចត្រូនិកបានផង ដែលវាអាចមានលក្ខណៈងាយស្រួលក្នុងការស្វែងរកឯកសារ និងត្រួតពិនិត្យទៅលើខ្លឹមសារជាដើម។ បាទ សូមអរគុណ។

[១៥:៣៤:៥៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មុននឹងផ្ដល់វេទិកា<ជូន>ទៅសហព្រះរាជអាជ្ញា ខ្ញុំមានសំណួរ<មួយ> ប្រហែលជាសហព្រះរាជអាជ្ញាគាត់អាចនឹងឆ្លើយផងដែរ<> នៅពេលដែលសហព្រះរាជអាជ្ញាទៅផ្ដល់យោបល់របស់ខ្លួន។ នៅក្នុងអ៊ីម៉ែល ដែលបានបញ្ជូនទៅឲ្យក្រុមមេធាវីការពារក្ដី ទី១និយាយថា សំណើសុំ គឺសុំឲ្យមានការបញ្ជាក់បន្ថែម<> ដែលនឹងដាក់នៅថ្ងៃទី២៣ កុម្ភៈ <ហើយចំណុចទី២ គឺលើកឡើងអំពីឯកសារចំនួន

៨៩ ដែលនឹងត្រូវដាក់បង្ហាញនាពេលខាងមុខឆាប់ៗនេះ។ ថាតើនៅក្នុងអ៊ីម៉ែលហ្នឹង មានន័យថាម៉េចនាពេលខាងមុខដ៏ឆាប់ហ្នឹង ឬក៏លោកនឹងធ្វើវានៅថ្ងៃនេះ តើ>អាចធ្វើបែបនេះបានទេ<។> នៅពេលដែលនិយាយសំដៅទៅលើឯកសារ១៩០ជាង <ខ្ញុំគិតថាវានៅកថាខណ្ឌចុងក្រោយ> នេះខ្ញុំស្មានទេ <ប៉ុន្តែនេះគឺជាសំណួរមួយ គឺថាឥឡូវនេះលោកមិនអាចប្រាប់យើងថា> ពេលណាដែលត្រូវបង្ហាញឯកសារនេះហើយដោយរបៀបណាទេ។> ហើយនេះគឺជាបណ្ដុំឯកសារទាំង១៩០ ដែលនឹងត្រូវដាក់យកមកបង្ហាញ ឬ -- ខ្ញុំដូចជាមិនយល់អំពីការរៀបចំនេះទេ? តើលោកតំណាងសហព្រះរាជអាជ្ញាអាចឆ្លើយនឹង<ទាំងនេះឥឡូវនេះបានដែរ ឬទេ>? ខ្ញុំដឹងថា នេះប្រហែលជាអ្វីដែលលោកមានផែនការនឹងធ្វើនៅ>ថ្ងៃចន្ទ ប៉ុន្តែ<-->

[១៥:៣៦:២៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកស្រីចៅក្រម។ ពិតណាស់ យើងបានបំភ្លឺអំពីដំណើរការដែលយើងកំពុងតែធ្វើ ហើយខ្ញុំចង់បញ្ជាក់ថា នេះជាភារកិច្ចដ៏ធ្ងន់ធ្ងរសម្រាប់ការិយាល័យសហព្រះរាជអាជ្ញាក្នុងការពិនិត្យមើលឯកសារមួយបាច់ៗ ដែលយើងទទួលបានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ <ដើម្បីដាក់បង្ហាញឯកសារទាំងអស់នេះ ទៅដល់ភាគី។> យើងត្រូវធ្វើសំណើបួនប្រាំផ្សេងគ្នា មុននឹងពេលដែលយើងបញ្ជូនឯកសារទៅ។ ពាក់ព័ន្ធទៅនឹងតួលេខដែលបានផ្ដល់ជូននោះ ខ្ញុំចង់បញ្ជាក់ជូនថា ក្នុងឯកសារទាំង៨៩ គឺឯកសារស្ដាប់ចម្លើយទាំង៨៩ ដែលយើងស្នើសុំ<ការអនុញ្ញាត>ពី<>សហចៅក្រមស៊ើបអង្កេត ដើម្បីផ្ញើជូនទៅឲ្យអង្គជំនុំជម្រះ និងភាគីនោះ គឺមានតែពីរប៉ុណ្ណោះដែលពាក់ព័ន្ធនឹងត្រាំកក់ ហើយនិងក្រាំងតាចាន់ ជាលក្ខណៈទូទៅ។ ហើយក្នុងចំណោមឯកសារទាំង៨៩នោះ មិនមានឯកសារណាមួយដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសាក្សី ដែលត្រូវបានជ្រើសរើសសម្រាប់យកមកផ្ដល់សក្ខីកម្មនៅក្នុងវគ្គទី១នេះទេ។

[១៥:៣៧:៤៦]

ពាក់ព័ន្ធនឹងឯកសារ១៩០វិញ យើងមិន<មានទាំងអស់នៅក្នុងដៃនោះទេ>។ យើងគ្រាន់តែអានឯកសារ នៅពេលដែលឯកសារមកដល់ ហើយយើងពិនិត្យមើលថាឯកសារណាដែលវាពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២ ហើយឯកសារណាខ្លះដែលអាចមានភស្តុតាងដោះបន្ទុក វាសំខាន់សម្រាប់មេធាវីការពារក្ដី។ ដូច្នេះ ពេលហ្នឹងហើយ យើងសូមការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតដើម្បីបញ្ជូនទៅ

ឲ្យភាគីផ្សេងៗ។ សហចៅក្រមស៊ើបអង្កេត និងក្រុមការងាររបស់គាត់ ជាអ្នកធ្វើការវិភាគទៅលើសំណើរបស់ពួកយើង ហើយពេលខ្លះ គាត់អត់ឯកភាពទេ ដោយសារតែវាជាការសម្ងាត់នៃការស៊ើបអង្កេត។ ដូច្នេះហើយមានការពន្យារពេល ហើយជួនកាលទៅពន្យារកាន់តែវែងទៅៗ។ ដូច្នេះ យើងបានទាញចំណាប់អារម្មណ៍សហចៅក្រមស៊ើបអង្កេតថា ប្រធានបទមួយចំនួននោះ គឺកំពុងតែត្រូវបានសិក្សាដោយអង្គជំនុំជម្រះនៅក្នុងសវនាការ។ ដូច្នេះ ពាក់ព័ន្ធនឹងឯកសារទាំងអស់នោះ គឺថាយើងត្រូវផ្ដល់<អាទិភាព>ទៅលើឯកសារហ្នឹង ដោយ<>សហចៅក្រមស៊ើបអង្កេត។ យើងមិនអាចបញ្ជាក់ឲ្យច្បាស់ថា តើនៅពេលណាដែលឯកសារទាំង១៩០នេះ ទទួលបានការអនុញ្ញាតក្នុងការចែកចាយជូនទៅភាគីទេ យើងមិនមែនជាអ្នកគ្រប់គ្រងទៅលើកាលវិភាគទាំងអស់នុំងទេ។ នៅពេលណាដែលយើងទទួលបាន គឺយើងតែងតែចែកជូនទៅឲ្យភាគីហើយ។ ដូច្នេះ<អ្វីដែលច្បាស់លាស់នោះ គឺនៅរាល់ពេលដែលយើងទទួលបានកំណត់ហេតុនៃការស្ដាប់ចម្លើយថ្មីៗ ដែលមានយោងនៅក្នុងសំណុំរឿងពីរផ្សេងទៀតនោះ> គឺយើង<អាន>ឲ្យបានលឿនទៅតាមលទ្ធភាពយើងដែលមាន ព្រោះយើងថាមាន យើងមានការងារផ្សេងទៀត ដែលត្រូវធ្វើផងដែរ។ យើងអាន -- យើងមិនអានភាសាខ្មែរទេ អ៊ីចឹងយើងត្រូវចាំពេលដែលមានការបកប្រែ។ អ៊ីចឹង បានយើងអាចអានកើត ហើយយើងអាននោះ គឺអានយ៉ាងប្រញាប់ទៀត នៅពេលឃើញដែលមានភាពពាក់ព័ន្ធហើយ យើងក៏ស្នើសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតដើម្បីផ្ញើជូនទៅភាគី។ ហើយការងារទាំងអស់ហ្នឹង សុទ្ធតែធ្វើ យើងធ្វើឡើងជាបន្ទាន់ ហើយការិយាសហចៅក្រមស៊ើបអង្កេតហ្នឹងគាត់ក៏មានកាតព្វកិច្ចក្នុងការធ្វើការងាររបស់គាត់។ ហើយអ៊ីចឹង យើងតែងតែសុំយ៉ាងទទូច ដើម្បីទទួលបានការអនុញ្ញាតឲ្យបានឆាប់ ក៏ប៉ុន្តែពេលខ្លះនោះ យើងត្រូវតែរង់ចាំពេលបានយូរទៀតទម្រាំតែមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតនោះ។

[១៥:៤០:២៨]

ដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្ដី ខ្ញុំសុំអនុញ្ញាតបញ្ជាក់ជូនថា ពួកគាត់ធ្វើហាក់ដូចជាភ្ញាក់ផ្អើលទៅនឹងតួលេខនេះ។ ខ្ញុំសូមរំឭកថា នៅក្នុងឯកសារដែលយើងបានផ្ញើជូន<អង្គជំនុំជម្រះនោះ>គឺ <E305.13> គឺជា<បញ្ជី>ឯកសារដែលពាក់ព័ន្ធទៅនឹងសំណុំរឿង00២/0២ យើងបាននិយាយតាំងពីខែមិថុនា ឆ្នាំ២០១៤ រួចមកហើយថា យ៉ាងហោចណាស់ក៏មាន<ចំនួន>២៦៧<កំណត់ហេតុនៃការ>ស្ដាប់ចម្លើយសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៣ និង០០៤ ដែលនឹងត្រូវដាក់បញ្ចូលមកក្នុងសំណុំរឿង<នេះ ពីព្រោះយើងជឿជាក់ថាកំណត់ហេតុនៃការស្ដាប់

ចម្លើយទាំងអស់នេះ>មានភាពពាក់ព័ន្ធ។ ដូច្នេះ ខ្ញុំដឹងថា ភាគីដឹងតាំងពីយូរណាស់មកហើយ ហើយយើងក៏មានការលំបាកផងដែរ ដោយសារតែយើងមិនបានទទួលការអនុញ្ញាតឆាប់រហ័សពីខាងការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ។

ខ្ញុំចង់បញ្ជាក់ជូនពាក់ព័ន្ធទៅនឹងតួលេខដែលថា ២៦៧ ហ្នឹងដែរគឺថា តាំងពីពេលហ្នឹងមកជារៀងរាល់ខែនោះ យើងប្រហែលជាទទួលបានឯកសារប្រហែលជា៣០ ដែល<បានប្រមូល>ដោយ<>សហចៅក្រមស៊ើបអង្កេត <ហើយដាក់នៅក្នុងសំណុំរឿង>។ ដូច្នេះ ខ្ញុំគិតថានៅមានឯកសារច្រើនទៀតលើសពី២៦៧ហ្នឹងទៅទៀត។ អ៊ីចឹង តួលេខនេះគឺប្រហាក់ប្រហែល គឺប្រហែលជាចន្លោះពី២០០ <> ទៅ៣០០ គឺប្រហែលជាជិត ៣០០ឯកសារឯណោះ <គឺច្រើនជាង២៦៧ឯកសារ>។

[១៥:៤២:០៧]

យើងគិតថានេះជាកាតព្វកិច្ចជាបន្តបន្ទាប់របស់យើង ឯកសារស្ដាប់ចម្លើយទាំងអស់ហ្នឹងនឹងមកដល់យើងបន្តបន្ទាប់មករហូតទៀត។ ដូច្នេះ យើងសុំជំទាស់ទៅហ្នឹងការពន្យារពេលសវនាការ ព្រោះថាយើងយល់អំពីការព្រួយបារម្ភរបស់ភាគីហើយ យើងផ្ទាល់នេះ ក៏យើងមានបន្ទុកការងារបន្ថែមទៀតដែរ។ ដូច្នេះ ចំណុចអ្វីដែលខ្ញុំអាចនិយាយបាននោះ ពាក់ព័ន្ធនឹងផ្នែកទី១នេះ ជាមួយនឹងឯកសារ២០ ដែលបានផ្ញើជូនទៅភាគីកាលពីសប្ដាហ៍មុន <ឬនៅព្រឹក>នេះ សម្រាប់ភាគីមួយចំនួននោះ។ អ៊ីចឹងគឺឯកសារនោះស្ទើរតែចប់ទៅហើយ ពាក់ព័ន្ធនឹងវគ្គទី១នេះនោះ គឺមានតែឯកសារពីរ<បន្ថែមប៉ុណ្ណោះ> ដែលមានការពាក់ព័ន្ធនឹងវគ្គទី១នេះ ហើយយើងកំពុង<តែរង់ចាំទទួល>ការអនុញ្ញាត។ អ៊ីចឹងវាមិនមែនជាជម្រើសរបស់ខាងការិយាល័យយើងខ្ញុំក្នុងការមិនផ្ដល់ជូនឯកសារទាំងអស់នេះទៅឲ្យភាគីទេ។ យើងធ្វើតាមតែលទ្ធភាពដែលអាចធ្វើទៅបាន ហើយយើងធ្វើយ៉ាងណាដើម្បីឲ្យភាគីអាចត្រៀមខ្លួនបានដូចជាយើងអ៊ីចឹងដែរ។

[១៥:៤៣:២៥]

ចំពោះការដែលមិនអាចចូលទៅឯកសារអេឡិចត្រូនិកបាននោះ គឺជាការដាក់កំហិត<>ដោយ<>សហចៅក្រមស៊ើបអង្កេត<>។ អ៊ីចឹង<>អង្គជំនុំជម្រះមិនមែនជាអ្នកសម្រេចលើរឿងនេះទេ គឺ<>ចៅក្រមស៊ើបអង្កេតជាអ្នកសម្រេចថាឲ្យភាគីចូលទៅមើលឯកសារអេឡិចត្រូនិកបាន ឬក៏មិនបាននោះ។ អ៊ីចឹង ខ្ញុំគិតថាទៅថ្ងៃខាងមុខប្រហែលជាអាចមានដំណោះស្រាយផ្សេង ក៏ប៉ុន្តែ ឥឡូវនេះយើងធ្វើម៉េច យើងត្រូវតែគោរពទៅតាមកាតព្វកិច្ចរបស់យើងក្នុងការរក្សាការសម្ងាត់ ហើយនិងគោរពទៅ

តាមការបង្គាប់របស់សហចៅក្រមស៊ើបអង្កេតត្រង់ចំណុចនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ដើម្បីពន្យល់ឲ្យបានច្បាស់លាស់អំពីជំហររបស់យើងខ្ញុំ យើងយល់ច្បាស់អំពីការព្រួយបារម្ភរបស់មេធាវីការពារក្តី។ យើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ យើងចង់លើកឡើងអំពីការព្រួយបារម្ភរបស់យើងផងដែរ។ យើងបានធ្វើការ<ស្នើសុំជាយូរមកហើយ> ដើម្បីឲ្យការជំនុំជម្រះប្រព្រឹត្តទៅបានឆាប់រហ័ស និងឈានទៅមុខបានលឿន។ ដូច្នេះ យើងកំពុងតែដើរទៅមុខហើយ ហើយយើងក៏មានព័ត៌មានជាច្រើនដែលទទួលបានពីសហព្រះរាជអាជ្ញា។ ដូច្នេះ ដើម្បីឲ្យភាគីយល់អំពីជំហររបស់យើង យើងក៏អត់មានទទួលបានឯកសារអេឡិចត្រូនិកនៃសំណុំរឿង០០៣, ០០៤ ដូចគ្នាដែរ។

[១៥:៤៥:០៩]

មេធាវីយើងមួយចំនួននោះក៏មានកូនក្តីដែលបានតាំងខ្លួននៅក្នុងសំណុំរឿង០០៣, ០០៤ដែរ។ ពួកគាត់ៗអាចចូលមើលបាន ក៏ប៉ុន្តែពួកគាត់មិនអាចឲ្យយើងចូលមើលបានទេ។ អ៊ីចឹងនៅពេលដែលយើងបំពេញការងារយើងហ្នឹង យើងក៏មានការពិបាកដែរ។ ដូច្នេះ អ្វីៗគឺសម្រេចទៅលើអង្គជំនុំជម្រះ ការលំបាករបស់យើងគឺពាក់ព័ន្ធទៅនឹង<កំណត់ហេតុនៃការស្តាប់ចម្លើយ>ទាំង២០ដែល<យើងទទួលបាននៅ>ថ្ងៃហ្នឹង មិនមែន៨៩<ទេ> ហើយ<កំណត់ហេតុនៃការស្តាប់ចម្លើយចំនួន>១៩០ ដែលនឹង<បញ្ជូន>មកនៅពេលខាងមុខ<>។ យើងគឺអាចមានលទ្ធភាពពិនិត្យមើលនៅពេលក្រោយ។ ក៏ប៉ុន្តែយើងៗត្រូវរង់ចាំការបំភ្លឺពីការិយាល័យសហព្រះរាជអាជ្ញានៅថ្ងៃទី២៣ កុម្ភៈ ឯណោះ ដើម្បីអាចឲ្យយើងដឹងថាយើងអាចឆ្លើយតបយ៉ាងម៉េចបានទៅនឹងការដាក់ឯកសារហ្នឹង។ អ៊ីចឹង ធ្វើយ៉ាងម៉េចត្រូវមានការបំភ្លឺពីខាងសហព្រះរាជអាជ្ញាសិន។ ចំពោះយើងផ្ទាល់ យើងសូមជំទាស់ដាច់ខាតទៅនឹងការផ្អាកសវនាការ។ អ៊ីចឹង ខ្ញុំ -- យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើយ៉ាងម៉េចសម្រេច គឺក្រោយពេលទទួលបានការបំភ្លឺជាលាយលក្ខណ៍អក្សរពីខាងសហព្រះរាជអាជ្ញានៅថ្ងៃទី២៣ ខែកុម្ភៈសិន ទើបបានសូមឲ្យអង្គជំនុំជម្រះមេត្តាសម្រេចទៅលើបញ្ហានេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក រ៉ិចទ័រ កូប៉េ!

[១៥:៤៦:៣៦]

**លោក រ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឆ្លើយតបដោយសង្ខេបទេ។ តំណាងសហព្រះរាជអាជ្ញាបានលើកឡើងនូវបញ្ហា ថាតើពេលណាដែលយើងអាចអានកំណត់ហេតុទាំង២០នេះ។ <ខ្ញុំត្រូវការគេងយប់នេះ ដូច្នេះខ្ញុំគិតថា ខ្ញុំមិនអាច> ខ្ញុំមិនអាចអាន<កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំង២០នេះឲ្យចប់មុន>ថ្ងៃស្អែកបានទេ។ <គឺ>ថាឯកសារមួយនៅក្នុងចំណោមឯកសារទាំង២០ គឺចុះខែសីហា ឆ្នាំ២០១៣។ ដូច្នេះ ខ្ញុំមិនដឹងថាហេតុអ្វីបានជាយើងត្រូវរង់ចាំយូរម្ល៉េះ <ដើម្បីទទួលបានឯកសារនោះ>។ នៅថ្ងៃច័ន្ទ ការរង់ចាំទៅដល់ថ្ងៃចន្ទ គឺវាយឺតពេលហើយ។ ខ្ញុំគិតថាថ្ងៃពុធ ឬថ្ងៃព្រហស្បតិ៍ គឺវាជារឿងមួយដែលសំខាន់ណាស់ដែល<វាពាក់ព័ន្ធយ៉ាងសំខាន់នឹង>អតីតកម្មាភិបាល<ម្នាក់ដែល>ត្រូវមកផ្តល់សក្ខីកម្ម <ដូច្នេះគាត់អាចនឹងត្រូវសួរដេញដោល>ពាក់ព័ន្ធទៅនឹង<ខ្លឹមសារ>ឯកសារ២០នេះ។ ដូច្នេះការរង់ចាំរហូតដល់ថ្ងៃចន្ទ រហូតដល់ព្រះរាជអាជ្ញាឆ្លើយតបបញ្ហានេះ គឺថាវាយឺតពេលទៅហើយ។ ការដែលលើកឡើងថាយើងធ្វើពុត ដូចជាភ្ញាក់ផ្អើល ខ្ញុំមិនដឹងថាចង់និយាយថាយ៉ាងម៉េចនោះទេ។ ខ្ញុំមានប្រតិចារឹក ហើយខ្ញុំសូមឲ្យតំណាងសហព្រះរាជអាជ្ញា ថាតើៗយើងរំពឹងយ៉ាងដូចម្តេច <ហើយគាត់បានឆ្លើយថាវាមានចំនួនតិចតួច។ ឥឡូវនេះ គាត់ និងខ្ញុំ យល់ខុសគ្នា>ពាក់ព័ន្ធទៅនឹងឯកសារដែលមានចំនួនតូចបែបនេះ។ ក៏ប៉ុន្តែតាមពិតទៅ គឺថាមិនមែនតូចទេ គឺមានរហូតដល់ជិតដល់៣០០ឯកសារឯណោះ។ ដូច្នេះ ខ្ញុំមិនយល់ មិនដឹងថាកិច្ចដំណើរការនីតិវិធីជាមួយសាក្សីទាំងនេះធ្វើដោយរបៀបណានោះទេ <នៅក្នុងសប្តាហ៍នេះ>?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

[១៥:៤៨:១៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ជាក់ស្តែងគឺយើងត្រូវគិតអំពីបញ្ហានេះ។ សម្រាប់នៅថ្ងៃបន្តបន្ទាប់ ដើម្បីរៀបចំសម្រាប់នៅថ្ងៃបន្តបន្ទាប់ យ៉ាងហោចណាស់ ក៏មេធាវី -- ក្រុមមេធាវីការពារក្តី នួន ជា គាត់<មិន>មានបញ្ហាសម្រាប់ថ្ងៃស្អែក<ទេ តើត្រឹមត្រូវទេ? តើយើងឯកភាពគ្នាលើកចំណុចនេះទេ?>។

**លោក វិចទ័រ កូប៉េ៖**

សម្រាប់ថ្ងៃស្អែកមិនបញ្ហាទេលោកស្រីចៅក្រម ប៉ុន្តែសម្រាប់បន្ទាប់មួយទៀត។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ចុះមេធាវីការពារ ខៀវ សំផន យ៉ាងម៉េចដែរសម្រាប់ថ្ងៃស្អែក?

<ចាស គឺយល់ព្រម។>

ក៏ប៉ុន្តែ សាក្សីសម្រាប់ថ្ងៃពុធ តាមការយល់របស់លោកគឺថា អាចវាបញ្ហា<ដែរឬទេ?>

**លោក វិចទ័រ កូប៉េ៖**

<អាចជាបឋមនោះ គឺថាគ្រាន់តែ>អានកំណត់ហេតុទាំង២០ <មុនទេ គឺវាហាក់បីដូចជា>មានប៉ះពាល់យ៉ាងសំខាន់ពាក់ព័ន្ធទៅនឹង<សាក្សីនៅ>ថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍។ ប៉ុន្តែនេះគឺជាការអានត្រួសៗមួយភ្លែតប៉ុណ្ណោះ។> មិនមានអ្វី<ច្រើន ដែលយើងអាចនិយាយឥឡូវនេះ>ទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

ខ្ញុំមានការបញ្ជាក់មួយ លោកប្រធាន។ វាអាចមានឯកសារមួយចំនួនបន្ថែមទៀត ក៏ប៉ុន្តែវាមានការ ដែលៗបង្ហាញថាវាមានការពន្យារពេលដោយសារតែមានការត្រូវការរង់ចាំការអនុញ្ញាតពីខាងអូ.ស៊ី.អាយ.ជេ។ ដូច្នេះពេលខ្លះនោះ យើងអត់បានជូនទៅភាគីមុនពេលកាលកំណត់ទេ ព្រោះដោយសារតែជាការសម្ងាត់របស់ខាងការស៊ើបអង្កេត។ ដូច្នេះឯកសារឆ្នាំ២០១៣នោះគឺថា<វាមិនចាំបាច់ក្នុងការ>ជូនដំណឹង<នៅក្នុងឆ្នាំ>២០១៣<នោះទេ> ក៏ប៉ុន្តែពេលខ្លះ <យើងអាចត្រូវរង់ចាំជាច្រើនខែ ឬក៏វែងជាងនេះ។> នៅពេលដែល ឌេល លីសាក់ គាត់និយាយអំពីឯកសារមួយចំនួនតូចនោះ ខ្ញុំគិតថាគាត់យោងទៅលើ<>ផ្នែកទី១<នៃសវនាការ។> គាត់មិនយោងទៅលើផ្នែកផ្សេងៗទៀតនៃសវនាការយើងនេះទេ។ ដូចយើងបានបញ្ជាក់កាលពីខែមិថុនា ឆ្នាំ២០១៤ <យើងបានប្រកាស>រួចមកហើយ<ថានឹងមានកំណត់ហេតុនៃការស្តាប់ចម្លើយចំនួន២៦៧ ហើយខ្ញុំបានប្រាប់អង្គជំនុំជម្រះកាលពីព្រឹកនេះ> ពាក់ព័ន្ធនឹងផ្នែកទី២ យើងកំពុងតែរង់ចាំការអនុញ្ញាតដើម្បីបញ្ជូន<កំណត់ហេតុនៃការស្តាប់ចម្លើយចំនួន>៦០<> ដែលពាក់ព័ន្ធ ជាពិសេសទៅនឹងទំនប់ត្រពាំងថ្ម។ នេះជាការបញ្ជាក់ជូនអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-934 ចូលមកកាន់បន្ទប់ កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៥:៥២:៣០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីលោកសាក្សី។ តើលោកឈ្មោះអី?

**លោក ភ្នៅ យ៉ាវ៖**

**ឆ៖** សូមគោរពលោកប្រធាន ខ្ញុំបាទឈ្មោះ ភ្នៅ យ៉ាវ។

**ស៖** បាទ អរគុណលោក ភ្នៅ យ៉ាវ។ តើលោកកើតនៅថ្ងៃ ខែ ឆ្នាំណាដែរ? លោកចាំថ្ងៃ ខែ ឆ្នាំកំណើតរបស់លោកដែរឬទេ?

**ឆ៖** បាទ កើតនៅឆ្នាំ១៩៤៧ បាទ។

**ស៖** អរគុណលោក ភ្នៅ យ៉ាវ ហើយតើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា? លោកចាំទេ?

**ឆ៖** បាទ ខ្ញុំបាទចាំដែរ ទីកន្លែងនៅភូមិប៉ែនមាស ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវបាទ។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃរបស់លោក តើលោកមានទីលំនៅនៅទីកន្លែងណា?

**ឆ៖** បាទ ទីលំនៅបច្ចុប្បន្ននៅកន្លែងដដែលហ្នឹងលោកប្រធាន បាទ។

**ស៖** បាទ អរគុណ។ ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរសព្វថ្ងៃលោក ភ្នៅ យ៉ាវ?

**ឆ៖** បាទ សូមទោស ខ្ញុំបច្ចុប្បន្នធ្វើស្រែចំការ ហើយធ្វើអាចារ្យវត្តនៅវត្តអង្គសីមាបាទ។

**ស៖** បាទ អរគុណ។ ចុះឪពុករបស់លោកឈ្មោះអី? ហើយម្តាយរបស់លោកគាត់ឈ្មោះអីដែរ?

**ឆ៖** បាទ ឪពុកខ្ញុំបាទឈ្មោះ ភ្នៅ ឆេង។ ម្តាយ ឈ្មោះ រៀម ឈ្មួន ស្លាប់បាទ។

**ស៖** អរគុណ។ ហើយចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ សែស វ៉ាន់ ហើយមានកូនប្រាំមួយនាក់ ប្រុសមួយ ស្រីប្រាំបាទ។

**ស៖** បាទអរគុណលោក ភ្នៅ យ៉ាវ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា កាលពី

ព្រឹកមិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានឪពុកម្ដាយ បុព្វញាតិ កូន បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធ ត្រូវទទួលស្គាល់ធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីនៅរឿងក្ដីនេះទេ។ តើពិតមែនដែរឬទេ?

[១៥:៥៥:០៣]

**ឆ៖** បាទ ពិតមែនលោកប្រធានបាទ។

**ស៖** តើលោកបានសម្បថនៅចំពោះមុខអ្នកតាដំបងដែកដែលនៅពីកើត -- ខាងកើតសាលសវនាការនេះហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបាទបានសម្បថហើយ លោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ភ្នៅ យ៉ាវ។ ឥឡូវនេះ យើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចក្នុងនាមលោកជាសាក្សីនៅចំពោះអង្គជំនុំជម្រះ។ អំពីសិទ្ធិក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះអង្គជំនុំជម្រះនេះ លោកអាចបដិសេធនៅក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំដាក់ពិរុទ្ធភាពលើខ្លួនឯងនេះ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះនាំលោកនឹងត្រូវទទួលរងការចោទប្រកាន់។ អំពីករណីយកិច្ច លោក ភ្នៅ យ៉ាវ ក្នុងនាមលោកជាសាក្សីត្រូវផ្ដល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមអង្គជំនុំជម្រះសួរចំពោះលោក។ លើកលែងតែសំណួរ ឬអំណះអំណាងដែលនាំឲ្យលោកឆ្លើយតបទៅដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានជម្រាបជូនខាងលើអ៊ីចឹង។ ក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមអង្គជំនុំជម្រះសួរចំពោះលោក។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ភ្នៅ យ៉ាវ តើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយប្រសិនបើមាន តើធ្វើប៉ុន្មានដង? ធ្វើនៅទីកន្លែងណា? ធ្វើនៅពេលណា?

[១៥:៥៧:៣៤]

**លោក ភ្នៅ យ៉ាវ៖**

**ឆ៖** ខ្ញុំបាទធ្លាប់ធ្វើម្ដងដែរលោកប្រធាន ធ្វើនៅផ្ទះខ្ញុំបាទតែម្ដងទានបាទ។

**ស៖** ពីពេលណា លោកចាំទេ?

**ឆ៖** បាទ ខ្ញុំភ្លេចឆ្នាំហើយលោកប្រធានបាទ។

**ស៖** បាទ មិនអីទេលោក ភ្នៅ យ៉ាវ។ ហើយមុនពេលចូលមកមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបានពិនិត្យមើល ឬអាននូវកំណត់ហេតុដែលលោកបានផ្ដល់ចម្លើយកាលពីដែលលោកធ្វើនាពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលលោកអះអាងថាធ្វើនៅផ្ទះរបស់លោក ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ លោកប្រធាន ខ្ញុំចាំខ្លះ ភ្លេចខ្លះហើយដែរព្រោះយូរឆ្នាំដែរ លោកប្រធានបាទ។

**ស៖** លោកមានបានពិនិត្យមើលកំណត់ហេតុហ្នឹងឡើងវិញដែរទេ មុនពេលចូលមកអង្គុយនៅទីនេះ?

**ឆ៖** បាទ ខ្ញុំបានពិនិត្យខ្លះដែរអំមិញ ប៉ុន្តែវាអត់សូវចាំ លោកប្រធានបាទ។

**ស៖** បាទ អរគុណ។ តាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំ តើលោកអាចបញ្ជាក់បានដែរឬទេថា កំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្មកាលពីធ្វើនាពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីរំឭកការចងចាំនោះ ហើយវាៗសមស្របដែរឬទេ នូវអ្វីដែលលោកបានអានមុនពេលនេះបន្តិចនោះ?

[១៥:៥៩:១២]

**ឆ៖** បាទ លោកប្រធាន សមស្របដែលលោកប្រធាន អត់អីទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនលោក ភ្នៅ យ៉ាវ។ ហើយយើងគ្រាន់តែសួរព័ត៌មានលោកបឋមប៉ុណ្ណោះទេ។ ដោយសារនៅរសៀលនេះអស់ពេលហើយ ហើយកិច្ចដំណើរការសវនាការរបស់លោក អង្គជំនុំជម្រះមិនទាន់បានស្ដាប់នូវសក្ខីកម្មសារធាតុរបស់លោកនៅឡើយទេ។ ដូច្នេះ អង្គជំនុំជម្រះនឹងកោះអញ្ជើញៗលោកមកផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ឲ្យបានមុនម៉ោងប្រាំបួនព្រឹក ហើយទំនងជាធ្វើតែមួយពេលស្អែកទេ នឹងចប់ហើយណា។

បាទ សវនាការថ្ងៃនេះឃើញថាដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១៧ ខែកុម្ភៈ ឆ្នាំ២០០៥*(ស៊ិក)* ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី ភ្នៅ យ៉ាវ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់។

ហើយបង្គាប់ឲ្យអនុរក្ស -- ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងបង្គាប់ឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅថ្ងៃស្អែក នៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងប្រាំបួន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វត.ត.ក វិញចុះ ហើយឲ្យបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*